Food and Agriculture
Organization of the
United Nations



# ការយល់ព្រមដោយពេញចិត្តដោយ បានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន)

## សៀវភៅណែនាំអំពីការអនុវត្តជាក់ស្តែងសម្រាប់រដ្ឋាភិបាល ក្រុមហ៊ុន អង្គការមិនមែនរដ្ឋាភិបាល ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី



សៀវភៅណែនាំបច្ចេកទេសស្តីពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់លេខ៣

# ការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ( ការយល់ព្រមជាមុន )

សៀវភៅណែនាំអំពីការអនុវត្តជាក់ស្តែងសម្រាប់រដ្ឋាភិបាល ក្រុមហ៊ុន
អង្គការមិនមែនរដ្ឋាភិបាល ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន
ពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី



អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)
ទីក្រុងរ៉ូម ឆ្នាំ២០២១

**គុណភាពថា**

FAO.២០២១។ *ការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន) – សៀវភៅណែនាំអំពីការអនុវត្តជាក់ស្តែងសម្រាប់រដ្ឋាភិបាល ក្រុមហ៊ុន អង្គការមិនមែនរដ្ឋាភិបាល ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ពាក់ព័ន្ធនឹងលទ្ធកម្មដីធ្លី។ សៀវភៅណែនាំបច្ចេកទេសស្តីពីអភិបាលកិច្ចលើសិទ្ធិកាន់កាប់លេខ៣។ ភ្នំពេញ។*

ឯកសារនេះរៀបចំឡើងក្នុងគោលបំណង គាំទ្រដល់ការប្រើប្រាស់ គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ច ប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដី ជលផល និងព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀងជាតិ។ ឯកសារនេះ មិនមានខ្លឹមសារផ្ទុយពីអ្វីដែលបានកំណត់ក្នុងគោលការណ៍ណែនាំ ដែលអនុម័តដោយគណៈកម្មាធិការសន្តិសុខស្បៀង ពិភពលោក នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២ និងតួនាទីរបស់បណ្តារដ្ឋក្នុងការអនុវត្តគោលការណ៍ណែនាំទាំងនោះឡើយ។

ឯកសារនេះចងក្រងឡើងក្រោមជំនួយរបស់អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO)មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) និងសហភាពអឺរ៉ុប (EU)។ទស្សនៈដែលបានស្តែងចេញនៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងពុំបាន ឆ្លុះបញ្ចាំងអំពីទស្សនៈ ឬ គោលនយោបាយ របស់អង្គការ FAO ឬ IFAD ឬសហភាពអឺរ៉ុបឡើយ។

ការប្រើឈ្មោះទាំងឡាយ និងព័ត៌មានផ្សេងៗដែលមានបង្ហាញក្នុងឯកសារនេះមិនមែនជាការសម្តែងមតិណាមួយរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់ ឬស្ថានភាពអភិវឌ្ឍន៍របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬ អាជ្ញាធរនៃប្រទេស ដែនដី ទីក្រុង ឬតំបន់ ឬពាក់ព័ន្ធនឹងការកំណត់ព្រំដែន របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនេះឡើយ។ ការលើកឡើងជាក់លាក់អំពីក្រុមហ៊ុន ឬផលិតផលរបស់ផលិតករណាមួយ ទោះបីជាក្រុមហ៊ុន ឬផលិតផលទាំងនេះមាន ឬគ្មានប្រកាសនីយបត្រតក្កកម្មក្តី មិនមែនមានន័យថាក្រុមហ៊ុន ឬផលិតផលទាំងនេះត្រូវបានគាំទ្រ ឬណែនាំដោយអង្គការ FAO ថាមានឧត្តមភាពជាងក្រុមហ៊ុន ឬផលិតផលស្រដៀងគ្នាដទៃទៀតដែលមិនបានលើកឡើងនោះទេ។

ទស្សនៈដែលបានស្តែងចេញនៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងពុំបានឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលនយោបាយ របស់អង្គការ FAO ឡើយ។

ISBN 978-92-5-134323-4

© FAO, ២០២១
© FAO, ២០១៤ (ភាសាអង់គ្លេស)

Some rights reserved. This work is made available under the Creative Commons Attribution-NonCommercial-ShareAlike 3.0 IGO licence (CC BY-NC-SA 3.0 IGO; https://creativecommons.org/licenses/by-nc-sa/3.0/igo/legalcode).

ក្រោមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ Creative Commons ឯកសារនេះ អាចត្រូវបានថតចម្លង ចែកចាយ និងកែសម្រួលសម្រាប់គោលបំណងដែលមិនមែនជាអាជីវកម្ម ក្នុងករណីដែលមានការធ្វើសេចក្តីយោងមកឯកសារនេះឱ្យបានត្រឹមត្រូវ។ ក្នុងការប្រើប្រាស់ណាមួយក៏ដោយនៃឯកសារនេះ មិនត្រូវលើកឡើងថាអង្គការ FAO គាំទ្រដល់ អង្គការ ផលិតផល ឬសេវាកម្មជាក់លាក់ណាមួយឡើយ។ ការប្រើប្រាស់រូបសញ្ញារបស់អង្គការ FAO មិនត្រូវបានអនុញ្ញាតឡើយ។ ប្រសិនបើ ឯកសារនេះ ត្រូវបានកែសម្រួលនោះ តម្រូវឱ្យមានអាជ្ញាប័ណ្ណក្រោមអាជ្ញាប័ណ្ណ Creative Commons ដូចគ្នា ឬប្រហាក់ប្រហែលនេះ។ ប្រសិនបើ មានការបកប្រែឯកសារនេះ តម្រូវឱ្យមានប្រយោគបដិសេធ ព្រមទាំងការបង្ហាញសេចក្តីយោងមកឯកសារនេះ ហើយប្រយោគបដិសេធមានខ្លឹមសារដូចតទៅ៖“ការបកប្រែនេះ មិនត្រូវបានធ្វើឡើងដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)ទេ។ អង្គការ FAO មិនទទួលខុសត្រូវចំពោះខ្លឹមសារ ឬភាពត្រឹមត្រូវនៃការបកប្រែនេះឡើយ។ ការបោះពុម្ព ក្នុងភាសាដើម គឺជាការបោះពុម្ពផ្សាយជាផ្លូវការ។

វិវាទដែលកើតឡើងក្រោមអាជ្ញាប័ណ្ណដែលមិនអាចដោះស្រាយដោយមេត្រីភាព នឹងត្រូវដោះស្រាយដោយការសម្រុះសម្រួល និងអាជ្ញាកណ្តាលដូចដែលមានចែងក្នុងមាត្រាទី ៨ នៃអាជ្ញាប័ណ្ណ លើកលែងតែមានចែងនៅទីនេះ។ វិធាននៃការសម្រុះសម្រួលដែលអាចអនុវត្តបាន គឺជាវិធាននៃការសម្រុះសម្រួលរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកhttp://www.wipo.int/amc/en/mediation/rules ហើយរាល់ការធ្វើអាជ្ញាកណ្តាលណាមួយ នឹងត្រូវធ្វើឡើងស្របតាមវិធានអាជ្ញាកណ្តាលរបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពី ច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) ។

**សម្ភារៈរបស់ភាគីទីបី៖** អ្នកប្រើប្រាស់ ដែលមានបំណងប្រើប្រាស់ ព័ត៌មានក្នុងឯកសារនេះ ដែល ជាកម្មសិទ្ធិរបស់ភាគីទីបី ដូចជា តារាង តួលេខ ឬរូបភាព មានទំនួលខុសត្រូវក្នុងការកំណត់លើតម្រូវការនៃការស្នើសុំ ការអនុញ្ញាត និងសម្រាប់ការទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិក្នុងការប្រើប្រាស់ឡើងវិញនៃព័ត៌មានទាំងនេះ។ ហានិភ័យនៃការទាមទារដែលបណ្តាលមកពីការរំលោភលើសមាសធាតុដែលជាកម្មសិទ្ធិរបស់ភាគីទីបីនៅក្នុងឯកសារនេះ គឺស្ថិតនៅក្រោមទំនួលខុសត្រូវរបស់អ្នកប្រើប្រាស់ប៉ុណ្ណោះ។

**ការលក់ សិទ្ធិ និងការផ្តល់អាជ្ញាប័ណ្ណ៖** ការបោះពុម្ពផ្សាយរបស់អង្គការ FAO មាននៅលើគេហទំព័រ (www.fao.org/publications) ហើយអាចរកជាវបានតាមរយៈ publications-sales@fao.org។ សំណើរសម្រាប់ប្រើប្រាស់ក្នុងលក្ខណៈអាជីវកម្ម តម្រូវឱ្យមានការស្នើសុំតាមរយៈ៖ www.fao.org/contact-us/licence-request ។ សំណួរទាក់ទងនឹងសិទ្ធិ និងការផ្តល់អាជ្ញាប័ណ្ណគួរធ្វើឡើងតាមរយៈសារអេឡិចត្រូនិចទៅកាន់ ៖ copyright@fao.org ។

# សេចក្តីថ្លែងអំណរគុណ

ការណែនាំផ្នែកបច្ចេកទេសនេះ ត្រូវបានរៀបចំឡើងក្រោមការចង្អុលបង្ហាញពី Francesca Romano ដោយមានការសហការពីក្រុមមកពីកម្មវិធី the Forest Peoples Programme និង Samuel Nguiffo មកពីមជ្ឈមណ្ឌល Cetre pour l'Environment et le Developpement (CED) ក្នុងប្រទេសកាមេរូន។ ការណែនាំនេះ ត្រូវបានតាក់តែងឡើងដោយ Marcus Colchester និង Sophie Chao ដោយមានការរួមចំណែកពីសិក្ខាកាមចូលរួមក្នុងសិក្ខាសាលាធ្វើសេចក្តីព្រាង ដូចជា Messe Venant, Ali Kaba, Alfred Brownell, Francis Collee, Jean-Marie Muanda, Norman Jiwan, Tang Men Kon, Arun Venkatarman, Alexandra Booth, Frederic Parfait Harold, Nina Koubahangoue, Henri Muyembe Ngasili, Hon. Dr Walter Wisner, Hon. Dr Brahima Kaba, Jean-Marie Vianney Bendegue, Philippe Karpe, Joseph Bisso, Jean-Guy Motto-Mallo និង Alain Bernard Atangana Tabi ។

ការងារនេះ អាចសម្រេចជោគជ័យទៅបាន ដោយសារមានការសហការយ៉ាងជិតស្និទ្ធពីសហសេវិកជាច្រើនទៀត ជាពិសេសក្រុមមកពីកម្មវិធី the Forest Peoples Programme ដូចជា Tom Lomax, Emmanuel Freudenthal, Stephanie Vig, John Nelson, Justin Kenrick, Valerie Couillard និង Fergus Mackey និងក្រុមមកពីមជ្ឈមណ្ឌល CED ដូចជា Samuel Nguiffo និង Pauline Ebelle Bessoka ។

ការបោះពុម្ពផ្សាយនេះ ត្រូវបានពិនិត្យឡើងវិញដោយ Paolo Groppo, Margret Vidar, Thea Hilhorst, Christopher Tanner, Lorenzo Cotula, Laura German, Antonella Cordone, Joanna Athlin, Alexandre Ghelew និងក្រុមការងារអាល្លឺម៉ង់ស្តីពីដីធ្លី ដែលរៀបចំឡើងដោយទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ)។ ឯកសារនេះ ត្រូវបានកែសម្រួលដោយ Anna Barnett និងរចនាដោយ Luca Feliziani ។

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ សូមថ្លែងអំណរគុណដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងតំណាងរាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិជនជាតិ ដើមភាគតិច រាល់ការផ្តល់ជាមតិយោបល់ និងការណែនាំក្នុងដំណាក់កាលពិនិត្យឡើងវិញ។

ការស្រាវជ្រាវ និងការព្រាងឯកសារនេះទទួលបានជំនួយហិរញ្ញវត្ថុពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) ចំណែកការបោះពុម្ព ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីសហគមន៍អឺរ៉ុប តាមរយៈកម្មវិធីលើកកម្ពស់អភិបាលកិច្ចសកលសម្រាប់ការកាត់បន្ថយគ្រោះអត់ឃ្លាន។

# អារម្ភកថា

សិទ្ធិកាន់កាប់ និងការគ្រប់គ្រងសិទ្ធិទាំងនោះ គឺជាសមាសធាតុដ៏សំខាន់ក្នុងការកំណត់ថាតើ ប្រជាជន សហគមន៍ និងបុគ្គលផ្សេងទៀតអាចទទួលបានសិទ្ធិក្នុងការប្រើប្រាស់ និងគ្រប់គ្រងដី និងធនធានធម្មជាតិផ្សេងទៀត ឬយ៉ាងណា និងរបៀបដែលពួកគេអាចទទួលបានសិទ្ធិទាំងនោះ។ ការគ្រប់គ្រងសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ ជួយជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាពដែលអាចជួយកាត់បន្ថយភាពក្រីក្រ និងអសន្តិសុខស្បៀង និងជំរុញឱ្យមានការវិនិយោគប្រកបដោយការទទួលខុសត្រូវ។ ការលើកកម្ពស់ការគ្រប់គ្រងសិទ្ធិកាន់កាប់គឺ ជាគោលបំណងរបស់ *គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពី អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដី ជលផល និង ព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀងជាតិ* (គោលការណ៍ណែនាំ) ដែលប្រើប្រាស់ជាឯកសារយោង និងកំណត់គោលការណ៍ និងស្តង់ដារដែលទទួលស្គាល់ជាអន្តរជាតិ សម្រាប់ការអនុវត្តដែលមានការទទួលខុសត្រូវ។

ការគ្រប់គ្រងដី និងធនធានធម្មជាតិមិនបានត្រឹមត្រូវ បូករួមនឹងកង្វះសិទ្ធិកាន់កាប់ដោយសុវត្ថិភាព ក្នុងបរិបទនៃកំណើនប្រជាជនសកលកំណើនកម្រិតជីវភាពរស់នៅកំណើនតម្លៃទំនិញពាណិជ្ជកម្មសកល និងការប្រើប្រាស់ដំណាំស្បៀងដូចជាជីវឥន្ធនៈកំពុងដាក់សម្ពាធខ្លាំងលើដីកសិកម្មនិងព្រៃឈើ។លទ្ធកម្មដីធ្លីដោយ ពុំមានច្បាប់ទម្លាប់គ្រប់គ្រងត្រឹមត្រូវ បានក្លាយជាបញ្ហាចម្បង ជាពិសេស ក្នុងអនុតំបន់អាហ្វ្រិកសាហារ៉ា និងអាស៊ីអា-គ្នេយ៍ ដោយបង្កជាការគំរាមកំហែងដល់សន្តិសុខស្បៀង របរចិញ្ចឹមជីវិតក្នុងមូលដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ព្រមទាំងធ្វើឱ្យមានជម្លោះដីធ្លី និងការរំលោភសិទ្ធិមនុស្ស។ ក្រុមដែលប្រឈមនឹងហានិភ័យបំផុត គឺក្រុមបាត់បង់ឱកាសក្នុងសង្គមដូចជា ជនជាតិដើមភាគតិច ម្ចាស់កម្មសិទ្ធិដីប្រពៃណីផ្សេងទៀត ស្ត្រី ប្រជាជនក្រីក្រ និងជនជាតិភាគតិច។

ក្តីបារម្ភអំពីផលវិបាករយៈពេលវែងផ្នែកសង្គម និងបរិស្ថានពាក់ព័ន្ធនឹងកំណើនលទ្ធកម្មដីធ្លី កំពុងមានទំហំកាន់តែធំធេង ហើយស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ និងស្ថាប័នកំណត់ស្តង់ដារ បានចាប់ផ្តើមស្រាវជ្រាវ និងអនុវត្តស្តង់ដារ និងនីតិវិធីថ្មីៗ ដែលត្រូវបានរៀបចំឡើង ដើម្បីជួយគ្រប់គ្រងដំណើរការនេះ។កិច្ចការនេះមិនមែនរារាំងរារាំងមិនឱ្យមានការវិនិយោគ និងបង្ការកុំឱ្យមានការអភិវឌ្ឍលើដីកសិកម្មថ្មីនោះទេ ប៉ុន្តែធានាថាកំណើននេះ កើតមានឡើងដោយមានការគោរពសិទ្ធិមនុស្ស ធានាជីវភាពរស់នៅប្រកបដោយនិរន្តរភាពនិងការអនុគ្រោះព្រមទាំងបញ្ចៀសកុំឱ្យមានសម្ពាធលើតំបន់ដែលមានសារសំខាន់ដល់ជីវភាពរស់នៅក្នុងមូលដ្ឋាននិងផ្តល់គុណតម្លៃអភិរក្សកម្រិតខ្ពស់។

គោលការណ៍ណែនាំនេះ បានលើកឡើងថា ការវិនិយោគដែលមានការទទួលខុសត្រូវ មិនត្រូវបង្កការបំផ្លិចបំផ្លាញឡើយ ប៉ុន្តែត្រូវធានាមិនឱ្យមានការដកហូតកម្មសិទ្ធិពីអ្នកមានសិទ្ធិកាន់កាប់ស្របច្បាប់ និងការហិនហោចបរិស្ថាន ហើយគួរគោរពសិទ្ធិមនុស្ស។

សៀវភៅណែនាំបច្ចេកទេសស្តីពី*ការយល់ព្រមដោយពេញចិត្ត និងប្រាប់ឱ្យដឹងជាមុនដោយបានទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន)* (FPIC) បានកំណត់វិធានការជាក់ស្តែង ដើម្បីឱ្យទីភ្នាក់ងាររដ្ឋាភិបាលគោរព និងការពារការគោរពចំពោះការយល់ព្រមជាមុន (FPIC) និងដើម្បីឱ្យអង្គការសង្គមស៊ីវិល អ្នកប្រើប្រាស់ដី និងវិនិយោគិនឯកជននៅជុំវិញពិភពលោក អនុលោមតាមការទទួលខុសត្រូវរបស់ពួកគេពាក់ព័ន្ធនឹងការគោរពចំពោះការយល់ព្រមជាមុន ដូចបានអនុម័តដោយគោលការណ៍ណែនាំនេះ។

**Maria Helena Semedo**
*អគ្គនាយករង*
អ្នកសម្របសម្រួលផ្នែកធនធានធម្មជាតិ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........ III
អារម្ភកថា ........ IV

**សេចក្តីផ្តើម ១**

ហេតុអ្វីបានជាអ្នកត្រូវការការណែនាំសំខាន់ៗនេះ? ........ ៣
ភារកិច្ច និងការទទួលខុសត្រូវ ........ ៨
តើគេគួរទទួលបានការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ(ការយល់ព្រមជាមុន)ពីនរណា? ........ ១០
អត្ថប្រយោជន៍នៃការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ(ការយល់ព្រមជាមុន ) ........ ១១

**សេចក្តីណែនាំអំពីការអនុវត្តជាក់ស្តែង ១៣**

ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្ត ........ ១៥
ការកំណត់រកអ្នកមានសិទ្ធិ ........ ១៩
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ២០
ការបញ្ជាក់អះអាងពីស្ថានភាពស្របច្បាប់របស់ដី ........ ២២
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ២៣
ការរៀបចំផែនទីទាមទារយក និងការប្រើប្រាស់ដី ........ ២៥
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ២៥
ចំណុចដែលត្រូវពិចារណា ........ ២៨
ការបញ្ចប់ដំណើរការរៀបចំផែនទី ........ ២៩
ការកំណត់រកស្ថាប័ន និងតំណាងដែលត្រូវធ្វើសេចក្តីសម្រេច ........ ២៩
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ៣០
ការរៀបចំការពិគ្រោះយោបល់ម្តងហើយម្តងទៀត និងការចែករំលែកព័ត៌មាន ........ ៣២
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ៣៣
ការផ្តល់លទ្ធភាពទទួលបានប្រភពព័ត៌មាន និងការណែនាំដោយឯករាជ្យ ........ ៣៨
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ៣៨
ការសម្រេចបានកិច្ចព្រមព្រៀង និងការជំរុញប្រសិទ្ធភាពនៃកិច្ចព្រមព្រៀង ........ ៣៩
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ៣៩
ការពិនិត្យតាមដាន និងការបញ្ជាក់កិច្ចព្រមព្រៀង ........ ៤១
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ៤២
ការបង្កើតដំណើរការបណ្តឹងសាទុក្ខ ........ ៤៣
តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា? ........ ៤៣
ការផ្តល់លទ្ធភាពទទួលបានដំណោះស្រាយ និងដំណោះស្រាយជម្លោះ ........ ៤៤

តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា?.................................................................៤៤
**ឧបសម្ព័ន្ធ ៤៧**
ឧបសម្ព័ន្ធ ១ ៖ ជំហានស្នើឡើងក្នុងដំណើរការនៃការគោរពការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ(ការយល់ព្រមជាមុន)................៤៩
ឧបសម្ព័ន្ធ ២ ៖ សំណួរសំខាន់ៗ.....................................................................................៥០
សំណួរដែលអ្នកត្រូវឆ្លើយ ៖ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ................................៥០
សំណួរដែលអ្នកត្រូវឆ្លើយ ៖ ក្រុមហ៊ុន និងវិនិយោគិន ..........................................................៥៣
សំណួរដែលអ្នកត្រូវឆ្លើយ ៖ មន្ត្រីរដ្ឋាភិបាល ......................................................................៥៥
សំណួរដែលអ្នកត្រូវឆ្លើយ ៖ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអង្គការ ជនជាតិដើមភាគតិច...........................................................................................................៥៦
ឧបសម្ព័ន្ធ ៣ ៖ ឯកសារយោង និងអំណានបន្ថែម ..............................................................៥៨

ការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន ) និងគោលការណ៍ណែនាំ.....................................................................៤
សមាសធាតុនៃការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មាន ពេញលេញ(ការយល់ព្រមជាមុន ).......................................................................................៦
ច្បាប់ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច (IPRA) ក្នុងប្រទេសហ្វីលីពីន.........................................៨
ការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន )ផ្តោតលើលទ្ធផល និងដំណើរការ.....................................................១១
កត្តាដែលប៉ះពាល់ពេលវេលា និងធនធានចាំបាច់ក្នុងការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ(ការយល់ព្រមជាមុន )................១៦
តើអ្វីខ្លះជាសិទ្ធិជាប្រពៃណី? .....................................................................................១៩
គោលការណ៍ណែនាំស្តីពីគុណតម្លៃផ្នែកវប្បធម៌របស់ដី និងធនធានធម្មជាតិ..................................២១
គោលការណ៍ណែនាំស្តីពីលទ្ធភាពទទួលបានព័ត៌មាន និងការមិនរើសអើង..................................៣៣
គោលការណ៍ណែនាំស្តីពីសន្តិសុខស្បៀង និងរបរចិញ្ចឹមជីវិត.....................................................៣៦
ការព្រមព្រៀងដោយជូនដំណឹង ......................................................................................៣៨
ជម្រើសនៃសិទ្ធិកាន់កាប់ និងម្ចាស់ភាគហ៊ុន.......................................................................៣៩
មូលដ្ឋានគ្រឹះនៃការចរចាប្រកបដោយប្រសិទ្ធភាព ................................................................៤០
គោលការណ៍ណែនាំស្តីពីបណ្តឹងសាទុក្ខដំណោះស្រាយ និងដំណោះស្រាយជម្លោះ.........................៤៣
សិទ្ធិទទួលបានដំណោះស្រាយ .....................................................................................៤៤

# សេចក្ដីផ្ដើម



# សេចក្តីផ្តើម

## ហេតុអ្វីបានជាអ្នកត្រូវការការណែនាំជាក់ស្តែងនេះ?

ការវិនិយោគខ្នាតធំលើដីធ្លី កំពុងមានកំណើនយ៉ាងខ្លាំងជាងពេលណាៗទាំងអស់ នៅភាគខាងត្បូងនៃសកលលោក។ ជាញឹកញាប់ ការវិនិយោគទាំងនេះ ផ្តោតលើដីដែលកាន់កាប់ដោយសិទ្ធិជាប្រពៃណី ដែលពុំមានការទទួលស្គាល់ និងការការពារពេញលេញក្រោមច្បាប់ជាតិ ឬទីកន្លែង ដែលរដ្ឋាភិបាលមិនសូវមានសមត្ថភាពក្នុងការពង្រឹងការអនុវត្តច្បាប់។ ការទិញដូរដី ដែលផ្លាស់ប្តូរការប្រើប្រាស់ដី និងធនធានធម្មជាតិ បានបង្កផលវិបាកជាច្រើនសម្រាប់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ដែលពឹងអាស្រ័យលើធនធានទាំងនេះ សម្រាប់ការចិញ្ចឹមជីវិត សុខុមាលភាព និងអត្តសញ្ញាណវប្បធម៌របស់ខ្លួន។ លទ្ធកម្មដីធ្លីដោយពុំមានច្បាប់ គ្រប់គ្រងត្រឹមត្រូវ បានក្លាយជាបញ្ហាចម្បង ជាពិសេស ក្នុងអនុតំបន់អាហ្វ្រិកសាហារ៉ា និងតំបន់អាស៊ីអាគ្នេយ៍ ដែលប្រការនេះ បានគំរាមកំហែងដល់សន្តិសុខស្បៀង ជីវភាពរស់នៅក្នុងមូលដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព និងបានបង្កឱ្យមានជម្លោះដីធ្លី និងការរំលោភបំពានសិទ្ធិមនុស្ស។ ក្រុមបាត់បង់ឱកាសក្នុងសង្គមមានហានិភ័យខ្ពស់ជាងគេដូចជាជនជាតិដើមភាគតិចអ្នកកាន់កាប់ដីជាប្រពៃណីផ្សេងទៀត ស្ត្រី ប្រជាជនក្រីក្រ និង ជនជាតិភាគតិច។

កាលពីខែឧសភា ឆ្នាំ២០១២ គណៈកម្មាធិការសន្តិសុខស្បៀងអាហារពិភពលោក (CFS) បានអនុម័ត *គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីសិទ្ធិកាន់កាប់ដីធ្លី ជលផល និងព្រៃឈើប្រកបដោយការទទួលខុសត្រូវក្នុងបរិបទសន្តិសុខស្បៀងជាតិ*( ពីពេលនេះតទៅហៅថា គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត )។ គោលការណ៍ណែនាំទាំងនេះ បានផ្តល់ការណែនាំសំខាន់ៗដល់បណ្តារដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ស្តីពីការគ្រប់គ្រងសិទ្ធិកាន់កាប់ប្រកបដោយការទទួលខុសត្រូវ និងបង្កើតក្របខណ្ឌសម្រាប់គោលនយោបាយ ច្បាប់ និងកម្មវិធី។ ពិសេសជាងនេះទៅទៀត គោលការណ៍ណែនាំនេះ បានជំរុញឱ្យមានការគោរពសិទ្ធិ អភិបាលកិច្ចល្អ និងលទ្ធផលប្រកបដោយសមធម៌ ដែលជួយធានាជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន និងជំរុញឱ្យមានការអភិវឌ្ឍតាមសហគមន៍ក្នុងរយៈពេលវែង។

ឯកសារនេះគឺជាសេចក្តីណែនាំផ្នែកបច្ចេកទេសស្តីពី ការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ ( ការយល់ព្រមជាមុន ) (FPIC)។ ឯកសារនេះ បានកំណត់វិធានការសំខាន់ៗដើម្បីឱ្យស្ថាប័នរដ្ឋាភិបាលគោរព និងការពារ FPIC និងដើម្បីឱ្យអង្គការសង្គមស៊ីវិល អ្នកប្រើប្រាស់ដី និងវិនិយោគិនឯកជននៅជុំវិញពិភពលោក អនុលោមតាមការទទួលខុសត្រូវរបស់ខ្លួនពាក់ព័ន្ធនឹងការយល់ព្រមជាមុន ដូចបានអនុម័ត ដោយគោលការណ៍ណែនាំក្នុងផ្នែក៩.៩។ សេចក្តីណែនាំនេះ ក៏បានរៀបរាប់អំពីរបៀបក្នុងការរៀបចំឱ្យមានការពិគ្រោះយោបល់ និងការចូលរួមជាមួយអ្នកមានសិទ្ធិដែលរងផលប៉ះពាល់ ដោយសារការផ្លាស់ប្តូរលើការប្រើប្រាស់ដី ស្របទៅតាមកថាខណ្ឌទី៣B.៦ នៃគោលការណ៍ណែនាំដោយស្ម័គ្រចិត្តទាំងនេះផងដែរ ( សូមមើល “ការយល់ព្រមជាមុន និងគោលការណ៍ណែនាំដោយស្ម័គ្រចិត្ត” )។

**ការយល់ព្រមជាមុន និងគោលការណ៍ណែនាំដោយស្ម័គ្រចិត្ត**

*ប្រភព ៖ អង្គការ FAO ឆ្នាំ២០១២*

គោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីសិទ្ធិកាន់កាប់ដី ជលផល និងព្រៃឈើប្រកបដោយការទទួលខុសត្រូវក្នុងបរិបទសន្តិសុខស្បៀងជាតិបានកំណត់ពីការទទួលខុសត្រូវពាក់ព័ន្ធនឹងការយល់ព្រមជាមុន ដូចខាងក្រោមនេះ៖

**៣ B.៦** ការពិគ្រោះយោបល់ និងការចូលរួម៖ ការជំរុញឱ្យមានការចូលរួម និងការស្វែងរកការគាំទ្រពីអ្នកដែលមានសិទ្ធិកាន់កាប់ស្របច្បាប់ អាចទទួលរងឥទ្ធិពលពីការសម្រេចចិត្ត មុនពេលធ្វើការសម្រេចចិត្ត និងការឆ្លើយតបទៅនឹងការចូលរួមចំណែករបស់ពួកគេ ការពិចារណាពីអតុល្យភាពអំណាចដែលកំពុងកើតមាន រវាងភាគីផ្សេងៗ និងការធានានូវការចូលរួមដែលសកម្មដោយសេរី មានប្រសិទ្ធភាពពេញលេញ និងផ្អែកតាមការជូនដំណឹងពីបុគ្គល និងក្រុមដែលពាក់ព័ន្ធក្នុងដំណើរការធ្វើសេចក្តីសម្រេច។

*៩.៩* បណ្តារដ្ឋ និងភាគីផ្សេងទៀតគួររៀបចំឱ្យមានការពិគ្រោះយោបល់ដោយសុចរិតជាមួយជនជាតិដើមភាគតិច មុនពេលផ្តួចផ្តើមគម្រោង ឬមុនពេលអនុម័ត និងអនុវត្តវិធានការផ្លូវច្បាប់ ឬរដ្ឋបាលដែលប៉ះពាល់ដល់ធនធានដែលសហគមន៍គ្រប់គ្រង។ គម្រោងទាំងនោះ គួរផ្អែកលើការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព និងពេញលេញជាមួយជនជាតិដើមភាគតិចតាមរយៈស្ថាប័នតំណាងរបស់ពួកគេ ដើម្បីទទួលបានការយល់ព្រមជាមុនពីពួកគេ តាមសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងយោងតាមជំហរជាក់លាក់ និងការយល់ដឹងរបស់បណ្តារដ្ឋនីមួយៗ។ ដំណើរការពិគ្រោះយោបល់ និងការធ្វើសេចក្តីសម្រេច គួរត្រូវបានរៀបចំឡើងដោយគ្មានការបំភិតបំភ័យនិងប្រកបដោយភាពជឿទុកចិត្ត។ គួរអនុវត្តគោលការណ៍នៃការពិគ្រោះយោបល់ និងការចូលរួម ដូចមានកំណត់ក្នុងកថាខណ្ឌ **៣ B.៦** ក្នុងករណីរបស់សហគមន៍ផ្សេងទៀត ដែលមានរៀបរាប់ក្នុងផ្នែកនេះ។

**១២.៧** ក្នុងករណីរបស់ជនជាតិដើមភាគតិច និងសហគមន៍របស់ពួកគេ បណ្តារដ្ឋគួរធានាថា រាល់វិធានការទាំងអស់ស៊ីសង្វាក់គ្នានឹងកាតព្វកិច្ចដែលមានស្រាប់ ក្រោមច្បាប់ជាតិ និងអន្តរជាតិ និងយោងតាមការសន្យាដោយស្ម័គ្រចិត្តក្រោមលិខិតុបករណ៍តំបន់ និងអន្តរជាតិជាធរមាន ដូចជាអនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារ (លេខ ១៦៩) ស្តីពីជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធក្នុងប្រទេសឯករាជ្យ និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច។ បណ្តារដ្ឋ និងភាគីផ្សេងទៀត គួរធ្វើការពិគ្រោះយោបល់ដោយសុចរិតជាមួយជនជាតិដើមភាគតិច មុនពេលផ្តួចផ្តើមគម្រោងវិនិយោគណាមួយ ដែលបង្កផលប៉ះពាល់ដល់ធនធាន ដែលសហគមន៍មានសិទ្ធិកាន់កាប់។ គម្រោងទាំងនោះគួរផ្អែកលើការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាព និងពេញលេញជាមួយសមាជិកជនជាតិដើមភាគតិច ដូចមានរៀបរាប់ក្នុងកថាខណ្ឌ *៩.៩*។ គួរអនុវត្តគោលការណ៍នៃការពិគ្រោះយោបល់ និងការចូលរួមរបស់គោលការណ៍ណែនាំទាំងនេះសម្រាប់ការវិនិយោគ ដែលប្រើប្រាស់ធនធានរបស់សហគមន៍ដទៃ។

## តើអ្វីទៅជាការយល់ព្រមដោយពេញចិត្ត ដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន)?

ការយល់ព្រមជាមុន (FPIC) បានលេចឡើងជាស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដែលកើតចេញពីសិទ្ធិសមូហភាព របស់ជនជាតិដើមភាគតិច ក្នុងការទទួលបានស្វ័យសម្រេច និងការកាន់កាប់ដីធ្លី ដែនដី និងទ្រព្យសម្បត្តិផ្សេងទៀតរបស់ពួកគេ។ គោលបំណងនៃសេចក្តីណែនាំនេះ គួរត្រូវបានចាត់ទុកជាសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិចក្នុងការធ្វើសេចក្តីសម្រេចតាមរយៈតំណាងដែលត្រូវបានជ្រើសរើស

ដោយសេរី និងប្រពៃណីរបស់ពួកគេ ឬស្ថាប័នផ្សេងទៀត និងដើម្បីផ្តល់ និងលុបចោលការព្រមព្រៀងរបស់ពួកគេមុនពេលមានការអនុម័តពីរដ្ឋាភិបាល ឧស្សាហកម្មឬភាគីផ្សេងទៀតរបស់គម្រោងណាមួយដែលអាចបង្កផលប៉ះពាល់ដល់ដី ដែនដី និងធនធានដែលពួកគេកាន់កាប់គ្រប់គ្រង ឬប្រើប្រាស់ជាប្រពៃណី។

ដូច្នេះនេះ មិនមែនជាសិទ្ធិដោយឡែកមួយនោះឡើយ ប៉ុន្តែជាការបង្ហាញពីកម្រងនៃការការពារសិទ្ធិមនុស្ស ដ៏ទូលំទូលាយមួយ ដែលធានានូវសិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការគ្រប់គ្រងជីវិត របរចិញ្ចឹមជីវិត ដីធ្លី ព្រមទាំងសិទ្ធិ និងសេរីភាពផ្សេងទៀត។ ការយល់ព្រមជាមុន ត្រូវបានចាត់ទុកជាស្តង់ដារដែលបន្ថែម និងជាមធ្យោបាយក្នុងការជះឥទ្ធិពលលើសិទ្ធិសំខាន់ៗទាំងនេះ[១]។ ដូច្នេះចាំបាច់ត្រូវមានការគោរពសិទ្ធិផ្សេងទៀតដូចជា សិទ្ធិពាក់ព័ន្ធនឹងស្វ័យគ្រប់គ្រង ការចូលរួម ការធ្វើជាតំណាង វប្បធម៌ អត្តសញ្ញាណ ទ្រព្យសម្បត្តិ និងជាពិសេស ដីធ្លី និងដែនដី។ គេមិនត្រឹមតែត្រូវគោរពការយល់ព្រមជាមុនប៉ុណ្ណោះទេ ប៉ុន្តែមិនត្រូវមានវិធានការណាមួយដែលរារាំងជនជាតិដើមភាគតិចក្នុងការប្រើប្រាស់សិទ្ធិមនុស្សឡើយ ទោះបីជាក្នុងករណីដែលមានការទទួលបានការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្តក៏ដោយ។

*សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច* (UNDRIP) បានបញ្ជាក់យ៉ាងច្បាស់ថា បណ្តារដ្ឋមានភារកិច្ច ក្នុងការទទួលបានការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត របស់ជនជាតិដើមភាគតិច សម្រាប់វិធានការដែលអាចតម្រូវឱ្យមានការបណ្តេញជនជាតិដើមភាគតិច (មាត្រា ១០) ឬការរក្សាទុកសារធាតុគ្រោះថ្នាក់ លើដីធ្លី របស់ជនជាតិដើមភាគតិច (មាត្រា ២៩(២)។ ក្រៅពីនេះ តាមរយៈការប្រកាន់ខ្ជាប់គោល ការណ៍ស្វ័យសម្រេច និងបទបញ្ញត្តិនៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចជារួម បណ្តារដ្ឋគួរទទួលបានការព្រមព្រៀងលើសារសំខាន់ជាមូលដ្ឋាននៃសិទ្ធិទាំងនោះ ការរស់រានមានជីវិត សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់ជនជាតិដើមភាគតិច។ គួរមានការអនុវត្តការយល់ព្រមដោយពេញចិត្តនិងប្រាប់ឱ្យដឹងជាមុននិងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន )រួមជាមួយនឹងសេចក្តី

1 របាយការណ៍របស់តំណាងរាយការណ៍ពិសេសស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច James Anaya។ A/HRC/២១/៤៧ (ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១២) ក្នុងកថាខណ្ឌ៥១។ ដូចគ្នានេះដែរ គណៈកម្មការអន្តរអាមេរិកស្តីពីសិទ្ធិមនុស្សបានពន្យល់ថា “លក្ខខណ្ឌតម្រូវនៃការព្រមព្រៀងត្រូវតែប្រែក្លាយទៅជាការធានាចាំបាច់នូវសិទ្ធិរបស់ជនជាតិដើមភាគតិច ដោយពិចារណាពីទំនាក់ទំនងដោយផ្ទាល់នៃការព្រមព្រៀងនោះទៅនឹងសិទ្ធិរស់រានមានជីវិត អត្តសញ្ញាណវប្បធម៌ និងសិទ្ធិមនុស្សសំខាន់ៗផ្សេងទៀត ពាក់ព័ន្ធនឹងការអនុវត្តផែនការអភិវឌ្ឍ ឬវិនិយោគ ដែលជះឥទ្ធិពលលើការព្រមព្រៀងមូលដ្ឋាននៃសិទ្ធិដែលបានលើកឡើង។ ដូច្នេះភារកិច្ចក្នុងការទទួលបានការព្រមព្រៀង ឆ្លើយតបនឹងការកំណត់រកមូលហេតុនៃទំនាក់ទំនង ពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់ជនជាតិដើមភាគតិច និងសិទ្ធិពាក់ព័ន្ធផ្សេងទៀត”។ សិទ្ធិរបស់ជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធក្នុងការកាន់កាប់ដីធ្លី និងធនធានធម្មជាតិពីដូនតា OEA/Ser.L/V/II.Doc. ៥៦/០៩ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ៣៣៣។

សម្រេចទាំងអស់ដែលអាចជះឥទ្ធិពលលើសិទ្ធិរបស់ពួកគេ ហើយភារកិច្ចនេះ ផ្សារភ្ជាប់ទៅនឹងភារកិច្ចរបស់រដ្ឋ ក្នុងការគោរពសិទ្ធិរបស់ជនជាតិដើមភាគតិច ដូចជា សិទ្ធិទទួលបានការធ្វើជាតំណាងតាមរយៈស្ថាប័នរបស់ពួកគេ សិទ្ធិអនុវត្តច្បាប់ជាប្រពៃណី សិទ្ធិកាន់កាប់ដី ដែនដី និងធនធានធម្មជាតិ ដែលពួកគេជាម្ចាស់កម្មសិទ្ធិគ្រប់គ្រង ឬប្រើប្រាស់ជាប្រពៃណី សិទ្ធិក្នុងការកំណត់អត្តសញ្ញាណដោយខ្លួនឯង សិទ្ធិក្នុងការបង្ហាញពីវប្បធម៌របស់ខ្លួននិងជាពិសេសសិទ្ធិស្វ័យសម្រេច។

ការយល់ព្រមជាមុនក៏បានផ្សារភ្ជាប់និងរួមបញ្ចូលសិទ្ធិក្នុងការចូលរួមព្រមទាំងសិទ្ធិផ្សេងទៀតដែលមានក្នុងឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដូចខាងក្រោម៖

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ **(ICCPR)**
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌ **(ICESCR)**
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងជាតិសាសន៍ **(ICERD)**
- អនុសញ្ញាពាក់ព័ន្ធនឹងជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធក្នុងប្រទេសឯករាជ្យ (អនុសញ្ញាលេខ ១៦៩ របស់អង្គការ **ILO)**
- អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស
- ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស **(ACHPR)**
- អនុសញ្ញាស្តីពីជីវចម្រុះ **(CBD)**

ទាំង ICCPR និង ICESCR សុទ្ធតែការពារសិទ្ធិស្វ័យសម្រេចរបស់មនុស្ស។ ខណៈដែលលិខិតុបករណ៍ចងកាតព្វកិច្ចជាសកលទាំងនេះ មិនបានបញ្ជាក់ច្បាស់ពីគោលការណ៍នៃការយល់ព្រមជាមុន គណៈកម្មាធិការសិទ្ធិមនុស្សដែលពិនិត្យតាមដានការអនុលោមតាម ICCPR និងគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ចសង្គមនិងវប្បធម៌ដែលពិនិត្យតាមដានការអនុលោមតាម ICESCRតែងតែប្រែក្លាយកតិកាសញ្ញាទាំងនេះ ទៅជាការព្រមព្រៀងជាមុនជាចាំ

**សមាសធាតុនៃការយល់ព្រមជាមុន**

*ប្រភព* ៖ UNPFII ឆ្នាំ២០០៥
EMRIP ឆ្នាំ២០១១

**ការយល់ព្រមដោយពេញចិត្ត៖** មិនមានការបង្ខិតបង្ខំការគំរាមកំហែង ឬការគ្រប់គ្រង

**ប្រាប់ឱ្យដឹងជាមុន៖** មានការស្វែងរកកិច្ចព្រមព្រៀងពេញលេញ មុនពេលធ្វើ ឬអនុវត្តសកម្មភាព និងមានការគោរព ពេលវេលាចាំបាច់ សម្រាប់ដំណើរការពិគ្រោះយោបល់ និងការព្រមព្រៀងរបស់ជនជាតិដើមភាគតិច។

**ទទួលបានព័ត៌មានពេញលេញ៖** បង្ហាញថា មានការផ្តល់រាល់ព័ត៌មានទាក់ទងនឹងសកម្មភាពនេះ ដល់ជនជាតិដើមភាគតិច ហើយព័ត៌មាននោះ មានលក្ខណៈសត្យានុម័តត្រឹមត្រូវ និងត្រូវបានបង្ហាញក្នុងរបៀប ឬទម្រង់ដែលជនជាតិដើមភាគតិចអាចយល់បាន។ព័ត៌មានពាក់ព័ន្ធមានដូចជា៖

១. លក្ខណៈ ទំហំ ជំហាន អំឡុងពេល ភាពអាចស្តារឡើងវិញបាន និងវិសាលភាពនៃគម្រោងដែលស្នើឡើង
២. មូលហេតុ ឬគោលបំណងរបស់គម្រោង
៣. ទីតាំងតំបន់ដែលនឹងរងផលប៉ះពាល់
៤. ការវាយតម្លៃបឋមលើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ដែលអាចកើតមាន រួមទាំង ហានិភ័យ និងអត្ថប្រយោជន៍។
៥. បុគ្គលិកដែលត្រូវចូលរួមក្នុងការអនុវត្តគម្រោង
៦. នីតិវិធីដែលអាចពាក់ព័ន្ធនឹងគម្រោង។

**ការយល់ព្រមជាមុន៖** បង្ហាញថា ជនជាតិដើមភាគតិច បានយល់ស្របនឹងសកម្មភាពដែលនឹងត្រូវធ្វើ បន្ទាប់ពីមានការពិគ្រោះយោបល់។ ជនជាតិដើមភាគតិច ក៏មានសិទ្ធិលុបចោលកិច្ចព្រមព្រៀង ឬផ្តល់ការព្រមព្រៀងដោយមានលក្ខខណ្ឌផងដែរ។ ការពិគ្រោះយោបល់ និងការចូលរួមគឺជាសមាសធាតុសំខាន់នៃដំណើរការស្វែងរកការព្រមព្រៀង។ ការពិគ្រោះយោបល់ ត្រូវតែធ្វើឡើងដោយសុចរិត ដែលតម្រូវឱ្យមានការកែសម្រួលទៅតាមទស្សនៈរបស់ជនជាតិដើមភាគតិច ក្នុងដំណើរការនេះ ឬមានការផ្តល់យុត្តិធម៌ដើម្បីបញ្ជាក់ពីមូលហេតុដែលគេមិនអាចធ្វើការកែសម្រួលនេះបាន។ ភាគីទាំងអស់ ត្រូវបង្កើតកិច្ចពិភាក្សាដែលអាចឱ្យពួកគេកំណត់រកដំណោះស្រាយសមស្រប និងអាចអនុវត្តទៅបាន ក្នុងបរិយាកាសដែលមានការគោរពគ្នាទៅវិញទៅមកនិងមានការចូលរួមពេញលេញនិងប្រកបដោយសមធម៌ ដោយផ្តល់ពេលវេលាយូរគ្រប់គ្រាន់ក្នុងការសម្រេចចិត្ត។ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ត្រូវមានលទ្ធភាពចូលរួមតាមរយៈតំណាងដែលត្រូវបានជ្រើសរើសដោយសេរីប្រពៃណីនិងស្ថាប័នផ្សេងទៀតរបស់ពួកគេ។គួរជំរុញឱ្យមានការចូលរួមពីស្ត្រី យុវជន និងកុមារទៅតាមស្ថានភាពជាក់ស្តែង។

បាច់សម្រាប់ជាការបង្ហាញពីស្វ័យសម្រេច[២]។ គណៈកម្មាធិការលុប បំបាត់ការរើសអើងជាតិសាសន៍ដែលពិនិត្យតាមដានការអនុលោមតាម ICERD ក៏បានបង្ហាញអំពីសិទ្ធិ របស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ដី និងបានអំពាវនាវម្តងហើយ ម្តងទៀតឱ្យបណ្តារដ្ឋនានាទទួលស្គាល់ និងការពារសិទ្ធិទាំងនេះ និងអនុវត្ត ការយល់ព្រមជាមុន[៣]។ អនុសញ្ញាលេខ ១៦៩ របស់អង្គការអន្តរជាតិខាងការងារបានហាមឃាត់ការបណ្តេញ និង/ឬការផ្លាស់ទីលំនៅជនជាតិដើមភាគតិច និងប្រជាជនកុលសម្ព័ន្ធចេញពីដែនដីរបស់ពួកគេដោយមិនមានការយល់ព្រមជាមុន ពីពួកគេនោះឡើយ។ ស្តង់ដារនៃ “ការអនុម័ត និងការចូលរួម”ក្នុងអនុសញ្ញាស្តីពីជីវចម្រុះ (CBD) ក៏មានលក្ខណៈដូចគ្នាទៅនឹងមិនបានទទួលការយល់ព្រមជាមុនផងដែរ និងត្រូវបានបញ្ជាក់អះអាងក្នុងអនុសញ្ញាស្តីពីជីវចម្រុះរបស់Akwe៖ គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត Kon។

ជាងនេះទៅទៀត លិខិតុបករណ៍ទាំងនេះ បានតម្រូវឱ្យមានការគោរពប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច រួមទាំងស្ថាប័ន និងគំរូនៃការធ្វើជាតំណាងរបស់ជនជាតិដើមភាគតិចដែលពាក់ព័ន្ធនឹងដំណើរការធ្វើសេចក្តីសម្រេច ដូចជា ការយល់ព្រមជាមុន ជាដើម។ ដូច្នេះ របៀបជាក់លាក់ដែលមានដំណើរការធ្វើ សេចក្តីសម្រេចពាក់ព័ន្ធនឹង ការយល់ព្រមជាមុន ពិតជាងាយនឹងផ្លាស់ប្តូរទៅតាមប្រពៃណី និងទំនៀមទម្លាប់របស់ប្រជាជន ឬសហគមន៍ដែលរងផលប៉ះពាល់។

---

2 សូមមើល ក្នុងចំណោម Angela Poma Poma និង Peru CCPR/C/៩៥/D/១៤៥៧/២០០៦ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩។ ការអង្កេតបូកសរុបរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ប្រទេសតូហ្គោ ៖ CCPR/C/TGO/CO/៤ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ កថាខណ្ឌ២១។ ការអង្កេតបូកសរុបរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ប្រទេសកូឡុំប៊ី ៖ CCPR/C/COL/CO/៦ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ កថាខណ្ឌ២៥។ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មតិរួមលេខ២១ សិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការចូលរួមក្នុងជីវភាពវប្បធម៌ (មាត្រា ១៥ កថាខណ្ឌ១ (ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌) ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំលើកទី៤៣ របស់គណៈកម្មាធិការ ថ្ងៃទី០២-២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសាររបស់អង្គការសហប្រជាជាតិ E/C. ១២/GC/២១ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ៣៦-៣៧។

3 សូមមើលអនុសាសន៍រួមទី២៣ ស្តីពីជនជាតិដើមភាគតិច ដែលត្រូវបានអនុម័តដោយគណៈកម្មាធិកាលុបបំបាត់ការរើសអើងជាតិសាសន៍ក្នុងកិច្ចប្រជុំលើកទី៥១ របស់ខ្លួន ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៧ កថាខណ្ឌ៤ (ឃ)។ ប្រទេសអូស្ត្រាលី ៖ CERD/C/AUS/១៤ ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០៥ កថាខណ្ឌ១១។ ប្រទេសហ្គូយយ៉ាណា ៖ CERD/C/GUY/CO/១៤ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៦ កថាខណ្ឌ ១៩។ ប្រទេសកម្ពុជា ៖ CERD/C/៣០៤/Add. ៥៤ ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ កថាខណ្ឌ១៣, ១៩។ ប្រទេសហ្គាតេម៉ាឡា ៖ CERD/C/GTM/CO/១១ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៦ កថាខណ្ឌ១៩។ ប្រទេសសូរីណាម ៖ សេចក្តីសម្រេចលេខ១ (៦៧) CERD/C/DEC/SUR/៤ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥ កថាខណ្ឌ៣។

## ភារកិច្ច និងការទទួលខុសត្រូវ

ក្នុងនាមជាសមាជិករបស់អង្គការសហប្រជាជាតិ និងសន្ធិសញ្ញាក្នុងតំបន់ផ្សេងទៀត និងអនុលោមតាមលិខិតុបករណ៍សិទ្ធិមនុស្សដែលពួកគេខិតខំប្រឹងប្រែងអនុវត្តតាមវាជាភារកិច្ចរបស់រដ្ឋាភិបាលក្នុងការធានាថាមានការគោរពការពារ និងបំពេញបាននូវសិទ្ធិមនុស្សរបស់ជនជាតិដើមភាគតិច។ ដូចគ្នានេះដែររដ្ឋាភិបាលមានភារកិច្ចធានាថា តួអង្គផ្សេងទៀត ជាពិសេស វិស័យឯកជនគោរពសិទ្ធិទាំងនេះ ដោយការពារសិទ្ធិទាំងនេះ យ៉ាងសកម្ម ទៅតាមករណីជាក់ស្តែង។ ដូច្នេះ រដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការពិនិត្យឡើងវិញ និងកែសម្រួលច្បាប់ជាតិក្នុងករណីចាំបាច់ និងបង្កើត ឬរក្សាដំណោះស្រាយប្រកបដោយការវិនិច្ឆ័យ និងមានប្រសិទ្ធភាពដែលធ្វើឱ្យមានការពង្រឹងសិទ្ធិទាំងនេះដើម្បីឱ្យច្បាប់ផ្តល់សុពលភាពដល់សិទ្ធិទាំងនេះ និងធានាថា ក្រុមហ៊ុនក៏គោរពសិទ្ធិទាំងនេះផងដែរ។ ការណែនាំនេះ មានគោលបំណងជំរុញឱ្យរដ្ឋាភិបាលធានាថាច្បាប់ជាតិទទួលស្គាល់សិទ្ធិជាប្រពៃណីរបស់សហគមន៍ និងជនជាតិដើមភាគតិចក្នុងការកាន់កាប់ដី និងដែនដីរបស់ខ្លួន ផ្តល់នីតិបុគ្គលសម្រាប់ស្ថាប័នតំណាងដែលពួកគេបានជ្រើសរើសដោយខ្លួនឯងផ្តល់ដំណោះស្រាយប្រកបដោយការវិនិច្ឆ័យ និងមានប្រសិទ្ធភាពផ្សេងទៀតដើម្បីពង្រឹងសិទ្ធិទាំងនោះ និងសិទ្ធិផ្សេងទៀត និងតម្រូវឱ្យស្ថាប័នរដ្ឋាភិបាល និងក្រុមហ៊ុនទទួលបានការយល់ព្រមជាមុនពីពួកគេមុនពេលចាត់វិធានការនានា ដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។

ក្នុងវិស័យឯកជន គេបានមើលឃើញកំណើននៃគំនិតផ្តួចផ្តើមស្តីពីការបង្កើតស្តង់ដារដោយស្ម័គ្រចិត្តក្នុង រយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះដែលទទួលស្គាល់សារសំខាន់ នៃការការពារសិទ្ធិជាប្រពៃណីក្នុងការកាន់កាប់ដីធ្លី និងធនធានធម្មជាតិផ្សេងទៀត។ ទន្ទឹមនឹងនេះ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីអាជីវកម្ម និងសិទ្ធិមនុស្សបានគូសបញ្ជាក់ថា ខណៈដែលរដ្ឋាភិបាលមានកាតព្វកិច្ចសំខាន់ក្នុងការរក្សាសិទ្ធិមនុស្ស អាជីវកម្មក៏ត្រូវទទួលខុសត្រូវលើការគោរពសិទ្ធិមនុស្សផងដែរ ហើយការទទួលខុសត្រូវនេះមានរួចជាស្រេច ដោយមិនអាស្រ័យលើសមត្ថភាព និង/ឬឆន្ទៈរបស់រដ្ឋក្នុងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនឡើយ។ ស្តង់ដារដោយស្ម័គ្រចិត្តជាច្រើនក្នុងវិស័យឯកជនតម្រូវឱ្យក្រុមហ៊ុនទទួលបានការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្តរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានមុនពេលស្នើឱ្យមានការអភិវឌ្ឍ សម្រាប់ជាការអនុវត្តល្អដោយផ្អែកលើការទទួលស្គាល់ថាក្រុមហ៊ុនមានកាតព្វកិច្ចប្រកបដោយសីលធម៌ ដែលល្អប្រសើរជាងលក្ខខណ្ឌតម្រូវអប្បបរមារបស់ច្បាប់ជាតិ [៤]។

### ច្បាប់ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច (IPRA) ក្នុងប្រទេសហ្វីលីពីន

ប្រទេសជាច្រើនបានតាក់តែងច្បាប់ជាតិដើម្បីធានាដំណើរការប្រកបដោយយុត្តិធម៌នៃការផ្ទេរកម្មសិទ្ធិដីធ្លីដោយអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងការទទួលបានការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត ប៉ុន្តែមានតែប៉ុន្មានប្រទេសប៉ុណ្ណោះដែលអនុម័តច្បាប់ជាតិដែលបញ្ជាក់យ៉ាងច្បាស់អំពីកាតព្វកិច្ចពាក់ព័ន្ធនឹងការទទួលបានយល់ព្រមជាមុន។ ករណីលើកលែងពិសេសមួយគឺប្រទេសហ្វីលីពីន ដែលច្បាប់ស្តីសិទ្ធិរបស់ជនជាតិ ដើមភាគតិចបានតម្រូវឱ្យមានការយល់ព្រមជាមុនសម្រាប់រាល់សកម្មភាពដែលអាចប៉ះពាល់ដល់សិទ្ធិកាន់កាប់ដីធ្លី និងធនធានរបស់ជនជាតិដើមភាគតិច។ នីតិវិធីសម្រាប់អនុវត្តតាមភារកិច្ចនេះ ស្ថិតក្រោមការឃ្លាំមើលរបស់គណៈកម្មការជាតិហ្វីលីពីនទទួលបន្ទុកជនជាតិដើមភាគតិចដែលបានផ្សព្វផ្សាយ និងពិនិត្យឡើងវិញលើឯកសារបទប្បញ្ញត្តិជាច្រើនដែលកំណត់ពីដំណើរការចាំបាច់សម្រាប់ការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន)។ មេរៀនសំខាន់ៗដែលទទួលបានពីបទពិសោធន៍នេះគឺថា នីតិវិធីសម្រាប់ការគោរពការយល់ព្រមជាមុនត្រូវផ្តល់វិសាលភាពពេញលេញដល់ជនជាតិដើមភាគតិចក្នុងការប្រើប្រាស់ច្បាប់ជាប្រពៃណីរបស់ខ្លួន និងធ្វើជាតំណាងខ្លួនឯង ទៅតាមការជ្រើសរើសដោយសេរីរបស់ពួកគេ ហើយសេចក្តីសម្រេចរបស់រដ្ឋាភិបាលត្រូវតែមានតម្លាភាព និងគណនេយ្យភាព។

---

4 ឧទាហរណ៍នានារួមមាន គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់ទឹក (WCD) ការពិនិត្យឡើងវិញលើឧស្សាហកម្មទាញយកផល (EIR) ក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ (FSC) កិច្ចពិភាក្សាតុមូលស្តីពីប្រេងដូងប្រកបដោយនិរន្តរភាព (RSPO) កិច្ចពិភាក្សាតុមូលស្តីពីសមាគមផលិតសណ្តែកសៀងដែលមានការទទួលខុសត្រូវ (RTRS) និងកិច្ចពិភាក្សាតុមូលស្តីពីជីវសារជាតុ (RSB)។

ក្រៅពីនេះ គោលនយោបាយប្រតិបត្តិរបស់បណ្ដាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិជាច្រើន បានអំពាវនាវឱ្យមានការទទួលបានការយល់ព្រមជាមុន របស់ជនជាតិដើមភាគតិចសម្រាប់គម្រោងហិរញ្ញវត្ថុដែលអាចជះឥទ្ធិពលលើដី និងធនធានរបស់ពួកគេ[5]។ ការយល់ព្រមជាមុនក៏ជា "គោលការណ៍និង សិទ្ធិ" ជាមូលដ្ឋានរបស់ជនជាតិដើមភាគតិចផងដែរ ក្រោម*គោលនយោបាយស្ដីពីជនជាតិដើមភាគតិច និងជនកុលសម្ព័ន្ធ*របស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (អង្គការ FAO ឆ្នាំ២០១០) ដែលណែនាំអំពីទំនាក់ទំនងរបស់អង្គការជាមួយ និងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនជាតិដើមភាគតិចក្នុងសកម្មភាពអភិវឌ្ឍន៍ ដែលអាចប៉ះពាល់ដល់ពួកគេ។

ក្នុងការអនុវត្ត ការយល់ព្រមជាមុននេះ ដាក់ស្ដែងជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានក្នុងនាមជាអ្នកមានសិទ្ធិគួរកំណត់ទម្រង់ជំហាន និងអ្នកចូលរួមក្នុងដំណើរការនេះដែលមានបណ្ដារដ្ឋ និងតួអង្គផ្សេងទៀតគោរព ការយល់ព្រមជាមុននេះ។ ដើម្បីបំពេញបានតាមស្តង់ដារការយល់ព្រមជាមុន ត្រូវមានកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងយល់ពីប្រពៃណីមួយចំនួន ឬដំណើរការធ្វើសេចក្ដីសម្រេចដែលបានកំណត់ដោយការស្ម័គ្រចិត្តផ្សេងទៀតដែលប្រើប្រាស់ដោយប្រជាជន ឬសហគមន៍ដែលរងផលប៉ះពាល់។




5 ស្ថាប័នទាំងនោះរួមមាន សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធនាគារអឺរ៉ុបសម្រាប់ការស្តារឡើងវិញ និងការអភិវឌ្ឍ (EBRD) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារអភិវឌ្ឍន៍អន្តរអាមេរិក (IADB) និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)។ ក្នុងខែមករា ឆ្នាំ២០១២ ធនាគារពាណិជ្ជឈានមុខគេជាច្រើនក្នុងពិភពលោក ដែលប្រកាន់ខ្ជាប់គោលការណ៍អេក្វាទ័រ បានយល់ព្រមអនុវត្តស្តង់ដារប្រសិទ្ធភាពការងារដែលបានធ្វើបច្ចុប្បន្នភាពរបស់ IFC សម្រាប់ការអនុវត្តគម្រោងរបស់ខ្លួន ដែលអនុម័តឱ្យមានសិទ្ធិទទួលបានការព្រមព្រៀងដោយសេរី និងដោយជូនដំណឹងជាមុន។ ធនាគារពិភពលោកបានចាប់ផ្តើមដំណើរការរយៈពេលពីរឆ្នាំនៃការធ្វើបច្ចុប្បន្នភាព និងបញ្ចូលគោលនយោបាយការពារបរិស្ថាន និងសង្គមរបស់ខ្លួន ដើម្បីផ្តល់ការយកចិត្តទុកដាក់បន្ថែមទៀតលើការគោរពសិទ្ធិទទួលបានការព្រមព្រៀងដោយសេរី និងដោយជូនដំណឹងជាមុន។

## តើគេគួរទទួលបានការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុននិងទទួលបានព័ត៌មានពេញលេញ(ការយល់ព្រមជាមុន)ពីនរណា?

ការយល់ព្រមជាមុន (FPIC) បានចែងយ៉ាងច្បាស់លាស់ពីសិទ្ធិរបស់ជនជាតិដើមភាគតិច។ បច្ចុប្បន្ន ច្បាប់អន្តរជាតិមិនសូវកំណត់ច្បាស់លាស់ពីសិទ្ធិកាន់កាប់ដីធ្លី និងធនធានរបស់បុគ្គល ឬក្រុមផ្សេងទៀត ដែលអាចនឹងមិនទទួលស្គាល់ខ្លួនឯងថាជា "ប្រជាជនកុលសម្ព័ន្ធ" ឬ "ជនជាតិដើមភាគតិច" ប៉ុន្តែ គឺជាអ្នកដែលមានលទ្ធភាពទទួលបានដីធ្លី និងធនធាន តាមរយៈច្បាប់ជាប្រពៃណី កេរ្តិ៍មរតកពីដូនតា ឬដំណើរការផ្លូវការផ្សេងទៀតនោះឡើយ។ គោលការណ៍ណែនាំ ទាមទារឱ្យមានការពិគ្រោះយោបល់ និងការចូលរួមដ៏សកម្ម ដោយសេរី មានប្រសិទ្ធភាពពេញលេញ និងផ្អែកតាមព័ត៌មានត្រឹមត្រូវជាមួយ ប្រជាជន ដែលរងផលប៉ះពាល់ដូចជា ជនជាតិដើមភាគតិច និងសហគមន៍ផ្សេងទៀតដែលមានសិទ្ធិ កាន់កាប់ជាប្រពៃណី ដូចមានចែងក្នុងកថាខណ្ឌ **៣ B.៦** ព្រមទាំងតម្រូវឱ្យមានការគោរពការយល់ព្រម ជាមុន្ត ក្នុងការដោះស្រាយបញ្ហាជាមួយជនជាតិដើមភាគតិច។

មិនមានការកំណត់ជាក់លាក់ និងទទួលស្គាល់ជាអន្តរជាតិអំពីនិយមន័យនៃជនជាតិដើមភាគតិច នោះទេ ប៉ុន្តែច្បាប់អន្តរជាតិបានគូសបញ្ជាក់យ៉ាងច្បាស់ថា ទស្សនទាននេះ គ្របដណ្តប់ទៅលើប្រជាជន ដែលត្រូវបានសំដៅជាទូទៅថាជា "ប្រជាជនកុលសម្ព័ន្ធ" ហើយទីភ្នាក់ងារអន្តរជាតិបានប្រើប្រាស់ពាក្យនេះ យ៉ាងទូលំទូលាយចំពោះក្រុមជាតិពន្ធុផ្សេងៗគ្នាដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងដីកេរ្តិ៍មរតក ដូនតា។ លក្ខណៈទូទៅមួយចំនួន ដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់ បុគ្គលទាំងនោះមានដូចជា៖

- ការកំណត់អត្តសញ្ញាណដោយខ្លួនឯង ក្នុងនាមជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើមភាគតិចដោយឡែកមួយ និងការទទួលស្គាល់អត្តសញ្ញាណនេះដោយអ្នកដទៃ។
- ការផ្សារភ្ជាប់ជារួមទៅនឹងទីជម្រកក្នុងតំបន់ភូមិសាស្ត្រដាច់ដោយឡែក ឬដែនដីដូនតាក្នុងតំបន់គម្រោង និងធនធានធម្មជាតិក្នុងទីជម្រក និងដែនដីទាំងនេះ។
- ស្ថាប័ននយោបាយ ឬសង្គម សេដ្ឋកិច្ច វប្បធម៌ជាប្រពៃណីដែលផ្តាច់ចេញពីសង្គម និងវប្បធម៌ទូទៅ។
- ភាសាជនជាតិដើមភាគតិច ដែលតែងតែខុសប្លែកពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់ (ធនាគារពិភពលោកឆ្នាំ២០០៥)។

តាមរយៈការយល់ដឹងថា ជាការបង្ហាញពីសិទ្ធិស្វ័យសម្រេច គេអាចបញ្ជាក់ការយល់ព្រមជាមុន ដោយអនុវត្តចំពោះប្រជាជនដែលកំណត់អត្តសញ្ញាណដោយខ្លួនឯងទាំងអស់ ដែលរក្សាទំនាក់ទំនងជាប្រពៃណី ជាមួយដីធ្លី និងធនធានធម្មជាតិរបស់ខ្លួនដោយបង្ហាញថា ពួកគេទទួលបានការយល់ព្រមជាមុនយ៉ាង ទូលំទូលាយក្នុងតំបន់ជនបទនៃទ្វីបអាហ្វ្រិក និងអាស៊ី និងដោយសង្គមជនបទជាច្រើនរបស់ជនជាតិ អាមេរិកស្បែកខ្មៅ។

រដ្ឋាភិបាល និងក្រុមហ៊ុនក៏ត្រូវពិចារណាផងដែរថា ក្នុងករណីដែលមានការកំណត់ថា សហគមន៍ជនបទ មិនមានលក្ខណៈជាជនជាតិដើមភាគតិចក្នុងន័យដ៏ទូលំទូលាយនេះ គម្រោងអភិវឌ្ឍន៍លើដីរបស់ប្រជាជន ទាំងនោះ មិនត្រូវធ្វើឱ្យពួកគេបាត់បង់សិទ្ធិរបស់ខ្លួនឡើយ។ សិទ្ធិទាំងនេះរួមមាន សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានទ្រព្យសម្បត្តិ និងបទដ្ឋានជីវភាពរស់នៅសមរម្យដូចជា ចំណីអាហារ ទឹកប្រើប្រាស់ និង ទីជម្រក ។ រាល់លទ្ធកម្មដីធ្លី គួរធ្វើឡើងដោយអនុលោមតាមនីតិវិធីផ្លូវច្បាប់ ដែលធានាសិទ្ធិមនុស្ស បន្ទាប់

ពីមានដំណើរការពិគ្រោះយោបល់ និងការចូលរួមដែលមានគោលបំណងជានានូវការគាំទ្រសិទ្ធទាំងនោះ។ គម្រោងផ្តល់លិខិតបញ្ជាក់ដោយស្ម័គ្រចិត្តមួយចំនួន នឹងមិនផ្តល់លិខិតបញ្ជាក់ដល់គម្រោងអភិវឌ្ឍន៍លើដីសហគមន៍ដែលត្រូវបានបែងចែកដល់ភាគីទីបីតាមរយៈការប្រើប្រាស់អំណាចរបស់រដ្ឋដើម្បីរឹបអូសយកដីឡើយ។

## អត្ថប្រយោជន៍នៃការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ(ការយល់ព្រមជាមុន )

នៅទីបំផុត ការគោរពការយល់ព្រមជាមុន ផ្តល់អត្ថប្រយោជន៍ដល់រដ្ឋ និងក្រុមហ៊ុនក្នុងរយៈពេលវែងតាមរយៈការកាត់បន្ថយជាអប្បបរមានូវហានិភ័យនៃការបង្កើតជាទំនាស់ដែលរីករាលដាលទៅជាជម្លោះ។ ការណ៍នេះជួយបង្ការមិនឱ្យមានការបាត់បង់ឱកាសវិនិយោគដែលអាចបាត់បង់ទៅវិញប្រសិនបើវិនិយោគិន សម្រេចផ្តោតលើប្រទេសផ្សេងទៀត ដែលពួកគេយល់ថាមានការធានាសុវត្ថិភាពដល់ការវិនិយោគរបស់ខ្លួន។ការយល់ព្រមជាមុននឹងផ្តល់អត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់ដោយការពាររបបចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន ពង្រឹងលទ្ធភាពជាក់ស្តែងលទ្ធភាពហិរញ្ញវត្ថុ និងនិរន្តរភាព ដំណើរការអាជីវកម្ម ព្រមទាំងបង្កើនសក្តានុពល និងឱកាសវិនិយោគរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

“ភារកិច្ចរបស់រដ្ឋក្នុងការទទួលបានការយល់ព្រមជាមុនពីសំណាក់ជនជាតិដើមភាគតិច គឺផ្តល់សិទ្ធិដល់ជនជាតិដើមភាគតិចក្នុងការកំណត់ប្រកបដោយប្រសិទ្ធភាពលើលទ្ធផលនៃការធ្វើសេចក្តីសម្រេចដែលជះឥទ្ធិពលលើពួកគេពោលគឺមិនត្រឹមតែផ្តល់សិទ្ធិចូលរួមនៅក្នុងដំណើរការនោះឡើយ” [៦]។

> ការយល់ព្រមជាមុន ទាមទារឱ្យមានការធានាថា សហគមន៍អាចចូលរួមពេញលេញក្នុងដំណើរការធ្វើសេចក្តីសម្រេច និងមានការពិចារណាលើបញ្ហាកង្វល់អាទិភាព និងការចង់បានរបស់ពួកគេក្នុងការរៀបចំសូចនាករ និងលទ្ធផលគម្រោង។ ជារួមដូចមានចែងដោយយន្តការជំនាញសហប្រជាជាតិទទួលបន្ទុកសិទ្ធិរបស់ជនជាតិដើមភាគតិច៖ “ភារកិច្ចរបស់រដ្ឋក្នុងការទទួលបានការយល់ព្រមជាមុនរបស់ជនជាតិដើមភាគតិច បានផ្តល់សិទ្ធិដល់ជនជាតិដើមភាគតិច ក្នុងការកំណត់ដោយប្រសិទ្ធភាពលើលទ្ធផលនៃការធ្វើសេចក្តីសម្រេចដែលជះឥទ្ធិពលលើពួកគេ ពោលគឺ មិនត្រឹមតែផ្តល់សិទ្ធិចូលរួមក្នុងដំណើរការនោះឡើយ”។ ក្រៅពីនេះ ការយល់ព្រមជាមុន បានកំណត់ថា សហគមន៍ ត្រូវតែអាចចរចាពីលទ្ធផលដែលយុត្តិធម៌ និងអាចអនុវត្តទៅបាន និងលុបចោលការព្រមព្រៀងរបស់ខ្លួនក្នុងគម្រោងណាមួយ ប្រសិនបើមិនមានការដោះស្រាយតម្រូវការអាទិភាព និងក្តីកង្វល់របស់ពួកគេបានសមស្របទេនោះ។ ការពិគ្រោះយោបល់ និងការចរចា ដែលមិនបានដោះស្រាយមូលហេតុនៃការជំទាស់របស់សហគមន៍ ឬសម្រេចបានការព្រមព្រៀង នឹងផ្តល់ការធានាតិចតួចលើជម្លោះ ដែលអាចធ្វើឱ្យអស់ចំណាយច្រើន និងបង្កការរំខាន។

**ការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន) គឺផ្តោតលើលទ្ធផល និងដំណើរការ**

---

៦ ក្រុមប្រឹក្សាសិទ្ធិមនុស្ស យន្តការជំនាញស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច របាយការណ៍ចុងក្រោយស្តីពីការសិក្សាជនជាតិដើមភាគតិច និងសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេច។ ការណែនាំលេខ២ នៃយន្តការជំនាញ (ឆ្នាំ២០១១) ៖ ជនជាតិដើមភាគតិច និងសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេច ឯកសាររបស់អង្គការសហប្រជាជាតិ A/HRC/១៨/៤២ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ កថាខណ្ឌ ២១។





# ការណែនាំអនុវត្តន៍ជាក់ស្តែង



## ការណែនាំអនុវត្តន៍ជាក់ស្តែង

សកម្មភាពល្អៗដែលបានលើកឡើងខាងក្រោម ផ្តល់ការណែនាំសំខាន់ៗពីរបៀបគោរពការយល់ព្រមជាមុន និងមានបញ្ចូលគំនិតល្អៗសម្រាប់រដ្ឋាភិបាល ក្រុមហ៊ុន ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល។ ផ្នែកពាក់ព័ន្ធផ្សេងទៀត នៃគោលការណ៍ណែនាំដោយស្ម័គ្រចិត្តមានបញ្ជាក់នៅផ្នែកខាងក្រោមនៃទំព័រ។ ជំហានផ្សេងៗសម្រាប់តួអង្គមួយចំនួនមានបញ្ជាក់ក្នុងករណីចាំបាច់។

ជំហានដែលបានលើកឡើងទាំងនេះ មិនមែនជានីតិវិធីដែលមានតែម្តងនោះឡើយ។ ផ្ទុយទៅវិញជំហានទាំងនេះ គឺជាផ្នែកមួយនៃដំណើរការដដែលៗ និងមានជាបន្តបន្ទាប់ ដែលសកម្មភាពមួយចំនួននោះនឹងត្រូវអនុវត្តម្តងហើយម្តងទៀត ដោយចំណាយពេលយូរ ឬយកមកអនុវត្តសារជាថ្មី ក្នុងដំណើរការទូលំទូលាយជាងមុន ដែលតម្រូវឱ្យមានការពិចារណាពីតួអង្គចម្រុះ និងទិដ្ឋភាពផ្សេងៗដែលពាក់ព័ន្ធ។ រាល់ព័ត៌មាននៅក្នុងដំណាក់កាលទាំងអស់ ត្រូវមានតម្លាភាព ហើយភាគីពាក់ព័ន្ធទាំងអស់ ត្រូវទទួលបានព័ត៌មានទាំងនោះ។ លំដាប់ជាក់លាក់នៃសកម្មភាពសំខាន់ៗ គឺមិនមានលក្ខណៈឋិតថេរនោះឡើយ។ សកម្មភាពទាំងនោះ នឹងប្រែប្រួលទៅតាមបរិបទសង្គម សេដ្ឋកិច្ច ច្បាប់ និងគោលនយោបាយដែលក្នុងនោះ សិទ្ធិកាន់កាប់ដីធ្លី គឺត្រូវបានធ្វើលទ្ធកម្មសម្រាប់គម្រោងខុសៗគ្នាជាច្រើន។ បន្ទាប់ពីមានការអនុវត្តសកម្មភាពនីមួយៗ ឯកសារដែលបានចងក្រងគួរផ្សព្វផ្សាយឱ្យបានទូលំទូលាយ ហើយគួរស្វែងរកយោបល់ត្រឡប់ពីគ្រប់តួអង្គទាំងអស់ ដើម្បីធានាបានថា រាល់ជំហាននៃដំណើរការ អាចត្រូវបានបង្កើតឡើងរួមគ្នា។

### ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្ត

មុនពេលអនុវត្តដំណើរការស្វែងរកការយល់ព្រមជាមុននោះត្រូវពិចារណាកត្តាដូចខាងក្រោមនេះ៖

**ដំណើរការ៖** ដោយសារតែលក្ខខណ្ឌក្នុងការទទួលបានការយល់ព្រមជាមុនមិនមែនជាសិទ្ធិដោយឡែក មិនគួរមានការបន្ថយដំណើរការជាបន្តបន្ទាប់ដែលបញ្ចប់ត្រឹមការឱ្យសហគមន៍ចុះកិច្ចព្រមព្រៀងនោះឡើយ។ ការគោរពការយល់ព្រមជាមុនធានាថា ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន អាចបញ្ចេញមតិយោបល់នៅគ្រប់ដំណាក់កាលនៃការរៀបចំផែនការអភិវឌ្ឍ និងការអនុវត្តសម្រាប់គម្រោងដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។ ប្រការនេះរួមមាន សិទ្ធិរបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានក្នុងការកំណត់ពីប្រភេទនៃការពិគ្រោះយោបល់ និងដំណើរការធ្វើសេចក្តីសម្រេចដែលសមស្របសម្រាប់ពួកគេ។ ការទទួលបានការព្រមព្រៀងជាមុន អាចជាជំហានដំបូង នៅក្នុងដំណើរការនៃប្រតិបត្តិការគម្រោង ហើយត្រូវការជាចាំបាច់នូវការចូលរួមជាបន្តបន្ទាប់ របស់សហគមន៍ ការពិនិត្យតាមដានដែលមានការចូលរួម និងការផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ដើម្បីទទួលបានការយល់ព្រមជាមុននេះ។

**ធនធាន៖** ក្រៅពីពេលវេលាការរកបានធនធានសម្ភារនិងធនធានមនុស្សគឺមានសារសំខាន់ខ្លាំងណាស់សម្រាប់ដំណើរការដ៏រឹងមាំ និងអាចផ្ទៀងផ្ទាត់បាន តាមការគោរពការយល់ព្រមជាមុន។ ដំណើរការនេះរាប់បញ្ចូលទាំងការវិនិយោគលើធនធានមនុស្សសម្ភារទំនាក់ទំនង និងយុទ្ធសាស្ត្រសកម្មភាពកសាងសមត្ថភាព ការផ្ទៀងផ្ទាត់ដោយឯករាជ្យ និងការណែនាំផ្នែកបច្ចេកទេស និងផ្នែកច្បាប់។ អ្នកមានសិទ្ធិក៏ត្រូវការធនធានឱ្យបានគ្រប់គ្រាន់ដើម្បីកសាងសមត្ថភាពក្នុងការពិចារណាពីគម្រោង ឬកម្មវិធីដែលបានស្នើឡើង។ នៅពេលដែលអ្នកមានសិទ្ធិចាប់អារម្មណ៍ចូលរួមក្នុងការរៀបចំ និងការអនុវត្តគម្រោងនោះ ពួកគេនឹងត្រូវការធនធានបន្ថែមទៀត ដើម្បីរៀបចំការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញសមស្រប។ អ្នកគាំទ្រគម្រោងគួរដឹងថា ការគោរពការយល់ព្រមជាមុន គឺជាការចំណាយលើការអភិវឌ្ឍគម្រោងដែលមានជាប់មកជាមួយ និងចាំបាច់។ ក្នុងករណីសមស្រប អ្នកបង្កើតគម្រោង គួររិះរកមធ្យោបាយដែលមានលក្ខណៈបើកចំហ និងមានគណនេយ្យភាពដើម្បីបែងចែកមូលនិធិដល់សហគមន៍ផ្សេងៗ ក្នុងគោលបំណងរក្សាឱ្យបាននូវសុចរិតភាពដំណើរការ និងឯករាជ្យភាពនៃតួនាទីរបស់សហគមន៍។

**កត្តាដែលប៉ះពាល់ដល់ពេលវេលា និងធនធានចាំបាច់ក្នុងការគោរពការយល់ព្រមជាមុន**
*ប្រភព* ៖ Anderson ២០១១

**ពេលវេលា៖** នៅក្នុងដំណើរការទាំងមូលនៃការគោរពការយល់ព្រមជាមុនជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានត្រូវចូលរួមពិភាក្សាជាក្រុមកាន់តែយូរកាន់តែល្អដើម្បីឱ្យពួកគេយល់ដឹងពិចារណានិងវិភាគសំណើគម្រោង។ប្រសិនបើចំណាយពេលកាន់តែច្រើនក្នុងការបង្កើតទំនាក់ទំនងមួយឱ្យបានល្អនៅពេលចាប់ផ្តើមដំណើរការចរចា នោះការចរចានឹងអាចធ្វើឡើងក្នុងលក្ខណៈមួយដែលមានការព្រមព្រៀងគ្នាបានយ៉ាងល្អ។ ដំណើរការមួយ ដែលប្រញាប់ប្រញាល់អាចរារាំងសហគមន៍មិនឱ្យសម្រេចបានការព្រមព្រៀងជារួម មុនពេលធ្វើសេចក្តីសម្រេចចុងក្រោយ។ កត្តានេះ អាចបង្កជាជម្លោះរវាង និងក្នុងសហគមន៍ និងជាមួយក្រុមហ៊ុន និងរដ្ឋាភិបាល។ ភាពស្របច្បាប់នៃកិច្ចព្រមព្រៀងអាចមិនទាន់មានលក្ខណៈច្បាស់លាស់ ចំណែកដំណើរការត្រូវចាប់ផ្តើមសាជាថ្មីនៅចំណុចមួយដែលមិនមានការពេញចិត្ត។នៅចុងបញ្ចប់ ភាគីពាក់ព័ន្ធទាំងអស់នឹងត្រូវចំណាយពេល និងធនធានកាន់តែច្រើនដោយសារបញ្ហានេះហើយ ជម្លោះ ដែលកើតចេញពីដំណើរការមួយដែលប្រញាប់ប្រញាល់ អាចធ្វើឱ្យមានការបែកបាក់ទំនុកចិត្តទៅវិញទៅមក និងការទទួលខុសត្រូវសំខាន់ៗក្នុងការសម្រេចបាន និងរក្សាបាននូវការព្រមព្រៀង។ ការត្រៀមខ្លួនរួចជាស្រេចក្នុងការចំណាយពេល និងធនធានក្នុងដំណើរការអាចកាត់បន្ថយហានិភ័យនៃការកើតមានទំនាស់ និងជម្លោះនៅដំណាក់កាលបន្ទាប់នៃដំណើរការគម្រោង និង ជាគន្លឹះដ៏សំខាន់ក្នុងការសម្រេចបានដំណើរការគម្រោងរយៈពេលយូរ និងប្រកបដោយនិរន្តរភាព។ ការកំណត់រកការជំទាស់របស់សហគមន៍លើសំណើគម្រោងឱ្យបានលឿន អាចជួយឱ្យអ្នកបង្កើតគម្រោងផ្តោតកិច្ចខិតខំប្រឹងប្រែងលើដីដែលមានផ្សេងទៀត។

- ចំនួនតួអង្គ និងក្រុមទទួលបានអត្ថប្រយោជន៍ដែលចូលរួមក្នុងការចរចា និងការធ្វើសេចក្តីសម្រេច
- ទីតាំងភូមិសាស្ត្រ និងលទ្ធភាពទទួលបាន
- ប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងសម្ព័ន្ធភាពនៅក្នុងសង្គមដែលមានស្រាប់
- តំណាងថ្នាក់ដឹកនាំដែលមានស្រាប់ និងលទ្ធភាពធ្វើសេចក្តីសម្រេចរបស ់ស្ត្រី និងក្រុមងាយរងគ្រោះផ្សេងទៀត
- បុគ្គលទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានដល់សហគមន៍ក្រៅពីអ្នកដឹកនាំតំណាង
- ប្រសិទ្ធភាពនៃដំណើរការ និងកម្រិតនៃការមិនឯកភាពក្នុងសហគមន៍ចំពោះគម្រោងដែលបានស្នើឡើង
- ដំណើរការទទួលបានព័ត៌មាន និងបច្ចេកវិទ្យាដែលមាន
- កម្រិតនៃភាពចេះអក្សរ និងការអប់រំ
- បញ្ហាពេលវេលាក្នុងការចូលរួមកិច្ចប្រជុំ/ទទួលបានព័ត៌មាន
- កម្រិតនៃការចាប់អារម្មណ៍ក្នុងការចូលរួមដើម្បីទទួលបានព័ត៌មានត្រឹមត្រូវគ្រប់គ្រាន់
- ភាពអាចរកបាន និងប្រសិទ្ធភាពនៃអន្តរការី
- ការផ្តល់ឱ្យការសម្របសម្រួល/ការណែនាំឯករាជ្យ និងគុណភាព
- កម្រិតនៃភាពស្មុគស្មាញពាក់ព័ន្ធនឹងបញ្ហាសិទ្ធិកាន់កាប់ដីធ្លី និងការទាមទារដីត្រួតស៊ីគ្នា
- ទំហំ ការរៀបចំ និងផលប៉ះពាល់របស់គម្រោងដែលកំពុងស្ថិតក្រោមការពិភាក្សា

**ការចូលរួមយ៉ាងទូលំទូលាយ៖** ការខិតខំស្វែងរកការចូលរួមពីសហគមន៍បានយ៉ាងច្រើនបំផុតតាមដែលអាចធ្វើទៅបាននៅក្នុងការធ្វើសេចក្តីសម្រេចរួមមានការចូលរួមពីស្ត្រីយុវជន ប្រជាជនក្រីក្រជនចំណាកស្រុក និងប្រជាជនដែលគ្មាន ដី អាចកាត់បន្ថយលទ្ធភាពក្នុងការប្រឈម ឬបណ្តាលឱ្យកើតមានការជំទាស់ក្នុងសហគមន៍ចំពោះរាល់សេចក្តីសម្រេចដែលបានធ្វើឡើងរួចហើយ។ ការរួមបញ្ចូលក្រុមប្រជាជនទាំងនេះ ក៏អាចឆ្លុះបញ្ចាំងបានកាន់តែប្រសើរពីការពិចារណាលើគុណតម្លៃ ការប្រើប្រាស់ និងធនធានជាច្រើនដែលត្រូវការសម្រាប់ការអនុវត្តគម្រោង។ ត្រូវចងចាំជានិច្ចថា សហគមន៍មិនមែនដូចគ្នាទាំងអស់នោះឡើយ ហើយរាល់សេចក្តីសម្រេច អាចខុសគ្នាពីសហគមន៍មួយទៅសហគមន៍មួយទៀតដោយផ្អែកលើតម្រូវការផ្សេងៗ។

**លទ្ធភាពទទួលបានព័ត៌មាន៖** ដើម្បីឱ្យជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានធ្វើសេចក្តីសម្រេច និងផ្តល់ការព្រមព្រៀងដោយផ្អែកតាមព័ត៌មានត្រឹមត្រូវនោះ ត្រូវផ្តល់ឱ្យពួកគេនូវរាល់សម្ភារ និងឯកសារចងក្រងពីសកម្មភាព។ ការណ៍នេះមានន័យថា ត្រូវផ្តល់ឯកសារទាំងនេះដល់ពួកគេដោយបើកចំហ ក្នុងពេលវេលាត្រឹមត្រូវ និងក្នុងទម្រង់ និងភាសាដែលអាចឱ្យពួកគេយល់បាន។ ប្រសើរបំផុត ត្រូវសរសេរឯកសារទាំងនោះជាភាសាកំណើតរបស់ពួកគេ ដោយមានជំនួយពីអ្នកបកប្រែ។ បញ្ហាភស្តុភារ ដូចជាចំណាយ និងមធ្យោបាយក្នុងការដឹកជញ្ជូន និងផ្សព្វផ្សាយ ក៏ត្រូវយកមកគិតពិចារណាផងដែរក្នុងការរៀបចំការពិគ្រោះយោបល់។ ធ្វើដូច្នេះទើបសហគមន៍មូលដ្ឋានមិនជួបការលំបាកនៅពេលចូលរួម។

**ការជឿជាក់៖** ចំណុចស្នូលនៃការគោរពការយល់ព្រមជាមុន រួមមានដំណើរការនៃការបង្កើតទំនាក់ទំនងដែលមានការជឿជាក់ទៅវិញទៅមក និងការយល់ដឹងតាមរយៈការចែករំលែកព័ត៌មានទៅវិញទៅមកប្រកបដោយតម្លាភាព ការបង្ហាញពីគណនេយ្យភាព ការពិភាក្សាយ៉ាងទូលំទូលាយការចរចាម្តងហើយម្តងទៀត និងការចូលរួមដោយសុចរិត។ នៅក្នុងដំណើរការនេះ ក្រុមហ៊ុនព្រមព្រៀងគោរពសិទ្ធិទូទៅរបស់សហគមន៍ ចូលរួមនៅក្នុងកិច្ចសន្ទនា សិក្សាពីជម្រើស និងផ្តល់ព័ត៌មាន អនុវត្តដោយការគោរពយល់ព្រមគាំទ្រនៅពេលមានការស្នើសុំ ចូលរួមក្នុងការចរចាក្នុងករណីមានការព្រមព្រៀង និងទទួលយក និងគោរពតាមសេចក្តីសម្រេច។ តាមរយៈនេះ ទំនាក់ទំនងប្រកបដោយសន្តិភាព និងរយៈពេលយូរ និងសន្តិសហវិជ្ជមាន ដែលមានការព្រមព្រៀងអាចឋិតថេរជានិរន្ត ហើយដំណោះស្រាយចំពោះចំណុចដែលមិនទាន់បានព្រមព្រៀងគ្នា អាចធ្វើឡើងប្រកបដោយការយោគយល់ និងគោរពគ្នាទៅវិញទៅមក។ ភាពបត់បែន ភាពក្រៅផ្លូវការ ពេលវេលា និងឱកាសក្នុងការស្គាល់គ្នាទៅវិញទៅមកឱ្យបានកាន់តែច្រើនគឺ ជាមធ្យោបាយដ៏សំខាន់ក្នុងការបង្កើតទំនុកចិត្តទៅវិញទៅមក និងដោយបើកចំហគំនិតទៅវិញទៅមក។ ប្រការសំខាន់ តំណាងរដ្ឋាភិបាល ក្រុមហ៊ុន និងសហគមន៍មូលដ្ឋានមានអំណាចច្បាស់លាស់ក្នុងការនិយាយតំណាង និងធ្វើឱ្យកិច្ចព្រមព្រៀងក្លាយជាកិច្ចព្រមព្រៀង ដែលចងភ្ជាប់កាតព្វកិច្ចជំនួសឱ្យស្ថាប័នរបស់ខ្លួន។

**ការយល់ដឹងពីវប្បធម៌៖** បទដ្ឋានវប្បធម៌ និងការរំពឹងទុក នឹងកំណត់ពីរបៀបដែលជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានទាក់ទង និងចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេច។ កត្តាទាំងនេះ អាចប៉ះពាល់ដល់បែបបទនៃការតំណាង យន្តការធ្វើសេចក្តីសម្រេច លក្ខខណ្ឌពេលវេលា របៀបធ្វើឱ្យកិច្ចព្រមព្រៀងក្លាយជាកិច្ចព្រមព្រៀងដែលចងកាតព្វកិច្ច និងកត្តាចូលរួមក្នុងដំណើរការចរចា។ ការលើកឡើងពី

តម្រូវការទាំងនេះ គឺមានសារសំខាន់ខ្លាំងណាស់ក្នុងការទទួលបានលទ្ធផលល្អប្រសើរ និងស្របច្បាប់ ហើយភាគីទាំងសងខាងពេញចិត្ត។ នៅពេលដែលជនជាតិដើមភាគតិច មិនត្រូវបានទទួលស្គាល់ ឬចុះបញ្ជីជាប្រជាពលរដ្ឋទេនោះ ឬនៅពេលដែលមិនមាននីតិរដ្ឋ និងឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ ប្រការសំខាន់ ត្រូវគោរពច្បាប់ជាប្រពៃណី និងប្រព័ន្ធជាប្រពៃណីសម្រាប់ការធ្វើសេចក្តីសម្រេច និងទទួលបានការព្រមព្រៀង។

**ការគោរពសិទ្ធិក្នុងការនិយាយថា "ទេ"៖** ក្រុមហ៊ុន និងរដ្ឋាភិបាលដែលចូលរួមក្នុងការចរចាដោយសុចរិតជាមួយសហគមន៍ ត្រូវទទួលស្គាល់ថា ទោះបីជាមានការអនុវត្តដំណើរការចរចា និងផ្តល់ព័ត៌មានយ៉ាងយកចិត្តទុកដាក់ក៏ដោយ ប៉ុន្តែជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន មានសិទ្ធិបដិសេធចំពោះការអភិវឌ្ឍឬគម្រោងនៅលើដីដែលប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់ខ្លួន។ផលវិបាកមួយចំនួននៃការសម្រេចបដិសេធរបស់ជនជាតិដើមភាគតិច មានភាពខុសគ្នាទៅតាមកាលៈទេសៈ។ ជាទូទៅគម្រោងដែលមានផលប៉ះពាល់ផ្ទាល់ ឬច្រើនលើជីវភាព និងសិទ្ធិមូលដ្ឋានរបស់ជនជាតិដើមភាគតិច មិនអាចអនុវត្តបានឡើយ ប្រសិនបើមិនមានការព្រមព្រៀងទេនោះ។ ជាពិសេស មិនត្រូវមានការផ្លាស់ប្តូរទីលំនៅរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន និងការរក្សាទុក ឬបោះចោលសារធាតុដែលមានគ្រោះថ្នាក់លើដីរបស់ពួកគេដោយមិនមានយល់ព្រមជាមុន។ សម្រាប់ការសម្រេច"យល់ព្រម"ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន អាចចរចាលក្ខខណ្ឌដែលពួកគេអាចព្រមព្រៀងចំពោះការអភិវឌ្ឍន៍ដែលបានស្នើឡើងលើដីរបស់ពួកគេ។ កិច្ចព្រមព្រៀងនៅដំណាក់ កាលណាមួយ នៃដំណើរការមិនមែនបានន័យថាជាការព្រមព្រៀងទុកជាលទ្ធផលចុងក្រោយដោយស្វ័យប្រវត្តិនោះឡើយ។

### តើត្រូវកំណត់ "អាទិភាព" ដោយរបៀបណា?

ដោយសារតែរដ្ឋាភិបាលមានកាតព្វកិច្ចចម្បងក្នុងការធានាឱ្យមានការគោរពការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្តរដ្ឋាភិបាលត្រូវចាត់វិធានការឱ្យបានលឿនបំផុតតាមដែលអាចធ្វើបានពាក់ព័ន្ធនឹងការប្រើប្រាស់ដី និងការរៀបចំផែនការគម្រោងដើម្បីឱ្យប្រជាជនដែលរងផលប៉ះពាល់បានចូលរួម។មិនគួរមានការសម្រេចចិត្តណាមួយ ក្នុងការបែងចែកដីទៅឱ្យភាគីទីបី ដោយមិនមានការជូនដំណឹងជាមុនដល់ប្រជាជនពាក់ព័ន្ធ និងការធានាបានការព្រមព្រៀងរបស់ពួកគេក្នុងនីតិវិធីដែលបានកំណត់ដូចខាងក្រោមឡើយ។ រដ្ឋាភិបាលមានភារកិច្ចសំខាន់ក្នុងការធានាថា ដីទាំងនោះ មិនត្រូវបានចែកទៅឱ្យក្រុមហ៊ុនតាមរយៈការលក់ដូរ ការជួល ការធ្វើសម្បទាន ឬជួលក្នុងលក្ខណៈមួយដែលបំពានសិទ្ធិ ឬបង្កើតឱ្យមានជាជម្លោះនោះឡើយ។

សម្រាប់ក្រុមហ៊ុនវិញស្ថានភាពនេះអាចមានលក្ខណៈស្រពេចស្រពិល។ ក្រុមហ៊ុនអាចយល់ថា ដីដែលខ្លួនបានធ្វើលទ្ធកម្មពីរដ្ឋាភិបាល (ឬតាមរយៈការផ្ទេរដីធ្លី) មានជាប់បន្ទុកសិទ្ធិជាប្រពៃណីដែលស្ថាប័នរដ្ឋាភិបាលបានមើលរំលង ឬមិនបានយកចិត្តទុកដាក់។ ក្នុងករណីបែបនេះ ក្រុមហ៊ុនទាំងនេះ អាចចូលរួមដោយផ្ទាល់ជាមួយសហគមន៍ដោយសុចរិត ដោយពន្យល់រៀបរាប់ពីស្ថានភាព។ ក្រុមហ៊ុនទាំងនោះ គួរអនុវត្តនីតិវិធីដែលមានកំណត់ដូចខាងក្រោម និងផ្សព្វផ្សាយថា ក្រុមហ៊ុននឹងមិនកាប់ឆ្ការដី ឬបន្តគោលបំណងវិនិយោគដោយមិនមានការទទួលស្គាល់ជាមុនពីកម្រិតពេញលេញនៃសិទ្ធិជាប្រពៃណី និងធានាឱ្យមានការយល់ព្រមជាមុនសម្រាប់ផែនការរបស់ខ្លួនពីអ្នកមានសិទ្ធិពាក់ព័ន្ធ។

ទោះជាយ៉ាងណាត្រូវមានការទទួលស្គាល់ថាស្ថានភាពបែបនេះបានដាក់សហគមន៍ដែលរងផលប៉ះពាល់ទៅក្នុងស្ថានភាពមួយដែលជួបការលំបាកកាន់តែខ្លាំង។ នៅពេលដែលដីរបស់ពួកគេត្រូវបានបែងចែកទៅឱ្យភាគីទីបីដោយមិនមានការព្រមព្រៀងពីពួកគេ នោះអានុភាពរបស់សហគមន៍នៅក្នុងការចរចាជាបន្តបន្ទាប់ជាមួយក្រុមហ៊ុននោះ នឹងកាន់តែខ្សោយទៅៗ។

## ការកំណត់រកអ្នកមានសិទ្ធិ[៧]

គោលបំណងនៃដំណាក់កាលនេះ គឺត្រូវកំណត់រកអ្នកដែលមានសិទ្ធិស្រាប់ និងអ្នកប្រើប្រាស់ដីក្នុងតំបន់គម្រោងគោលដៅក្នុងដំណើរការមួយដែលមានការចូលរួម។ កិច្ចការនេះនឹងជួយកំណត់ពីរបៀបដែលសហគមន៍មូលដ្ឋានប្រើប្រាស់ដី ព្រមទាំងប្រភេទនៃការទាមទារផ្សេងៗ របស់ក្រុមជាច្រើនទៅលើដីគោលដៅ និងធនធានធម្មជាតិ និងអ្នកដែលមានសិទ្ធិទទួលបានការពិគ្រោះយោបល់ និងផ្តល់ ឬលុបចោលការព្រមព្រៀងចំពោះគម្រោង។ គួរមានការកំណត់អ្នកមានសិទ្ធិនៅគ្រប់ផ្នែកទាំងអស់នៃតំបន់គម្រោងគោលដៅ ព្រមទាំងតំបន់ជុំវិញតំបន់គម្រោង។សហគមន៍ជិតខាង អាចទាមទារយកដីដែលនៅក្នុងតំបន់គម្រោង ឬធនធានដែលរងផលប៉ះពាល់ដោយសារសកម្មភាពគម្រោង (ដូចជា ទឹក) ឬក៏ពួកគេអាចប្រើប្រាស់ធនធានក្នុងតំបន់នោះ តាមរដូវ ឬមានទម្រង់បែបបទសិទ្ធិកាន់កាប់ផ្សេងទៀត ជាមួយប្រជាជនដែលរស់នៅក្នុងតំបន់គម្រោងគោលដៅ។

**តើអ្វីខ្លះជាសិទ្ធិប្រពៃណី?**

> សិទ្ធិប្រពៃណីបានមកពីច្បាប់ជាប្រពៃណី ដែលជាកម្រងក្បួនខ្នាតមិនមែនជាលាយលក្ខណ៍អក្សរដែលទាញយកអំណាចពី "ប្រពៃណី"។ ច្បាប់ជាប្រពៃណី គ្របដណ្តប់បញ្ហាជាច្រើន រួមមាន ទំនាក់ទំនងគ្រួសារ ច្បាប់ស្តីពីទ្រព្យសម្បត្តិ និងការប្រើប្រាស់ និងកម្មសិទ្ធិលើដី និងធនធានធម្មជាតិ។ សិទ្ធិកាន់កាប់ដី ដែលប្រើប្រាស់ជាលក្ខណៈប្រពៃណី សំដៅលើប្រព័ន្ធដែលសហគមន៍ជនបទជាច្រើន ប្រើប្រាស់ដើម្បីបង្ហាញ និងគ្រប់គ្រងកម្មសិទ្ធិរបស់ខ្លួន គ្រប់គ្រង ប្រើប្រាស់ ទទួលបាន និងផ្ទេរដី និងធនធានធម្មជាតិ។ សិទ្ធិកាន់កាប់ដី ដែលប្រើប្រាស់ជាលក្ខណៈប្រពៃណីជារឿយៗ ពាក់ព័ន្ធទៅនឹងគោលគំនិតមូលដ្ឋានដ៏ស្មុគស្មាញនៃញាតិព័ន្ធមរតកពីជំនាន់មួយ ទៅជំនាន់មួយ និងការកំណត់និយមន័យ របស់សង្គមយ៉ាងទូលំទូលាយស្តីពីតួនាទី និងសិទ្ធិរបស់បុគ្គល និងក្រុមក្នុងសហគមន៍។
>
> ច្បាប់ និងសិទ្ធិប្រពៃណីបានមកពីសហគមន៍ជាជាងបានមកពីរដ្ឋ (ច្បាប់) ហើយទោះបីជាមូលដ្ឋានប្រព័ន្ធទាំងពីរនេះ មានលក្ខណៈជាន់គ្នាក៏ដោយ ក៏ជារឿយៗ សិទ្ធិប្រពៃណីមិនត្រូវបានទទួលស្គាល់ ឬទទួលបានការឱ្យតម្លៃស្មើគ្នាពីរដ្ឋឡើយ។ សិទ្ធិប្រពៃណី អាចមានលក្ខណៈមិនផ្លូវការ (ដោយសារមិនមានការទទួលស្គាល់ពីរដ្ឋដោយផ្លូវការ) ឬក៏ច្បាប់ទាំងនោះ អាចមានលក្ខណៈផ្លូវការនៅពេលដែលច្បាប់ទាំងនោះ ត្រូវបានអនុវត្តជាធរមានដោយ សន្ធិសញ្ញាអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយស្ថាប័នជាតិ ច្បាប់ និងបទប្បញ្ញត្តិ ឬតាមរយៈសេចក្តីសម្រេចរបស់តុលាការ។ សិទ្ធិកាន់កាប់ដីដែលប្រើប្រាស់ជាលក្ខណៈប្រពៃណីមានលក្ខណៈខុសគ្នាទៅតាមសហគមន៍ ដោយអាស្រ័យតាមទីតាំង ការរៀបចំសង្គម និងបែបបទនៃការចិញ្ចឹមជីវិត។ នៅក្នុងសហគមន៍មួយចំនួនដី និងធនធានធម្មជាតិអាចត្រូវបានគ្រប់គ្រង និងប្រើប្រាស់ជាសមូហភាព និងគ្រប់គ្រងដោយស្មើភាព (ពេលខ្លះសំដៅលើ "កម្មសិទ្ធិរួម" នៃសិទ្ធិកាន់កាប់ជាប្រពៃណី)។ ជារឿយៗ សិទ្ធិត្រូវបាន "ផ្តល់ឱ្យ" នៅពេលដែលដីកសិកម្មរបស់បុគ្គល ឬគ្រួសារត្រូវបានគ្រប់គ្រងក្នុងដែនដីសហគមន៍យ៉ាងទូលំទូលាយ។ ដី និងធនធាន ធម្មជាតិក៏មានគុណតម្លៃផ្នែកសង្គម វប្បធម៌ ជំនឿ សេដ្ឋកិច្ច បរិស្ថាន និងនយោបាយផងដែរ សម្រាប់ជនជាតិដើមភាគតិច និងសហគមន៍ផ្សេងទៀតដែលមានប្រព័ន្ធកាន់កាប់ដីជាប្រពៃណី។

7 ការកំណត់រកអ្នកមានសិទ្ធិ ៖ សូមមើលគោលការណ៍ណែនាំក្នុង 3A.1.1; 4.5; 7.1–7.6; 8.2; 8.4; 8.6; 8.7; 9.5; 9.8; 11.5; 12.9; 12.10; ផ្នែក 17.1-17.5។

### តើកិច្ចការនេះគួរត្រូវអនុវត្តដោយរបៀបណា?

រៀបចំបទសម្ភាសន៍ការពិគ្រោះយោបល់ និងកិច្ចពិភាក្សាក្រុមគោលដៅដោយបំពេញបន្ថែម ឬអមមកជាមួយនូវបញ្ជីសំណួរ ដើម្បីកំណត់ពី៖

- បុគ្គល គ្រួសារ ភូមិ កុលសម្ព័ន្ធ និងនីតិបុគ្គលក្នុងសង្គមក្នុងតំបន់គម្រោង និងតំបន់នៅជុំវិញ
- លក្ខណៈនៃទំនាក់ទំនងដែលមានស្រាប់ក្នុងចំណោមក្រុមទាំងនេះ។ ទំនាក់ទំនងទាំងនេះអាចរួមមានទំនាក់ទំនងពីជំនាន់មួយទៅជំនាន់មួយព្រមទាំងទំនាក់ទំនងសេដ្ឋកិច្ចសង្គមទូទៅដូចជាទំនាក់ទំនងពាណិជ្ជកម្ម នយោបាយ សេដ្ឋកិច្ច ឬវប្បធម៌។
- ទីតាំងភូមិសាស្ត្រ និងប្រជាជនសរុបនៃក្រុមផ្សេងៗដែលបានកំណត់។ ផែនទីនិងប្រព័ន្ធកំណត់កូអរ៍ឌីណេភូមិសាស្ត្រ (GPS) អាចប្រើប្រាស់ដើម្បីចង្អុលបង្ហាញទីតាំង។ត្រូវចងចាំជានិច្ចថាសហគមន៍មួយចំនួន អាចមានលក្ខណៈចល័ត ផ្លាស់ប្តូរទីតាំងតាមរដូវក្នុងដែនដីមួយ ដោយអាស្រ័យលើបែបបទនៃការចិញ្ចឹមជីវិត។ ឧទាហរណ៍ដូចជា អ្នកប្រមាញ់ និងនេសាទ អ្នកចិញ្ចឹមសត្វ កសិករដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ និងពលករបណ្តោះអាសន្ន។
- អង្គភាពគ្រប់គ្រងដែលមានសហគមន៍រស់នៅ និងប្រើប្រាស់សិទ្ធិ (ដូចជា តំបន់ ស្រុក ឬខេត្ត)។
- លក្ខណៈទំនាក់ទំនងរវាងសហគមន៍ និងរដ្ឋពាក់ព័ន្ធនឹងអភិបាលកិច្ច និងការគ្រប់គ្រង ការប្រើប្រាស់ច្បាប់ជាប្រពៃណី និងការទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លី ជាពិសេសផ្អែកតាមសិទ្ធិជាប្រពៃណី។
- ប្រវត្តិនៃការកាន់កាប់ដីនិងការប្រើប្រាស់របស់សហគមន៍មូលដ្ឋាន ទំនាក់ទំនងរបស់ពួកគេទៅនឹងដីធ្លី ប្រព័ន្ធជាប្រពៃណីនៃសិទ្ធិកាន់កាប់ដី ការគ្រប់គ្រង និងការទទួលកេរ្តិ៍ មរតក និងរបៀបដែលការផ្ទេរដីត្រូវបានគ្រប់គ្រងជាប្រពៃណី ទាំងក្នុងចំណោម និងក្នុងសហគមន៍ និងក្រៅសហគមន៍។ ប្រសិនបើមានជាតិពន្ធុច្រើន ត្រូវស្វែងយល់ពីរបៀបដែលប្រជាពលរដ្ឋទាំងនោះ មានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក និងគ្រប់គ្រងទំនាក់ទំនងពាក់ព័ន្ធនឹងធនធានដី និងធម្មជាតិ។
- របៀបដែលសហគមន៍បង្ហាញភាពត្រឹមត្រូវនៃការទាមទារយកដី និងការប្រើប្រាស់ដី។ ទាំងនេះ អាចរួមមាន ច្បាប់ជាប្រពៃណី ពូជពង្ស កេរ្តិ៍ មរតក ការទិញ ការជួល ឬកម្មវិធីផ្តល់ទីជម្រកដែលឧបត្ថម្ភដោយរដ្ឋ។ ត្រូវចងចាំជានិច្ចថា អ្នកមានសិទ្ធិ និងអ្នកប្រើប្រាស់ដីអាចខុសពីបុគ្គលម្នាក់ៗ ឬសហគមន៍ផ្សេងទៀត។
- កត្តាប្រវត្តិសាស្ត្រដែលបានកំណត់ និងកែប្រែប្រជាជនដែលមានស្រាប់ និងទំនាក់ទំនងទៅនឹងការប្រើប្រាស់ដី។ កត្តាទាំងនេះ អាចជាសង្គ្រាមស៊ីវិលពីអតីតកាល ឬកំពុងតែបន្ត ជនបំលាស់ទីក្នុងស្រុក (IDPs) លំនាំនៃការធ្វើចំណាកស្រុក ឬការអភិវឌ្ឍទីក្រុង និងវិស័យកសិកម្ម។
- លក្ខណៈប្រជាសាស្ត្ររបស់សហគមន៍។ ទាំងនេះ អាចរួមមាន ក្រុមអាយុ ផលធៀបយេនឌ័រ និងក្រុមប្រជាជនក្នុងមូលដ្ឋាន និងជនចំណាកស្រុក។
- ស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសហគមន៍។ ទាំងនេះ អាចរួមមាន តួនាទីក្នុងការបែងចែកកម្លាំងការងារ សិទ្ធិទទួលបាន និងប្រើប្រាស់ដី អំណាចក្នុងការធ្វើសេចក្តីសម្រេច និងរបៀបដែលពួកគេទទួលបានការតំណាង[៨]។

---

8 យេនឌ័រ ៖ សូមមើលគោលការណ៍ណែនាំក្នុង 3B.3; 3B.4; 4.4; 4.6; 4.7; 5.3; 5.4; 5.5; 6.1; 7.1; 7.4; 8.9; 8.11; 9.2; 9.6; 9.10; 10.1; 10.3; 12.11; 13.5; 13.6; 14.4; 15.3; 15.5; 15.6; 15.9; 15.10; 17.3; 20.2; 20.3; 21.1; 23.2; 25.3; 25.4; 25.5; 26.2។ សម្រាប់ការណែនាំស្តីពី ការគ្រប់គ្រងដីដែលមានសមធម៌យេនឌ័រ សូមមើល អង្គការ FAO ឆ្នាំ២០១៣។

- បែបបទនៃការរស់នៅក្នុងសហគមន៍ និងធនធានដែលពួកគេអាស្រ័យដើម្បីចិញ្ចឹមជីវិត។ ទាំងនេះអាចរួមមាន ការធ្វើកសិកម្មជាអចិន្ត្រៃយ៍ ឬតាមរដូវ ការចិញ្ចឹមសត្វ ការនេសាទ ការប្រមាញ់ ឬការរួមបញ្ចូលរបរទាំងនេះ។
- ប្រព័ន្ធមូលដ្ឋាននៃការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិ អាចមានដូចជា ការគ្រប់គ្រង និងការប្រើប្រាស់ទឹកទន្លេ និងសមុទ្រ ដី ព្រៃឈើ ដំណាំ និងការចិញ្ចឹមសត្វ។ ប្រជាជននៅតាមជនបទភាគច្រើនមានសេដ្ឋកិច្ចចម្រុះ និងប្រើប្រាស់ដី និងធនធានខុសៗគ្នា។
- ទម្រង់មូលដ្ឋាននៃការរៀបចំសង្គម រួមបញ្ចូលទាំងប៉ុន្តែមិនកំណត់ត្រឹមបុគ្គល និងស្ថាប័នទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេច ការពង្រឹងការអនុវត្តច្បាប់ជាប្រពៃណី ការគោរពសាសនា សកម្មភាពសេដ្ឋកិច្ច ទំនាក់ទំនងក្នុង និងក្រៅសហគមន៍ អំណាចនយោបាយ និងការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិ។
- កម្រិតអក្ខរភាពក្នុងមូលដ្ឋាន៖ នៅក្នុងសហគមន៍មូលដ្ឋានដែល ថ្នាក់ដឹកនាំ មិនចេះអក្សរ ឬចេះអក្សរតិចតួច ប្រការសំខាន់ត្រូវជានាថា រាល់ព័ត៌មានដែលបញ្ជូនទៅពួកគេស្ថិតក្នុងទម្រង់ និងភាសាដែលអាចយល់បាន និងសមស្រប ហើយរាល់ដំណើរការត្រូវបានថតទុកជាសម្លេងសម្រាប់ជាឯកសារយោង។ ការប្រើប្រាស់ដ្យាក្រាម រូបភាព និងវីដេអូ ក្រៅពីទំនាក់ទំនងផ្ទាល់ក៏អាចជួយឱ្យសហគមន៍ទទួលបានព័ត៌មានផងដែរ។
- គុណតម្លៃផ្នែកវប្បធម៌របស់ដី និងធនធានធម្មជាតិសម្រាប់សហគមន៍ អាចរួមមាន ទំនាក់ទំនងផ្នែកសេដ្ឋកិច្ចសង្គម ជំនឿ/សាសនា នយោបាយ ប្រវត្តិសាស្ត្រ និងទំនាក់ទំនងគ្រួសារទៅនឹងដី[៩]។
- ជម្លោះពីអតីត និង/ឬជាបន្តបន្ទាប់ ឬជម្លោះរវាង និងក្នុងសហគមន៍ពាក់ព័ន្ធនឹងដី និងធនធានធម្មជាតិ និងបុព្វហេតុនៃជម្លោះ។ ការយល់ដឹងពីជម្លោះដែលមានស្រាប់អាចជួយបញ្ចៀសការបញ្ចូលគ្នារវាងក្រុមខុសៗគ្នា និងផ្តល់លទ្ធភាពឱ្យមានការយល់ដឹងកាន់តែប្រសើរពីអត្ថប្រយោជន៍ផ្សេងៗ និងផ្នែកផ្សេងទៀតដែលប្រឈមនឹងហានិភ័យ។
- ជម្លោះពីអតីត និង/ឬជាបន្តបន្ទាប់ ឬជម្លោះរវាង និងក្នុងសហគមន៍ និងក្រុមហ៊ុន ឬស្ថាប័នរដ្ឋក្នុងតំបន់ បុព្វហេតុនៃជម្លោះ និងរបៀបដែលជម្លោះទាំងនោះត្រូវបាន និងកំពុងដោះស្រាយ។ សម្រាប់ការបំពានសិទ្ធិរបស់សហគមន៍ដោយតួអង្គ ឬប្រជានគ្រប់គ្រងគម្រោងមុនៗ ឬការសន្យាដែលមិនទាន់បានបំពេញរបស់តួអង្គគម្រោងមុនៗចំពោះសហគមន៍ចាំបាច់ត្រូវដោះស្រាយ និងផ្តល់ជាដំណោះស្រាយ។
- ភាពខុសគ្នាផ្នែកភាសារវាងពាក្យតាមតំបន់ និងពាក្យផ្លូវការ និងពាក្យជាក់លាក់តាមតំបន់ផ្សេងទៀត។ ទាំងនេះអាចមានបញ្ចូលនិកាយរបស់ក្រុមសង្គម និងការប្រើប្រាស់ពាក្យដើម្បីរៀបរាប់ពីសិទ្ធិការអនុវត្តរចនាសម្ព័ន្ធនៃការធ្វើសេចក្តីសម្រេច និងការរៀបចំនយោបាយ។ ការរក្សាបាននូវនិយមន័យច្បាស់លាស់អាចជួយបញ្ចៀសការយល់ខុស និងផ្តល់សារសំខាន់ក្នុងការទទួលបានប្រព័ន្ធមូលដ្ឋាននៃចំណេះដឹង និងពាក្យបច្ចេកទេស។ ត្រូវប្រាកដថាអ្នកបកប្រែមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចាប់យកនិងប្រើប្រាស់ពាក្យ ដែលមានន័យខុសគ្នាបន្តិចបន្តួច និងពាក្យក្នុងតំបន់។

**គោលការណ៍ណែនាំស្តីពីគុណតម្លៃផ្នែកវប្បធម៌របស់ដី និងធនធានធម្មជាតិ**

*ប្រភព* ៖ អង្គការ FAO ឆ្នាំ២០១២

**៩.១** រដ្ឋ និងតួអង្គមិនមែនរដ្ឋគួរទទួលស្គាល់ថា ដី ធនធានជលផល និងធនធានព្រៃឈើមានគុណតម្លៃផ្នែកសង្គម វប្បធម៌ ជំនឿ សេដ្ឋកិច្ច បរិស្ថាននិងនយោបាយសម្រាប់ជនជាតិដើមភាគតិច និងសហគមន៍ផ្សេងទៀត ក្នុងប្រព័ន្ធសិទ្ធិកាន់កាប់ជាប្រពៃណី។

9 គុណតម្លៃផ្នែកវប្បធម៌របស់ដី និងធនធានធម្មជាតិ ៖ សូមមើលគោលការណ៍ណែនាំក្នុង 4.8; 5.3; 5.9; 9.1; 9.7; 11.2; 16.2; 18.2.

**រៀបចំជំរឿនដោយផ្អែកតាមបញ្ជីសំណួរ** តាមរយៈការចុះតាមមូលដ្ឋាន និងការពិគ្រោះយោបល់ជាមួយសហគមន៍ទាំងអស់ក្នុងតំបន់គម្រោងគោលដៅ និងតំបន់ជុំវិញតំបន់គម្រោង។ នៅក្នុងការពិគ្រោះយោបល់ត្រូវពន្យល់ភាគីទាំងអស់ឱ្យបានច្បាស់ពីស្ថាប័នដែលអ្នកតំណាង មូលហេតុក្នុងការធ្វើជំរឿន និងស្នើសុំការព្រមព្រៀងដើម្បីទទួលបានការពិគ្រោះយោបល់ និងផ្តល់ព័ត៌មានសម្រាប់បញ្ជីសំណួរ។ សហគមន៍មានសិទ្ធិលុបចោលការព្រមព្រៀងនៅដំណាក់កាលនេះ (ដំណាក់កាលណាមួយ) ក្នុងករណីដែលមិនអាចបន្តគម្រោងទៅមុខបាន។

**ធ្វើយ៉ាងណាឱ្យការពិគ្រោះយោបល់ និងបញ្ជីសំណួរមានលក្ខណៈជាទម្រង់បើក៖** ដំណើរការធ្វើជំរឿនគួរផ្តល់ឱកាសឱ្យមានការគិតគូរពិចារណាពីបញ្ហាពាក់ព័ន្ធផ្សេងទៀត និងបញ្ហាកង្វល់របស់សហគមន៍ ដោយសារតែបញ្ហាទាំងនេះអាចមិនត្រូវបានគិតទុកក្នុងសេចក្តីព្រាងបញ្ជីសំណួរឡើយ។

**ពិគ្រោះយោបល់ជាមួយប្រភពផ្សេងទៀត៖** ការពិគ្រោះយោបល់ជាមួយសហគមន៍ គួរបំពេញបន្ថែមដោយការពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋាភិបាលក្នុងមូលដ្ឋាន ឬតាមបណ្តាខេត្តពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋានជាតិ និងអន្តរជាតិ ដើម្បីបន្តកំណត់រក៖

- ស្ថានភាពរបស់សហគមន៍ និងបុគ្គលដែលរងផលប៉ះពាល់ខ្លាំង និងសិទ្ធិកាន់កាប់ដីជាប្រពៃណីក្នុងច្បាប់មូលដ្ឋាន និងច្បាប់ជាតិ។
- របៀបដែលសហគមន៍ត្រូវបានញែកចេញពីក្រុមសង្គម និងក្រុមសង្គមទូទៅក្នុងច្បាប់រដ្ឋ។
- ជំរឿនដែលអាចរៀបចំក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗ និងថាតើសហគមន៍ត្រូវបានយកមកឆ្លុះបញ្ចាំងក្នុងជំរឿនទាំងនោះ ឬយ៉ាងណា។
- ទិន្នន័យបែងចែកពាក់ព័ន្ធបន្ថែមទៀត។

**ត្រូវផ្តល់លទ្ធផលដែលបានចងក្រង** ដល់ក្រុមទទួលបានអត្ថប្រយោជន៍ ក្នុងទម្រង់ និងភាសាដែលពួកគេអាចមើលយល់[10]។

## ការបញ្ជាក់អះអាងពីស្ថានភាពស្របច្បាប់នៃដី

ក្នុងដំណើរការលទ្ធកម្មដីធ្លី ជំហានសំខាន់ទីមួយក្នុងការគោរពការយល់ព្រមជាមុនគឺត្រូវកំណត់ពីកម្រិតសិទ្ធិរបស់ជនជាតិដើមភាគតិចលើដី និងធនធានផ្សេងទៀត និងប្រភពនៃការធានាបានសិទ្ធិទាំងនេះ។ នៅក្នុងការបង្ហាញ ឬលុបចោលការយល់ព្រមជាមុនចំពោះការវិនិយោគផ្អែកកសិកម្មដែលបានស្នើឡើងប្រជាជនដែលពាក់ព័ន្ធត្រូវទទួលបានការធានាថា កម្រិតពេញលេញនៃសិទ្ធិជាប្រពៃណីរបស់ខ្លួននិងប្រព័ន្ធប្រើប្រាស់ដីបច្ចុប្បន្នត្រូវបានទទួលស្គាល់ និងគោរព។ ដោយសារតែប្រព័ន្ធច្បាប់របស់ប្រទេសជាច្រើនមិនបានទទួលស្គាល់ជាផ្លូវការនូវសិទ្ធិជាប្រពៃណី ប្រការសំខាន់សហគមន៍ត្រូវមានសិទ្ធិផ្តល់ ឬលុបចោលការព្រមព្រៀងចំពោះអ្វីដែលបានកើតឡើងលើដីរបស់ពួកគេ។

គោលបំណងនៃជំហាននេះគឺ ត្រូវកំណត់ពីបុគ្គលដែលមានសិទ្ធិលើដីគម្រោងគោលដៅ ទាំងក្នុងច្បាប់រដ្ឋ និងច្បាប់ជាប្រពៃណី របៀបដែលស្ថានភាពស្របច្បាប់របស់ដីនឹងផ្លាស់ប្តូរ ប្រសិនបើក្រុមហ៊ុនធ្វើលទ្ធកម្មដីនោះ និងផលប៉ះពាល់លើអ្នកមានសិទ្ធិ។ រាល់គោលនយោបាយស្តីពីសិទ្ធិកាន់កាប់ និងការអនុវត្តនឹង

10 ឯកសារ ៖ សូមមើលគោលការណ៍ណែនាំក្នុង 9.8; 12.11; 25.4. ភាពអាចរកបាននៃព័ត៌មាន៖ សូមមើលគោលការណ៍ណែនាំក្នុង 3B.7; 3B.8;5.8; 6.4; 8.9; 9.4; 10.4; 11.3; 14.4; 17.4។

មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ហើយដោយសារតែ ស្ថិរភាពសង្គម និងសន្តិសហវិជ្ជមាន អាចអាស្រ័យលើលក្ខណៈនៃរបបសិទ្ធិកាន់កាប់ដីដែលមានស្រាប់ ប្រការសំខាន់ ត្រូវពិចារណាពីលក្ខណៈសំខាន់ទាំងនេះ។ ប្រការនេះ កាន់តែមានសារសំខាន់ សម្រាប់ប្រទេសដែលសិទ្ធិជាប្រពៃណី មិនត្រូវបានទទួលស្គាល់ ឬការពារដោយច្បាប់ជាតិប្រកបដោយប្រសិទ្ធភាព និងមានអ្នកមានសិទ្ធិច្រើន (ទាំងផ្លូវការនិងក្រៅផ្លូវការ)ដោយមានការទាមទារយកដីតែមួយនោះ។ គួរមានការពិនិត្យលើស្ថានភាពស្របច្បាប់របស់ដី សម្រាប់គ្រប់ផ្នែកនៃតំបន់គម្រោងគោលដៅ ព្រមទាំងតំបន់ជុំវិញតំបន់គម្រោង។

ជារឿយៗ ដីដែលប្រើប្រាស់ជាលក្ខណៈប្រពៃណី ត្រូវបានចាត់ថ្នាក់ជាដីរបស់រដ្ឋស្ថិតក្រោមច្បាប់។ ទោះបីជាគោលការណ៍ណែនាំមានភាពស្របគ្នាជាមួយនឹងច្បាប់អន្តរជាតិក៏ដោយ ក៏នៅតែទាមទារឱ្យស្ថាប័នរដ្ឋ និងវិនិយោគិនធានា ឱ្យមានសិទ្ធិកាន់កាប់ដីស្របច្បាប់រួមមាន ការគោរពសិទ្ធិជាប្រពៃណី និងការទទួលបានការយល់ព្រមជាមុនពីជនជាតិដើមភាគតិចសម្រាប់គម្រោងវិនិយោគ ដែលប៉ះពាល់ដល់សិទ្ធិទាំងនោះ។ ផលវិបាកផ្នែកច្បាប់ក៏ចាំបាច់ត្រូវលើកបង្ហាញផងដែរដូចជា នៅក្នុងយុត្តាធិការនៃច្បាប់តាមប្រទេសអង់គ្លេសជាច្រើន ការកាន់កាប់ដីក្រោមច្បាប់ជាប្រពៃណី ពេលខ្លះហៅថា "កម្មសិទ្ធិដីពីកំណើត" អាចផ្តល់ឱ្យបានសម្រាប់តែរដ្ឋប៉ុណ្ណោះ។ ប្រការនេះ ទាមទារឱ្យរដ្ឋទទួលខុសត្រូវក្នុងនាមជាជនកាន់កាប់ជាទីទុកចិត្តដើម្បីជានាសុខុមាលភាពរបស់ជនជាតិដើមភាគតិច។ បន្ថែមពីនេះដោយសារតែមិនមានទីផ្សារដីក្នុងតំបន់ជនជាតិដើមភាគតិច លក្ខខណ្ឌក្នុងការផ្ទេរដីឱ្យបានត្រឹមត្រូវពីម្ចាស់ ដែលប្រើប្រាស់ដីជាលក្ខណៈប្រពៃណីទៅវិនិយោគិននោះ មិនថាតាមរយៈការជួល ការដាក់ជួល ឬការលក់នោះ មិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ។ ក្នុងកាលៈទេសៈនេះ ស្ថាប័នរដ្ឋាភិបាល មានទំនួលខុសត្រូវចម្បងក្នុងការធានាឱ្យបានភាពត្រឹមត្រូវ និងការពារអត្ថប្រយោជន៍របស់សហគមន៍ ដែលមានសិទ្ធិមិនគ្រប់គ្រាន់ ឬមិនមានការធានា។

## តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា?

ជំរុញឱ្យមានការចូលរួមពីអ្នកផ្តល់ប្រឹក្សា ឬមេធាវីដើម្បីរៀបចំការពិនិត្យឡើងវិញឱ្យបានហ្មត់ចត់លើច្បាប់ជាតិ ក្របខណ្ឌគោលនយោបាយ និងស្ថាប័ន។ ប្រសើរបំផុត អ្នកផ្តល់ប្រឹក្សា គួរប្រើប្រាស់វិធីសាស្ត្រសាកសួរដែលមានភាពច្នៃប្រឌិត និងចម្រុះផ្នែកព្រមទាំងអភិក្រមដែលមានការសហការ និងការចូលរួមក្នុងដំណើរការស្រាវជ្រាវ។

ការពិនិត្យឡើងវិញគួរមានបញ្ចូល៖

- ច្បាប់ ស្ថាប័ន និងគោលនយោបាយ ដែលចែងពីក្របខណ្ឌសម្រាប់លទ្ធកម្មដីធ្លីក្នុងប្រទេសជាក់លាក់ដែលស្ថិតក្រោមការពិចារណា
- សិទ្ធិកាន់កាប់ដីរបស់ប្រជាពលរដ្ឋ ស្ត្រី ជនជាតិដើមភាគតិច និងក្រុមជាតិពន្ធុ
- ស្ថានភាពស្របច្បាប់របស់ដីជាផ្លូវការបច្ចុប្បន្នស្ថិតក្រោមច្បាប់ជាតិ។ ដីអាចត្រូវបានរៀបចំជាដីរដ្ឋ ដីសាធារណៈ ដីឯកជន ដីដែលប្រើប្រាស់ជាលក្ខណៈប្រពៃណី ព្រៃរដ្ឋ ព្រៃសាធារណៈ ព្រៃឯកជន ព្រៃសហគមន៍ ព្រៃឧស្សាហកម្ម ឬព្រៃអភិរក្ស ព្រៃការពារ សម្បទាន។ល។ ក្រៅពីនេះ ត្រូវកំណត់ពីភាពត្រួតស៊ីគ្នា នៃការធ្វើចំណាត់ថ្នាក់ដីជាផ្លូវការ។

- យុត្តាធិការពាក់ព័ន្ធ និងអង្គភាពរដ្ឋ ដែលទទួលខុសត្រូវលើដី ការគ្រប់គ្រង និងការបែងចែកដីនោះ។ អង្គភាពទាំងនេះអាចជាអាជ្ញាធរជាតិនិង/ឬខេត្ត ក្រសួងបរិស្ថានដីនិង/ឬកសិកម្មនាយកដ្ឋានព្រៃឈើ ឬស្ថាប័នជំនាញផ្សេងទៀត។ ក្រៅពីនេះ ត្រូវកំណត់ពីភាពត្រួតស៊ីគ្នាក្នុងយុត្តាធិការលើតំបន់គម្រោងគោលដៅ។
- របៀបដែលសិទ្ធិកាន់កាប់ដីដែលប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋានត្រូវបានទទួលស្គាល់ដោយច្បាប់ជាតិ និងគោលនយោបាយ និងរបៀបដែលសិទ្ធិនេះប៉ះពាល់ដល់សហគមន៍មួយចំនួនក្នុងតំបន់គម្រោងគោលដៅ។ ព័ត៌មានពាក់ព័ន្ធរួមមាន សិទ្ធិធានាដោយរដ្ឋធម្មនុញ្ញ និងសិទ្ធិក្រោមច្បាប់ផ្សេងទៀតដូចជា ច្បាប់ភូមិបាល ច្បាប់បរិស្ថាន និងច្បាប់ស្តីពីព្រៃឈើជាដើម។ ក្នុងករណីដែលមានការទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លី អាចមានដូចជា ប័ណ្ណកម្មសិទ្ធិ ឯកសារ ការជួល ម្ចាស់កម្មសិទ្ធិ ការគ្រប់គ្រង ការប្រើប្រាស់/សិទ្ធិទទួលបានអត្ថប្រយោជន៍ ឬសិទ្ធិទទួលបានពីកំណើត និងអាចមានលក្ខណៈជាការចែករំលែកការដាំដំណាំ និងសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ។ ក្នុងប្រទេសជាច្រើន សិទ្ធិទាំងនេះត្រូវចងក្រងជាឯកសារផ្លូវការ ដើម្បីទទួលស្គាល់ (ដែលអាចត្រូវចំណាយច្រើន) ប៉ុន្តែក្នុងប្រទេសផ្សេងទៀត សិទ្ធិជាប្រពៃណីត្រូវបានទទួលស្គាល់ដោយមិនមានការចុះបញ្ជីផ្លូវការ។
- ស្ថានភាពដីចេញពីទស្សនៈរបស់សហគមន៍ និងច្បាប់ជាប្រពៃណី ថាតើច្បាប់ជាប្រពៃណីនេះ មានលក្ខណៈ ផ្លូវការ ឬមិនផ្លូវការ។
- ថាតើច្បាប់រដ្ឋ និងគោលនយោបាយទទួលស្គាល់ និងការពារសិទ្ធិសមូហភាព និងសិទ្ធិជាប្រពៃណីរបស់សហគមន៍ក្នុងការកាន់កាប់ដី ឬយ៉ាងណា និងផ្អែកលើមូលដ្ឋានអ្វីខ្លះ។
- ដំណើរការស្របច្បាប់ដែលក្រុមហ៊ុន និង/ឬ រដ្ឋនឹងធ្វើលទ្ធកម្មដីធ្លី និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធទាំងអស់ដែលត្រូវទាក់ទង។
- ការផ្លាស់ប្តូរស្ថានភាពស្របច្បាប់របស់ដី ក្នុងករណីដែលក្រុមហ៊ុនធ្វើលទ្ធកម្មដី។
- ផលវិបាកដែលអាចកើតមានសម្រាប់សហគមន៍មូលដ្ឋាន ដោយសារការផ្លាស់ប្តូរស្ថានភាពស្របច្បាប់របស់ដី ពាក់ព័ន្ធនឹងលទ្ធភាព និងសិទ្ធិកាន់កាប់ដីក្នុងរយៈពេលខ្លី មធ្យម និងវែង។ គោលការណ៍នេះអាចអាស្រ័យលើលក្ខណៈ និងរយៈពេលរបស់គម្រោង ឬស្ថានភាពស្របច្បាប់នៃសិទ្ធិកាន់កាប់ដី(ដូចជាដាក់ជួល ដាក់លក់ឬការធ្វើកិច្ចសន្យាសាជាថ្មី)។ បន្ថែមពីនេះកំណត់ពីស្ថានភាពសិទ្ធិរបស់សហគមន៍បន្ទាប់ពីផុតកំណត់ការជួល។ ឧទាហរណ៍ តើដីនឹងផ្តល់ជូនទៅឱ្យសហគមន៍វិញ ឬក៏ដីនោះ នឹងត្រូវបានធ្វើចំណាត់ថ្នាក់ម្តងទៀតទុកជាដីរដ្ឋ? ត្រូវបញ្ជាក់ពីបញ្ហានេះ ឱ្យបានច្បាស់ដល់សហគមន៍ដើម្បីជានាបាន ការចរចា។
- ដំណើរការពិគ្រោះយោបល់ស្របច្បាប់ ដែលទាមទារឱ្យមានការពិគ្រោះយោបល់សម្រាប់លទ្ធកម្មដីធ្លីយោងតាមច្បាប់ជាតិ ឬការសន្យាជាអន្តរជាតិ និងទម្លាប់អនុវត្តន៍ដំណើរការពីមុនមកសម្រាប់លទ្ធកម្មដីធ្លីផ្សេងទៀត។
- តួអង្គគម្រោងមុនៗលើដីគោលដៅ និងកាតព្វកិច្ចរបស់តួអង្គទាំងនេះចំពោះសហគមន៍មូលដ្ឋានដែលបានបំពេញ ឬមិនទាន់បានបំពេញ។ កាតព្វកិច្ចទាំងនេះអាចមានបញ្ចូលទម្រង់ផ្សេងៗនៃដំណោះស្រាយសំណងជំងឺចិត្ត បដិទានដី ការផ្លាស់ប្តូរទីលំនៅរបស់សហគមន៍ ឱកាសការងារ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ឬគម្រោងសុខុមាលភាពសង្គម និង សេដ្ឋកិច្ច។

ប្រៀបធៀបលទ្ធផលរកឃើញជាមួយទិន្នន័យទទួលបាន តាមរយៈដំណើរការកំណត់រកអ្នកមានសិទ្ធិ (សូមមើលផ្នែកមុន) ដើម្បីបញ្ចូលលទ្ធផលរកឃើញទាំងនោះ ឬកំណត់រកភាពខុសគ្នា រវាងស្ថានភាពស្របច្បាប់នៃ ដី និង ទំនៀមទម្លាប់នៃសិទ្ធិកាន់កាប់របស់អ្នកមានសិទ្ធិជាប្រពៃណី។

ចែករំលែក និងបញ្ជាក់លទ្ធផលរកឃើញ ដោយរៀបចំការពិគ្រោះយោបល់ជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន។

ប្រភពព័ត៌មានផ្សេងៗទៀតសម្រាប់ជំហាននេះរួមមាន ស្ថាប័នរដ្ឋាភិបាល ទីភ្នាក់ងារអេកិវឡេន៍ អ្នកជំនាញផ្នែកសិទ្ធិកាន់កាប់ដីធ្លី និងអ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ផែនទីផ្លូវការ និងការស្ទង់មតិ សុរិយោដី កំណត់ត្រាពន្ធដីការរៀបចំផែនការប្រើប្រាស់ដី និងផែនទីគ្រប់គ្រងដី ការស្ទង់មតិពីភាពខុសគ្នានៃជាតិសាសន៍និង វប្បធម៌ ការស្រាវជ្រាវជាន់ខ្ពស់ ច្បាប់ និងបទប្បញ្ញត្តិ សាលក្រមតុលាការ កំណត់ត្រាក្រុមហ៊ុន និងឯកសារបោះពុម្ពផ្សាយរបស់អង្គការមិនមែនរដ្ឋាភិបាល។

## ការរៀបចំផែនទីទាមទារយក និងការប្រើប្រាស់ដី[១១]

គោលបំណងនៃជំហាននេះ គឺសំដៅបង្កើតទំហំដី និងធនធានរបស់ប្រជាជនដែលមានស្រាប់ក្នុងតំបន់គម្រោងគោលដៅ ដែលមានសិទ្ធិ និង/ឬការប្រើប្រាស់ដីផ្លូវការ និងក្រៅផ្លូវការ។ ផែនទី គួរគ្របដណ្តប់គ្រប់ផ្នែកនៃតំបន់គម្រោងគោលដៅ ព្រមទាំងតំបន់ដែលនៅជុំវិញ។

តាមរយៈតំណាងរបស់ខ្លួន សហគមន៍មូលដ្ឋាន គួរដើរតួនាទី ដ៏សំខាន់ក្នុងសកម្មភាពរៀបចំផែនទី។ ផែនទីត្រូវរៀបចំឡើង ដោយមានការយល់ដឹងបានពេញលេញ និងកិច្ចព្រមព្រៀង និងស្ថិតក្រោមការគ្រប់គ្រងរបស់សហគមន៍ និងភាគីពាក់ព័ន្ធផ្សេងទៀត។ ត្រូវផ្ទៀងផ្ទាត់ផែនទីទាំងនេះ ជាមួយសហគមន៍ជិតខាង ដើម្បីជៀសវាងភាពតានតឹង ឬការបង្កជម្លោះដីធ្លី។

ការផ្តល់ផែនទីដល់ភាគីទាំងអស់ គឺពិតជាសំខាន់ខ្លាំងណាស់នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការហើយគួរចាត់ទុកផែនទីទាំងនោះ ជាមធ្យោបាយក្នុងការផ្សព្វផ្សាយ និងចែករំលែកព័ត៌មានរវាងក្រុមទទួលបានផល ប្រយោជន៍។ ការរៀបចំផែនទី គួរតែជាដំណើរការដែលដឹកនាំដោយសហគមន៍សម្របសម្រួល និងគាំទ្រដោយក្រុមហ៊ុន និង/ឬរដ្ឋាភិបាល ដែលអាចមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ ត្រូវចាត់ទុកផែនទីជាឧបករណ៍មួយក្នុងដំណើរការនេះ និងមិនមែនជាគោលដៅចុងក្រោយនោះទេ។

## តើកិច្ចការនេះ គួរត្រូវអនុវត្តដោយរបៀបណា?

**កំណត់រកអ្នកមានសិទ្ធិមុនពេលចាប់ផ្តើមគម្រោង៖** ការកំណត់រកជាមុននូវអ្នកប្រើប្រាស់ដី និងអ្នកមានសិទ្ធិ ព្រមទាំងការយល់ដឹងអំពីសិទ្ធិកាន់កាប់ជាប្រពៃណី និងប្រព័ន្ធវប្បធម៌សង្គមមូលដ្ឋាន នឹងអាចជួយរៀបចំផែនទីដីដែលប្រើប្រាស់ ជាលក្ខណៈប្រពៃណីបានកាន់តែប្រសើរ។

11 ការរៀបចំផែនទី៖ សូមមើលគោលការណ៍ណែនាំ ៧.៤ សម្រាប់បទពិសោធន៍តាមមូលដ្ឋានដែលបានចងក្រងជាឯកសារដោយការរៀបចំផែនទីដែលមានការចូលរួម សូមមើល Tanner et al. 2009. Nelson 2007។

**ពិគ្រោះយោបល់ជាមួយសហគមន៍ដូចជា៖**

- លក្ខណៈរបស់គម្រោងលើដី និងធនធាន ដែលកំពុងត្រូវបានរៀបចំជាផែនទីនិងផលវិបាកដែលអាចកើតមានពាក់ព័ន្ធនឹងសិទ្ធិ និងរបរចិញ្ចឹមជីវិត។
- គោលបំណងនៃសកម្មភាពរៀបចំផែនទី និងសារសំខាន់ក្នុងការការពារសិទ្ធិជាប្រពៃណី និងអំណាចធន្ទានុសិទ្ធិ លើការប្រើប្រាស់ដី និងធនធាននាពេលខាងមុខ។
- ប្រការដែលដំណើរការរៀបចំផែនទី នឹងបង្កើតឱ្យមានការទាក់ទងនឹងធនធាន ពេលវេលា ការចូលរួម និងចំណាយ និងអ្នកដែលត្រូវទទួលខុសត្រូវលើការចំណាយទាំងនេះ។
- សហគមន៍មានសិទ្ធិសម្រេចពីបុគ្គល ដែលនឹងចូលរួមក្នុងដំណើរការរៀបចំផែនទី ដោយផ្ទាល់ និងដោយប្រយោល។
- រាល់ដំណោះស្រាយដែលផ្ដល់ឱ្យសម្រាប់ការចំណាយពេលវេលានិងធនធានក្នុងដំណើរការរៀបចំផែនទី
- ភាគីឯករាជ្យដែលមានអ្នកជំនាញ និងបទពិសោធន៍ដើម្បីគាំទ្រសហគមន៍ក្នុងដំណើរការរៀបចំផែនទីរបស់ខ្លួន (ដូចជា អង្គការមិនមែនរដ្ឋាភិបាល)។
- សហគមន៍មានសិទ្ធិលុបចោលការព្រមព្រៀងនៅដំណាក់កាលនេះ ក្នុងករណីដែល គម្រោងមិនអាចបន្តទៅមុខបាន។

**ការព្រមព្រៀងលើការចូលរួម៖** ប្រសិនបើសហគមន៍យល់ព្រមចូលរួម ក្នុងសកម្មភាពរៀបចំផែនទីដោយមានការចូលរួម ពួកគេគួរព្រមព្រៀងចំពោះបុគ្គលមកពីសហគមន៍ដែលនឹងចូលរួម ដោយចំណាយពេលឱ្យបានច្រើនតាមតម្រូវការ ដើម្បីធ្វើសេចក្ដីសម្រេច។ គួរមានការជ្រើសរើសតំណាងទាំងអស់ ដោយសេរី តាមរយៈសហគមន៍ ឬស្ថាប័នរបស់ខ្លួន។ សហគមន៍មានសិទ្ធិសម្រេចជ្រើសរើសបុគ្គលផ្សេងទៀត ដែលគួរចូលរួមក្នុង សកម្មភាពរៀបចំផែនទី។

**ផ្ដល់ការគាំទ្រឯករាជ្យដល់សហគមន៍៖** សហគមន៍ គួរទទួលបានជម្រើសជាច្រើនសម្រាប់ភាគីឯករាជ្យដែល អាចគាំទ្រពួកគេក្នុងការរៀបចំ និងអនុវត្តសកម្មភាពរៀបចំផែនទី។ ភាគីទាំងនោះ អាចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋានដែលស្គាល់តំបន់ និងបច្ចេកទេសចាំបាច់ សម្រាប់ការរៀបចំផែនទីដែលមានការចូលរួម។ សហគមន៍មាន សិទ្ធិជ្រើសរើសអង្គភាព ដែលនឹងគាំទ្រខ្លួន ក្នុងការរៀបចំផែនទី និងក្រោមលក្ខខណ្ឌមួយចំនួន នៅពេលដែលពួកគេទទួលបានព័ត៌មានពេញលេញពីជម្រើសដែលមាន។

**ស្វែងរកតំណាងផ្សេងៗ៖** អ្វីកាន់តែប្រសើរនោះតំណាងរបស់អ្នកមានសិទ្ធិរួមមាន ស្ត្រី យុវជនគ្រួសារក្រីក្រ និងមនុស្សចាស់ គួរចូលរួមក្នុងការរៀបចំផែនទី ដោយសារកិច្ចការនេះ បង្ហាញពីគុណតម្លៃជាច្រើន ការប្រើប្រាស់ និងធនធានដែលត្រូវការដើម្បីបញ្ចូលក្នុងផែនទី។ ឧទាហរណ៍ មនុស្សចាស់ គឺជាប្រភពផ្ដល់ចំណេះដឹងដ៏ច្រើនបំផុតទាក់ទងនឹងទីតាំងប្រវត្តិសាស្ត្រ និងសារសំខាន់នៃវប្បធម៌។ បុរស និងស្ត្រី អាចប្រើប្រាស់ដី និងធនធានផ្សេងទៀតក្នុងលក្ខណៈខុសៗគ្នា។ ផែនទី គួរឆ្លុះបញ្ចាំងរាល់គុណតម្លៃ និងការប្រើប្រាស់ទាំងនេះ។ ខណៈដែលសមាជិកសហគមន៍មិនបានចូលរួមដោយផ្ទាល់ជាមួយក្រុមរៀបចំផែនទី

អ្វីដែលល្អនោះសហគមន៍ត្រូវចូលរួមពិគ្រោះយោបល់ក្នុងដំណើរការដើម្បីប្រាកដថាផែនទីបង្ហាញពីការយល់ដឹងរបស់ពួកគេ និងការប្រើប្រាស់ដី និងធនធានធម្មជាតិ។

**ផ្តល់លទ្ធភាពឱ្យមានការរៀបចំផែនទីចម្រុះ៖** អង្គការគាំទ្រដែលចូលរួមក្នុងការរៀបចំផែនទី គួរចងចាំជានិច្ចថា ក្នុងករណី ដែលមានសហគមន៍ខុសៗគ្នាជាច្រើន សហគមន៍ទាំងនេះ អាចចូលរួមក្នុងសកម្មភាពរៀបចំផែនទីផ្សេងៗពីគ្នា។ ប្រការនេះ អាចកើតមានឡើងប្រសិនបើក្រុមបង្ហាញពីការកាន់កាប់តំបន់ផ្សេងៗ ឬក្នុងករណីដែលពួកគេមានកម្មសិទ្ធិត្រួតស៊ីគ្នា ឬកម្រិតមិនស្មើគ្នានៃសុវត្ថិភាពកម្មសិទ្ធិដីធ្លីតែមួយនោះ។ សហគមន៍នីមួយៗ ត្រូវទទួលបានឱកាសស្មើគ្នា ក្នុងការចូលរួមក្នុងដំណើរការរៀបចំផែនទី ប្រសិនបើពួកគេចង់ចូលរួម។ ក្នុងករណីដែលសហគមន៍ជាច្រើនចែករំលែកសិទ្ធិក្នុងការកាន់កាប់តំបន់ ការបញ្ជាក់ពីសិទ្ធិរបស់ក្រុមតែមួយក្នុងការកាន់កាប់តំបន់អាចបង្កជាជម្លោះ។ សហគមន៍ជិតខាង គួរចូលរួមក្នុងការធ្វើផែនទីតំបន់ជុំវិញ ដើម្បីបង្កើតការព្រមព្រៀងពីការកំណត់ព្រំដែនដី និងការបញ្ជាក់ពីអ្នកមានសិទ្ធិ។

**ប្រៀបធៀប និងបញ្ជាក់ពីព័ត៌មានដែលប្រមូលបាន** ជាមួយប្រភពផ្សេងទៀតក្នុងករណីចាំបាច់។ ប្រៀបធៀបទាំងព័ត៌មានក្នុងសហគមន៍ និងរវាងសហគមន៍ ដើម្បីយល់ដឹងបានកាន់តែប្រសើរពីស្ថានភាពរួមរបស់ដី។ ផែនទីដែលបានរៀបចំ គួរប្រៀបធៀបជាមួយផែនទីដែលមានស្រាប់ ដែលរៀបចំឡើងដោយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនផ្សេងទៀត ដែលបានដំណើរការក្នុង ឬជិតតំបន់គម្រោងគោលដៅ។

**បណ្តុះបណ្តាលពីបច្ចេកវិទ្យាសមស្រប៖** អង្គការគាំទ្រគួរបណ្តុះបណ្តាលសមាជិកក្រុមរៀបចំផែនទីពីការប្រើប្រាស់បច្ចេកវិទ្យាធរណីមាត្រ ដូចជាឧបករណ៍កំណត់កូអរ៍ឌីណេភូមិសាស្ត្រ និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដែលជាមធ្យោបាយមួយចំណាយទាប លឿន និងងាយស្រួលប្រើក្នុងការកំណត់ពីវិសាលភាពនៃសិទ្ធិជាប្រពៃណី និងសិទ្ធិផ្សេងទៀត។ ប្រសិនបើកម្រិតអក្ខរភាពនៅទាបនោះ ត្រូវប្រើប្រាស់ប្រព័ន្ធឧបករណ៍កំណត់កូអរ៍ឌីណេភូមិសាស្ត្រផ្អែកតាមនិមិត្តសញ្ញា ឬរូបភាពដោយមានរូបភាព និងលេខកូដពណ៌ជាជាងការសរសេរជាអត្ថបទ ធ្វើដូច្នេះទើបសមាជិកសហគមន៍មិនមានការលំបាកក្នុងដំណើរការរៀបចំផែនទី។ កម្មវិធីក្នុងទូរសព្ទឆ្លាតវៃ ផ្តល់មធ្យោបាយយ៉ាងច្រើន និងចំណាយតិចក្នុងការកត់ត្រា និងរៀបចំទិន្នន័យផែនទីក្នុងពេលជាមួយគ្នា។ កម្មវិធីទូរសព្ទឆ្លាតវៃមួយចំនួនក៏អាចប្រើប្រាស់ដើម្បីតាមដានពេលវេលា និងខ្សែសង្វាក់សកម្មភាពផ្ទាល់ខ្លួន (ដូចជា ទីតាំង បុគ្គលពាក់ព័ន្ធ គោលបំណងសកម្មភាព លទ្ធផលសកម្មភាព។ល។)។

**ដើរតួជាអ្នកដឹកនាំក្នុងការរៀបចំផែនទី៖** នៅពេលដែលសមាជិកក្រុមយល់ថា ពួកគេមានសមត្ថភាពក្នុងការរៀបចំផែនទីដោយខ្លួនឯង អង្គការគាំទ្រគួរដើរតួជាអ្នកដឹកនាំ ជាជាងអ្នកកំណត់តួនាទីក្នុងដំណើរការរៀបចំផែនទី ដោយទុកលទ្ធភាពឱ្យសហគមន៍ ទីភ្នាក់ងារ និងអ្នកផ្តួចផ្តើមអនុវត្តសកម្មភាពរៀបចំផែនទីដែលពួកគេយល់ថាសមស្រប។ ក្នុងករណីដែលភាពខុសគ្នាតិចតួចនៃអំណាច ងាយនឹងផាត់ចេញក្រុមអ្នកមានសិទ្ធិ ឬអ្នកប្រើប្រាស់ដីមួយចំនួននោះ អង្គការមិនមែនរដ្ឋាភិបាល ឬភាគីអព្យាក្រឹត្យ អាចចូលរួមសម្របសម្រួលដំណើរការនៃការប្រៀបធៀបព័ត៌មានក្នុងក្រុម។

**ចំណាយពេលវេលា និងធនធានឱ្យបានគ្រប់គ្រាន់** សម្រាប់រៀបចំផែនទីដើម្បីឆ្លុះបញ្ចាំងឱ្យបានពេញលេញ ពីគុណតម្លៃ របស់ដីចំពោះសហគមន៍ គ្រួសារ និងបុគ្គលដែលរងផលប៉ះពាល់ខ្លាំង។ ផែនទីនេះនឹងលើកឡើងពីរបៀបធ្វើលទ្ធកម្មដីធ្លីក្នុងលក្ខណៈមួយដែលគោរពសិទ្ធិប្រជាជន និង ធានារបរចិញ្ចឹមជីវិតរបស់ពួកគេ ហើយនឹងចង្អុលបង្ហាញ ពីផលប៉ះពាល់នៃលទ្ធកម្មដីនោះ។

## ចំណុចដែលត្រូវពិចារណា

សហគមន៍មូលដ្ឋាន គួរអាចជ្រើសរើសអ្វីដែលត្រូវ និងមិនត្រូវដាក់បញ្ចូលទៅក្នុងផែនទី។ សហគមន៍គួរជ្រើសរើសផែនទីយោងទៅតាមតម្រូវការ និងគោលបំណងរបស់ខ្លួន។

ព័ត៌មានខាងក្រោមនេះ មានសារសំខាន់ណាស់សម្រាប់យកមកពិចារណាក្នុងដំណើរការរៀបចំផែនទី និងអាចបញ្ចូលទៅក្នុងផែនទីតែម្តង ឬបញ្ចូលទុកជាការរៀបរាប់ដើម្បីបំពេញអត្ថន័យបន្ថែមក្នុងផែនទី៖

- ប្រភេទដី និងធនធានដែលសហគមន៍ប្រើប្រាស់ និងអាស្រ័យលើ និងពាក្យក្នុងតំបន់សម្រាប់ការប្រើប្រាស់ដីខុសៗគ្នា ការស្តារឡើងវិញរបស់ធម្មជាតិ និងធនធាន និងរុក្ខជាតិ។ធនធានទាំងនេះអាចរួមមាន ព្រៃឈើ ទន្លេ តំបន់ដែលបានកាប់ឆ្ការ ភ្នំ និងវាលស្មៅ។ ការប្រើប្រាស់ធនធានអាចរួមមានការបរបាញ់ និងប្រមាញ់ ការនេសាទ ការធ្វើកសិកម្ម ការចិញ្ចឹមសត្វការប្រមូលរុក្ខជាតិឱសថ។ល។
- ការអះអាងពីភាពត្រួតស៊ីគ្នា និង/ឬជម្លោះលើដីពីសហគមន៍ខុសៗគ្នា ឬក្នុងសហគមន៍ និងរបៀបដែល ធនធានទាំងនេះ ត្រូវបានគ្រប់គ្រង និងផ្តល់ឱ្យជាលក្ខណៈប្រពៃណី។
- សកម្មភាពកសិកម្ម ដូចជា កសិកម្មវិលជុំ ការប្រើប្រាស់ដីតាមរដូវ និងការធ្វើចំណាកស្រុករបស់សហគមន៍តាមរដូវកាល។ ឧទាហរណ៍ ដីទំនេរ អាចជាផ្នែកមួយដ៏សំខាន់សម្រាប់របរចិញ្ចឹមជីវិតរបស់សហគមន៍ ខណៈដែលការចិញ្ចឹមសត្វតាមរដូវដែលចំណាយពេលយូរ គឺជាមូលដ្ឋាននៃរបរចិញ្ចឹមជីវិតរបស់ពួកគេ។
- តំបន់ធនធានរួមដូចជា កន្លែងប្រមាញ់ វាលស្មៅចិញ្ចឹមសត្វ ទន្លេ និងព្រៃឈើ។ ជាពិសេសគួររៀបចំផែនទីច្រកទៅកាន់ប្រភពទឹក ព្រមទាំងសហគមន៍ដែលពឹងផ្អែកលើប្រភពទឹកទាំងនោះ។
- ទីកន្លែងដែលមានគុណតម្លៃផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ និងជំនឿចំពោះសហគមន៍មូលដ្ឋាន។កន្លែងនេះមានដូចជា ទីបញ្ចុះសព ព្រៃជំនឿ ភ្នំ និងទន្លេ កន្លែងសម្រាប់ប្រារព្ធពិធី និងកន្លែងបួងសួង។
- គុណតម្លៃតំបន់មួយចំនួនសម្រាប់អ្នកប្រើប្រាស់ដីក្នុងសហគមន៍។ កន្លែងទាំងនេះ មានដូចជាកន្លែងដែលប្រើប្រាស់ដោយស្ត្រី កុមារ អ្នកដាំដុះ ជនចំណាកស្រុកតាមរដូវកាល អ្នកចិញ្ចឹមសត្វ អ្នកប្រមាញ់ និងអ្នកដាក់អន្ទាក់សត្វ សហគមន៍តាមដងស្ទឹងព្រែក។ល។ ត្រូវចាំថា តំបន់មួយចំនួនមិនអាចប្រើប្រាស់រហូតដោយសហគមន៍ឡើយ ប៉ុន្តែនៅតែមានគុណតម្លៃផ្នែកវប្បធម៌ឬសេដ្ឋកិច្ចចំពោះពួកគេ។ ឧទាហរណ៍ ជនជាតិ Maasai នៃតំបន់អាហ្វ្រិកខាងកើតប្រើប្រាស់ដីទំនាបសម្រាប់ចិញ្ចឹមគោក្របី ប៉ុន្តែពួកគេប្រើប្រាស់ព្រៃឈើជាផ្នែកមួយដ៏សំខាន់ សម្រាប់រៀបចំពិធីរបស់ខ្លួន។
- តំបន់ដែលប្រមូលផ្តុំទៅដោយជីវចម្រុះយ៉ាងច្រើន ក្នុងពិភពលោក តំបន់ ឬប្រទេស (ឧទាហរណ៍ព្រៃដើម និងព្រៃបន្ទាប់ ព្រៃកោងកាង ឬតំបន់អភិរក្ស)។

- ការអភិវឌ្ឍរបស់មនុស្ស និងសម្បត្តិលើដី ដែលកំពុងយកមកពិភាក្សា អាចរួមមាន ទីជម្រក ដំណាំ និងដើមឈើ ប្រព័ន្ធធារាសាស្ត្រ ស្ពាន អគារ និង ផ្លូវថ្នល់ បូជនីយដ្ឋាន និង ទីបញ្ចុះសព។
- ព្រំដែន និងព្រំប្រទល់ដី ដែលប្រើប្រាស់ជាលក្ខណៈប្រពៃណីមានដូចជា ព្រំប្រទល់ធម្មជាតិ ដូចជា ច្រាំងទន្លេ រុក្ខជាតិ ដីព្រៃ ឬលក្ខណៈភូមិសាស្ត្រផ្សេងទៀត។
- ព្រំប្រទល់ដី ដែលជាភស្តុតាងបង្ហាញពីការគ្រប់គ្រង តាំងពីដើមរបស់សហគមន៍មូលដ្ឋានរួមមាន ដើមឈើដែលបានដាំដុះ ទីបញ្ចុះសពចាស់ៗ ស្លាកស្នាមភូមិពីមុនៗ។ល។
- តំបន់ដែលផ្តល់សេវាធម្មជាតិមួយចំនួនដូចជា ការការពារទីជម្រាល របបទឹកហូរ អាងរងទឹកភ្លៀង ការសឹករេចរិល និង ការគ្រប់គ្រងភ្លើងឆាបឆេះ។
- ប្រតិបត្តិការរបស់ក្រុមហ៊ុនឯកជន និងតំបន់អភិរក្ស ដែលនៅជាប់តំបន់គម្រោងគោលដៅរួមមាន ការកាប់ព្រៃឈើ ការរុករករ៉ែ ឬសម្បទានព្រៃឈើ ព្រមទាំងព្រៃការពារ និង ឧទ្យានជាតិ។ កត់ត្រាពីចំណុចត្រួតស៊ីគ្នារវាង តំបន់ទាំងនេះ និងតំ បន់គម្រោងគោលដៅ។

## ការបញ្ចប់ដំណើរការរៀបចំផែនទី

**ធានាថា ក្រុមរៀបចំផែនទីពិគ្រោះយោបល់ជាមួយសហគមន៍បានយ៉ាងទូលំទូលាយ** ស្តីពីកំណែផែនទីចុងក្រោយដើម្បីប្រាកដថា រាល់ព័ត៌មានពាក់ព័ន្ធ ត្រូវបានបញ្ចូលក្នុងផែនទីនោះ។ ផែនទីនេះ គួររៀបចំឡើងក្នុងទម្រង់ និងភាសាដែលអាចឱ្យសហគមន៍មូលដ្ឋានយល់បាន។ ការប្រើប្រាស់ដ្យាក្រាម និងគំរូដែលមានបីផ្នែកអាចមានសារសំខាន់ក្នុងការជួយបង្ហាញពីអត្ថន័យរបស់ផែនទី។

**ត្រូវធ្វើយ៉ាងណាឱ្យតួអង្គទាំងអស់យល់ពីផែនទី** និងផ្តល់ផែនទីនោះ ក្នុងទម្រង់ និងភាសាដែលអាចយល់បានដល់ពួកគេ នៅពេលមានការស្នើសុំ។

**បង្កើតកម្មសិទ្ធិផ្លូវការលើផែនទី និងការទទួលបានផែនទី៖** ព្រមព្រៀងជាមួយសហគមន៍ក្នុងការបង្កើតកម្មសិទ្ធិផ្លូវការលើផែនទីដោយសហគមន៍ដែលបានរៀបចំឡើងតាមរយៈឯកសារដែលបានចុះហត្ថលេខា ឬទម្រង់បែបបទផ្សេងទៀត ដែលសហគមន៍អាចទទួលយកបាន។ ព្រមព្រៀងលើនីតិវិធី ក្នុងការផ្តល់ផែនទីដល់ភាគីផ្សេងទៀត។

**រៀបចំការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមបន្ថែមទៀត** និងការវាយតម្លៃលើគុណតម្លៃនៃការអភិរក្សកម្រិតខ្ពស់ ក្នុងករណីចាំបាច់ ឬមានការណែនាំ។ ដំណើរការនេះ គួរស្រដៀងនឹងអ្វីដែលបានរៀបរាប់ខាងលើដោយមានការចូលរួមយ៉ាងពេញលេញនិងប្រកបដោយប្រសិទ្ធភាពរបស់សហគមន៍ ការពិចារណាពីការប្រើប្រាស់ដី និងធនធានធម្មជាតិជាលក្ខណៈប្រពៃណី និងក្នុងទម្រង់និងភាសាដែលអាចឱ្យពួកគេយល់បាន។

## ការកំណត់រកស្ថាប័ន និងតំណាងដែលត្រូវធ្វើសេចក្តីសម្រេច

គោលបំណងនៃដំណាក់កាលនេះ គឺសំដៅធានាថា អ្នកមានសិទ្ធិទទួលបានការតំណាងតាមរយៈបុគ្គល និងស្ថាប័នពីជម្រើសផ្ទាល់ខ្លួន និងអ្នកដែលទទួលខុសត្រូវ និងភាពស្របច្បាប់ចំពោះបុគ្គល ដែលពួកគេតំណាងដោយមានការពិគ្រោះយោបល់ការចរចាការធ្វើសេចក្តីសម្រេចនិងការស្វែងរកការព្រមព្រៀង។

ការតំណាងនេះជួយបញ្ចៀសការយល់ខុស និងកិច្ចព្រមព្រៀងដែលមិនបានឆ្លុះបញ្ចាំង ពីទស្សនៈរបស់សហគមន៍ ដែលនឹងអាចបង្កឱ្យមានជាជម្លោះ។ រដ្ឋាភិបាល និងក្រុមហ៊ុនត្រូវទទួលបានព័ត៌មាន អំពីតំណាងសហគមន៍ដែលខ្លួននឹងទាក់ទងជាមួយក្នុងការជានាបានការចរចា។

សហគមន៍មូលដ្ឋានអាចស្នើសុំ និងទទួលបានអត្ថប្រយោជន៍ពីការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ប្រឹក្សាឯករាជ្យក្នុងការសម្រេចជ្រើសរើសអង្គភាព ឬបុគ្គលដែលនឹងតំណាងឱ្យពួកគេបានពេញលេញ ដោយមិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាល និងក្រុមហ៊ុន។ ការពិគ្រោះយោបល់ ក្នុងការជ្រើសរើសតំណាងគួរមានការចូលរួមឱ្យបានទូលំទូលាយ និងបើកចំហសម្រាប់សមាជិកសហគមន៍ទាំងអស់។ ការពិគ្រោះយោបល់ គួរធ្វើឡើងក្នុងដែនដីរបស់សហគមន៍ ដែលពិគ្រោះយោបល់ ដែលខ្លួនយល់ថាមានសុវត្ថិភាព និងអាចបញ្ចេញមតិយោបល់ច្រើនជាងកន្លែង ដែលពួកគេមិនធ្លាប់ស្គាល់ និងកន្លែងដែលពួកគេទទួលបានជំនួយពីសហគមន៍ក្នុងការពិភាក្សាអំពីបញ្ហា។

### តើកិច្ចការនេះគួរត្រូវអនុវត្តដោយរបៀបណា?

**ចុះទៅសហគមន៍៖** ត្រូវពន្យល់សហគមន៍ឱ្យបានច្បាស់អំពីបុគ្គលដែលអ្នកតំណាងលក្ខណៈនៃគម្រោងអភិវឌ្ឍន៍ ដែលបានស្នើឡើង គោលបំណងរបស់អ្នកបង្កើតគម្រោងក្នុងការគោរពការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត ពាក់ព័ន្ធនឹងសហគមន៍ និងរយៈពេល នៃជំហានដែលអាចចាប់ផ្តើមចេញពីការពិគ្រោះយោបល់រហូតដល់ការចរចាឱ្យទទួលបានកិច្ចព្រមព្រៀង ប្រសិនបើ សហគមន៍មានគោលបំណងដូច្នោះ។ សហគមន៍មានសិទ្ធិលុបចោលការព្រមព្រៀង ដើម្បីបន្តពិភាក្សាពីគម្រោង ទោះបីជាស្ថិតក្នុងដំណាក់កាលដំបូងក៏ដោយ ហើយត្រូវគោរពការសម្រេចចិត្តនេះ។

**រៀបចំការពិគ្រោះយោបល់៖** ប្រសិនបើសហគមន៍សម្រេចពិចារណាពីគម្រោង ត្រូវយល់ព្រមជាមួយពួកគេសម្រាប់ពេលវេលាមួយសមស្របបំផុត និងទីកន្លែងសម្រាប់ការពិគ្រោះយោបល់។ ផ្តល់ពេលវេលាឱ្យបានច្រើនដើម្បីធ្វើការពិភាក្សា និងការចរចាជាមួយសហគមន៍ ដើម្បីអាចឱ្យពួកគេសម្រេចជ្រើសរើសអ្នកដែលតំណាងឱ្យពួកគេ ក្នុងការជានាឱ្យបាននូវដំណាក់កាលនានាក្នុងដំណើរការ។

**ផ្សព្វផ្សាយពីសិទ្ធិ៖** ត្រូវបង្ហាញសហគមន៍ឱ្យបានច្បាស់ថា៖

- សហគមន៍មានសិទ្ធិទទួលបានតំណាងពីស្ថាប័ន និងបុគ្គលដែលពួកគេជ្រើសរើសដោយខ្លួនឯង និងអាចសម្រេចលើចំនួនអប្បបរមានៃតំណាង ដែលចាំបាច់សម្រាប់ធ្វើការសម្រេចចិត្ត។ ការតំណាង អាចធ្វើឡើងតាមរយៈស្ថាប័នជាប្រពៃណី ប្រធាន ឬមនុស្សចាស់ សហករណ៍ ស្ថាប័នគ្រប់គ្រងមូលដ្ឋាន ស្ថាប័ន ឬតំណាងសាសនា ស្ថាប័នថ្មី ឬស្ថាប័នកូនកាត់ អង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន ប្រព័ន្ធផ្លាស់ប្តូរតំណាង ឬការរួមបញ្ចូលគ្នានៃចំណុចខាងលើ។
- សហគមន៍មានសិទ្ធិទទួលបានជំនួយសម្របសម្រួលដោយឯករាជ្យ ក្នុងករណីចាំបាច់ និងពេលមានការស្នើសុំ។
- សហគមន៍មានសិទ្ធិបង្កើតអង្គភាពតំណាងដែលខ្លួនយល់ថា នឹងជួយសម្របសម្រួលសកម្មភាពវប្បធម៌របស់ពួកគេបានយ៉ាងល្អ និងតម្រូវការនៃការធ្វើសេចក្តីសម្រេច។

- សហគមន៍អាចស្នើសុំកន្លែង ដែលខ្លួនជ្រើសរើស ដោយមានតុល្យភាពអំណាចក្នុងសហគមន៍ ប្រសិនបើពួកគេយល់ថា មានហានិភ័យនៃការមិនរាប់បញ្ចូលក្នុងការធ្វើសេចក្តីសម្រេច ឬមានការបំពានលើអំណាច។

**ពិភាក្សាពីតំណាង និងការទទួលខុសត្រូវ៖** អង្គការមិនមែនរដ្ឋាភិបាល អាចជួយរៀបចំសហគមន៍មូលដ្ឋានឱ្យជ្រើសរើសតំណាង ដោយបញ្ជាក់ពីការទទួលខុសត្រូវរបស់តំណាង (ដូចជា ការចរចាពីជម្រើសសម្រាប់ប្រជាជនទូទៅ ជាជាងការធ្វើសេចក្តីសម្រេចដោយឯកតោភាគី) និងហានិភ័យដែលអាចកើតមានសម្រាប់តំណាង (ដូចជា ឥទ្ធិពល និង/ឬសម្ពាធពីភាគីផ្សេងទៀត អត្ថប្រយោជន៍បុគ្គល ដែលសំខាន់ជាងអត្ថប្រយោជន៍ក្រុម ការជ្រើសតាំងដោយខ្លួនឯង ឬការខកខានមិនបានចែករំលែកព័ត៌មានជាមួយសហគមន៍ឱ្យបានទូលំទូលាយ ដោយសារដំណើរការចរចាកាន់តែមានលក្ខណៈបច្ចេកទេស និងជំនាញ)។ អង្គការមិនមែនរដ្ឋាភិបាល ត្រូវការការពារដើម្បីបញ្ចៀសការប្រាសចាក ពីការទទួលខុសត្រូវដែលបានព្រមព្រៀង និងការចូលរួម ឬការជះឥទ្ធិពលលើដំណើរការធ្វើសេចក្តីសម្រេចរបស់សហគមន៍មូលដ្ឋានដោយមិនសមស្រប។

**ជំរុញឱ្យមានការផ្តល់ធាតុចូលយ៉ាងទូលំទូលាយ៖** ខណៈដែលគំរូតំណាងដែលបានជ្រើសរើសមិនបានរាប់បញ្ចូលស្ត្រី យុវជន ប្រជាជនក្រីក្រ ឬក្រុមបាត់បង់ឱកាសផ្សេងទៀត ស្ថាប័នរដ្ឋាភិបាល ឬអ្នកបង្កើតគម្រោងអាចស្នើ និងជំរុញឱ្យមានការចូលរួមយ៉ាងទូលំទូលាយ ពីសហគមន៍មុនដំណាក់កាលនីមួយៗនៃការចរចា និងការពិគ្រោះយោបល់។ ការពិគ្រោះយោបល់ដាច់ដោយឡែក អាចត្រូវបានស្នើឡើងដោយក្រុមមួយចំនួន (ដូចជា ស្ត្រី យុវជន ឬជនចំណាកស្រុក) ប៉ុន្តែ មិនត្រូវសន្មតថា ក្រុមទាំងនេះ ឬទស្សនៈរបស់ក្រុមទាំងនេះ មានលក្ខណៈដូចគ្នានោះឡើយ[១២]។

**ផ្តល់លទ្ធភាពឱ្យមានតំណាងខុសៗគ្នា៖** ត្រូវចាំថា សហគមន៍ផ្សេងៗគ្នា ឬក្រុមក្នុងសហគមន៍ អាចជ្រើសរើសអង្គភាពផ្សេងៗ ធ្វើជាតំណាង។ ក្នុងករណីនេះ ប្រការសំខាន់ ត្រូវពិចារណាពីការបង្កើតគណៈកម្មាធិការតំណាងសហគមន៍ ដែលនឹងជួបប្រជុំទៅតាមដំណាក់កាលដើម្បីព្រមព្រៀងលើបញ្ហាជារួម ដែលប៉ះពាល់លើអ្នកមានសិទ្ធិ។ ក្នុងករណីមានចម្ងល់ ឬខ្លឹមសារមិនច្បាស់លាស់ទាក់ទងនឹងបុគ្គល ដែលផ្តល់ការព្រមព្រៀង អ្វីដែលល្អបំផុតត្រូវបញ្ចូលភាគីឱ្យបានច្រើន ជាជាងការជ្រើសរើសតិចតួចដោយឯកតោភាគី។

**ការបង្កើតតំណាងផ្លូវការ៖** ព្រមព្រៀងជាមួយសហគមន៍ ក្នុងការធ្វើឱ្យមានលក្ខណៈផ្លូវការនូវការសម្រេចចិត្តរបស់សហគមន៍ស្តីពីការជ្រើសរើសបុគ្គល ឬអង្គភាពតំណាង ក្នុងទម្រង់មួយដែលមានការព្រមព្រៀងពីភាគីទាំងអស់។ ដំណើរការនេះ អាចធ្វើឡើងជាឯកសារជាលាយលក្ខណ៍អក្សរ ការប្រារព្ធពិធីសាសនា កិច្ចសន្យាដែលចុះហត្ថលេខាដោយភាគីទាំងអស់ ដោយមានវត្តមានសាក្សីដែលឯករាជ្យ ឬការរួមបញ្ចូលចំណុចខាងលើ។ ក្នុងករណីទាំងអស់ សហគមន៍មានសិទ្ធិរៀបចំកិច្ចព្រមព្រៀង ឱ្យក្លាយជាកិច្ចព្រមព្រៀងដែលចងភ្ជាប់កាតព្វកិច្ចទៅតាមការអនុវត្តជាប្រពៃណី ទៅតាមឆន្ទៈរបស់ពួកគេ។

---

12 ភាពខុសៗគ្នានៃទស្សនៈពីអ្នកមានសិទ្ធិខុសៗគ្នា៖ សូមមើលគោលការណ៍ណែនាំក្នុង ៣.3 និងឯកសារយោងសម្រាប់ការយល់ដឹងពីយេនឌ័រក្នុងលេខយោងទី ៥។

### កិច្ចព្រមព្រៀងត្រូវបញ្ជាក់ចំណុចដូចខាងក្រោម៖

- បុគ្គលដែលត្រូវបានជ្រើសរើសជាតំណាង
- តួនាទីរបស់បុគ្គលទាំងនោះក្នុងសហគមន៍
- របៀបជ្រើសរើសបុគ្គលទាំងនោះ
- ការទទួលខុសត្រូវ និងតួនាទីក្នុងនាមជាតំណាង
- របៀបទាក់ទងជាមួយបុគ្គលទាំងនោះ
- មធ្យោបាយដ៏ល្អបំផុត ក្នុងការធ្វើទំនាក់ទំនងជាមួយតំណាង (ភាសានិយាយ កម្រិតអក្ខរកម្ម សីលធម៌ដែលត្រូវអនុវត្តតាម ក្នុងករណីពួកគាត់ជាមនុស្សចាស់ ឬតំណាងសាសនា)។
- របៀបដែលតំណាងនឹងធានាបានថា ពួកគេតំណាងឱ្យសហគមន៍ជារួម ដោយពិចារណាពីក្រុមបាត់បង់ឱកាសដូចជា ស្ត្រី យុវជន ប្រជាជនក្រីក្រ តាមតំបន់ជនបទ ប្រជាជនគ្មានដី និងជនចំណាកស្រុក។
- ព្រំដែននៃការធ្វើសេចក្តីសម្រេចរបស់តំណាង និងក្រោមលក្ខខណ្ឌដែលតំណាងនោះ ត្រូវដាក់បញ្ចូលជម្រើសចរចាក្នុងវេទិកាសហគមន៍ ដើម្បីធ្វើសេចក្តីសម្រេច។
- របៀបចែករំលែកកិច្ចសន្ទនាជាមួយអង្គភាពសំខាន់ៗ និង ព័ត៌មានដែលប្រមូលបានដើម្បីធ្វើសេចក្តីសម្រេច។
- កិច្ចព្រមព្រៀងផ្នែកភស្តុការសម្រាប់ការពិគ្រោះយោបល់ចម្រុះភាគី (ពេលវេលា ទីកន្លែងភាពញឹកញាប់ អ្នកចូលរួម ចំណាយបន្ថែម និងមធ្យោបាយធ្វើដំណើរ)។
- ដំណើរការដែលសហគមន៍ ឬតួអង្គផ្សេងទៀតអាចចូលរួម ប្រសិនបើតំណាងបង្ហាញពីកង្វះសមត្ថភាពក្នុងការអនុវត្តតួនាទីរបស់ខ្លួន។
- បញ្ហាដែលនឹងកើតមានឡើង ប្រសិនបើតំណាងខកខានមិនបានបំពេញតាមតួនាទីរបស់ខ្លួន ឬក្នុងករណីដែលសហគមន៍សម្រេចផ្លាស់ប្តូរពួកគេ។

**ចងក្រងជាឯកសារនូវដំណើរការ និងលទ្ធផលនៃការពិគ្រោះយោបល់** និងផ្តល់ឯកសារទាំងនេះដលភាគីពាក់ព័ន្ធទាំងអស់។

**ធានាភាពស្របច្បាប់៖** ក្នុងករណីមានចម្ងល់ទាក់ទងនឹងភាពស្របច្បាប់និងអត្ថប្រយោជន៍របស់តំណាងដែលបានជ្រើសរើស ដូចដែលបានលើកឡើងដោយសហគមន៍ ឬភាគីផ្សេងទៀត គួរមានការរៀបចំការពិគ្រោះយោបល់ ដោយឥតព្រាងទុកបន្ថែមទៀត ជាមួយសំណាកគំរូរបស់សហគមន៍។ ប្រសើរបំផុត ការពិគ្រោះយោបល់ទាំងនេះ គួរធ្វើឡើងដោយសម្ងាត់ និងឆ្លុះបញ្ចាំងពីទស្សនៈរបស់ស្ត្រី មនុស្សចាស់ និងយុវជន។

### ការរៀបចំការពិគ្រោះយោបល់ម្តងហើយម្តងទៀត និងការចែករំលែកព័ត៌មាន

គោលបំណងនៃការពិគ្រោះយោបល់ម្តងហើយម្តងទៀត គឺសំដៅចែករំលែករាល់ព័ត៌មានពាក់ព័ន្ធទាំងអស់របស់គម្រោងអភិវឌ្ឍន៍ជាមួយតួអង្គពាក់ព័ន្ធ និងអ្នកមានសិទ្ធិក្នុងដំណើរការចង្អុលប្រាប់ទិសចម្រុះ។ តាមរយៈព័ត៌មាននេះ សហគមន៍ទទួលបានគោលជំហរយ៉ាងប្រសើរ ក្នុងការសម្រេចថាតើគួរបន្ត ឬបញ្ឈប់គម្រោង និងពិភាក្សាពីការកែប្រែចាំបាច់ដើម្បីធានាបានការព្រមព្រៀង។

**គោលការណ៍ណែនាំស្ដីពីលទ្ធភាពទទួលបានព័ត៌មាន និងការមិនរើសអើង**

*ប្រភព ៖* FAO ២០១២

**១២.១១**ភាគីជាប់កិច្ចសន្យាគួរផ្តល់ព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីធានាថា រាល់បុគ្គលពាក់ព័ន្ធចូលរួម និងទទួលបានព័ត៌មានត្រឹមត្រូវនៅក្នុងការចរចា និងគួរធានាថាកិច្ចព្រមព្រៀងត្រូវបានចងក្រងជាឯកសារ និងមានការយល់ដឹងពីគ្រប់បុគ្គលដែលរងផលប៉ះពាល់។ដំណើរការចរចាគួរធ្វើឡើងដោយមិនមានការរើសអើង និងយកចិត្តទុកដាក់លើយេនឌ័រ។

ការពិគ្រោះយោបល់ ចាប់ផ្តើមដោយការកំណត់រកអ្នកមានសិទ្ធិ និងអ្នកប្រើប្រាស់ដី និងគួររៀបចំឡើងក្នុងជំហាននីមួយៗ។ ការពិគ្រោះយោបល់ គួររៀបចំនៅទីតាំងមួយ និងឱ្យបានញឹកញាប់សម្រាប់ភាគីទាំងអស់ដើម្បីបង្កភាពងាយស្រួល និងទំនុកចិត្តក្នុងការចូលរួមយ៉ាងសកម្ម ពេញលេញ និងដោយសេរី។ គួរមានការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយប្រកបដោយតម្លាភាពដោយសេរីក្នុងពេលវេលាត្រឹមត្រូវមុនពេលចាប់ផ្តើមសកម្មភាព ឬការធ្វើសេចក្តីសម្រេច ពោលគឺ ក្នុងដំណើរការចែករំលែកព័ត៌មានដោយមិនមានការរើសអើងដែលប្រើប្រាស់ទម្រង់ និងភាសាសមស្រប និងអាចទទួលបាន[១៣] ។ត្រូវចាំថានៅក្នុងដំណើរការនេះ ក្រុមហ៊ុន និងរដ្ឋាភិបាល គួរគោរពសិទ្ធិរបស់សហគមន៍ក្នុងការផ្តល់ ឬលុបចោលការព្រមព្រៀងក្នុងនាមជាភ្នាក់ងារសកម្មក្នុងដំណើរការ។

## តើកិច្ចការនេះគួរត្រូវអនុវត្តដោយរបៀបណា?

### *ដំណើរការ*

**រៀបចំកិច្ចប្រជុំក្នុងមូលដ្ឋាន៖** ព្រមព្រៀងជាមួយសហគមន៍ជាមុនទាក់ទងនឹងពេលវេលា អំឡុងពេល ទីកន្លែង អ្នកចូលរួម និងគោលបំណង នៃការពិគ្រោះយោបល់ជាបន្តបន្ទាប់នីមួយៗ។អ្វីដែលប្រសើរនោះ ការពិគ្រោះយោបល់ គួររៀបចំឡើងក្នុងដែនដីរបស់សហគមន៍ដែលពិគ្រោះយោបល់។ លទ្ធភាពទទួលបានគឺជាចំណុចស្នូលសម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាពនៅគ្រប់ជំហានទាំងអស់នៃដំណើរការ ។ការពិគ្រោះយោបល់ក្នុងទីក្រុងឆ្ងាយៗ អាចចំណាយអស់ច្រើន និងមិនសមស្របសម្រាប់ឱ្យសហគមន៍មូលដ្ឋានចូលរួមបានពេញលេញ និងដោយសម្ងាត់ឡើយ។ សហគមន៍អាចយល់ថា តំណាងរបស់ខ្លួនអាចបញ្ចេញទស្សនៈរបស់ខ្លួនបានយ៉ាងត្រឹមត្រូវ ប្រសិនបើតំណាងមិនបានស្ថិតនៅឱ្យឆ្ងាយពីអង្គភាពសំខាន់របស់ខ្លួនទេនោះ។

**រៀបចំការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមដោយមានការចូលរួម** និងចែករំលែកលទ្ធផលរកឃើញជាមួយសហគមន៍រងផលប៉ះពាល់។ នៅពេលអនុវត្តដោយមានការយល់ដឹង និងមានការចូលរួមពីសហគមន៍រងផលប៉ះពាល់ និងការគោរពសិទ្ធិ ការវាយតម្លៃនេះ អាចផ្តល់ព័ត៌មានសំខាន់ៗ។ ការវាយតម្លៃនេះ ប្រាប់សហគមន៍ពីចំណាយ និងអត្ថប្រយោជន៍នៃផែនការអភិវឌ្ឍ ផលប៉ះពាល់លើបរចិញ្ចឹមជីវិត និងវិធានការដែលត្រូវអនុវត្តដើម្បីបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់ឥតព្រាងទុក។ការវាយតមផលប៉ះពាល់ក៏ផ្តល់អត្ថប្រយោជន៍ក្នុងការផ្តល់ទិន្នន័យគោល ធៀបនឹងការវាយតម្លៃការអនុវត្ត និងអនុលោមតាមនាពេលបន្ទាប់។ អនុសញ្ញាស្តីពីជីវចម្រុះបានរៀបចំគោលការណ៍ណែនាំលម្អិតសម្រាប់អនុវត្តការវាយតម្លៃផលប៉ះពាល់លើដីរបស់ជនជាតិដើមភាគតិច (CBD ឆ្នាំ ២០០៤)។

**ការផ្សព្វផ្សាយព័ត៌មាន៖** ផ្សព្វផ្សាយរាល់ព័ត៌មានក្នុងគ្រប់ទម្រង់ និងភាសាដែលអាចយល់បាន និងពាក់ព័ន្ធសម្រាប់គ្រប់ភាគីពាក់ព័ន្ធ។ ព័ត៌មានទាំងនេះ អាចរួមមាន ប្រព័ន្ធព័ត៌មានជាលាយលក្ខណ៍អក្សរ និងមានការកត់ត្រា ផ្សាក្រាម រូបភាព វីដេអូ ការសម្តែងតួ។ល។ គំរូជាប្រពៃណីនៃទំនាក់ទំនង និងបទដ្ឋាននៃទំនាក់ទំនងអាចមានភាពខុសគ្នាក្នុងសហគមន៍ជាច្រើន និងគួរមានការគោរព។

13 ការមិនរើសអើង ៖ សូមមើលគោលការណ៍ណែនាំក្នុង 3B.1.2; 4.4; 4.6; 4.7; 5.3. 6.3; 9.10; 11.3; 12.11; 17.3; 21.3; 21.6; 25.3; 25.5; 25.7។ ការពិគ្រោះយោបល់ និងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេច ៖ សូមមើលគោលការណ៍ណែនាំក្នុង 3B.6; 6.4; 8.6; 8.9; 9.2; 9.7; 9.9; 9.12; 10.3; 11.2; 12.5; 15.7; 12.9–12.11, 16.2។ តម្លាភាព និងគណនេយ្យភាព ៖ សូមមើលគោលការណ៍ណែនាំក្នុង 3B.8; 3B.9; 5.8; 6.9; 8.6; 8.9; 10.5; 11.1–11.4; 12.3; 12.5; 12.13; 16.2។

**ជំរុញឱ្យមានការចូលរួមពីអ្នកសម្របសម្រួល** ក្នុងការពិគ្រោះយោបល់ ប្រសើរបំផុតគឺ អ្នកសម្របសម្រួលដែលឯករាជ្យដើម្បីធានាថា ភាគីទាំងអស់មានសិទ្ធិស្មើគ្នាក្នុងការបញ្ចេញទស្សនៈ។ អ្នកសម្របសម្រួលអាចជាតំណាងអង្គការមិនមែនរដ្ឋាភិបាល ឬភាគីទីបី ដែលសហគមន៍ទទួលយក។

**ជួយសហគមន៍បង្កើតផែនការសកម្មភាព៖** អង្គការមិនមែនរដ្ឋាភិបាល ឬអង្គការគាំទ្រផ្សេងទៀត ដែលមានជំនួយពីការការពារពាក់ព័ន្ធ និងការអនុវត្ត អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសហគមន៍មូលដ្ឋានបង្កើតផែនការសកម្មភាព ដែលបង្ហាញពីតម្រូវការជាក់លាក់ បញ្ហាកង្វល់ និងតម្រូវការ។ កិច្ចការនេះអាចបង្កើតការព្រមព្រៀងក្នុងសហគមន៍មុនពេលចរចា។ ការរៀបចំផែនការជាមុនមានការពាក់ព័ន្ធជាពិសេស នៅពេលដែល សហគមន៍មិនទាន់យល់ដឹងពីប្រភេទនៃគម្រោងអភិវឌ្ឍដែលបានស្នើឡើង ឬតម្រូវការការគាំទ្របន្ថែមដើម្បីរៀបចំ និងតំណាងខ្លួនឯងក្នុងករណីមានការផ្លាស់ប្តូរផែតព្រាងទុកដែលអាចប៉ះពាល់ដល់ពួកគេ។

**ជំរុញឱ្យសហគមន៍ជាច្រើនចូលរួមក្នុងការពិគ្រោះយោបល់ឱ្យបានច្រើនតាមដែលអាចធ្វើបាន៖** ត្រូវចងចាំថាសហគមន៍ខុសៗគ្នា និងក្រុមខុសៗគ្នា ក្នុងសហគមន៍អាចមានទស្សនៈ និងតម្រូវការខុសៗគ្នា។ ត្រូវចាំថា សមាជិកសហគមន៍មួយចំនួន ដែលរស់នៅក្រៅភូមិក្នុងមូលដ្ឋាន ក៏ចង់បញ្ចេញមតិយោបល់ក្នុងកិច្ចពិភាក្សាផងដែរ ហើយសហគមន៍គួរ ស្វះស្វែងផ្តល់ព័ត៌មានដល់ពួកគេពីការចរចា និងប្រមូលយោបល់ត្រឡប់លើសេចក្តីសម្រេចដែលកំពុងធ្វើឡើង។

**ចំណាយពេលវេលា និងធនធានចាំបាច់** ដើម្បីផ្សព្វផ្សាយព័ត៌មានឱ្យបានច្បាស់លាស់ ត្រឹមត្រូវ និងពេញលេញ លើកឡើងនូវសំណួរ និងបញ្ហាកង្វល់ និងបញ្ជាក់ ឬពិនិត្យឡើងវិញលើបញ្ហាក្នុងករណីចាំបាច់។ ព័ត៌មានភាគច្រើន ដែលចែករំលែក គឺជាព័ត៌មានថ្មីសម្រាប់ភាគីផ្សេងៗដែលពាក់ព័ន្ធ ហើយពេលវេលា គឺមានសារសំខាន់សម្រាប់ពួកគេក្នុងការពិចារណា និងឆ្លើយតបឱ្យបានត្រឹមត្រូវចំពោះព័ត៌មាននេះ។ ផ្តល់ពេលវេលាសម្រាកឱ្យបាន គ្រប់គ្រាន់ ក្នុងការពិគ្រោះយោបល់ ដើម្បីឱ្យភាគីពិនិត្យឡើងវិញ វិភាគនិងពិភាក្សាពីព័ត៌មានដែលទទួលបាន និងសាកសួរជាសំណួរ ឬ ធ្វើការបញ្ជាក់។

ត្រូវបង្ហាញឱ្យច្បាស់ថា អ្នកគ្រប់គ្នាដែលពាក់ព័ន្ធគឺជាអ្នករៀនសូត្រ និងអ្នកចែករំលែកព័ត៌មានដោយស្មើភាព ប៉ុន្តែការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត គឺជាការលើកឡើងពីសិទ្ធិទូលំទូលាយ របស់សហគមន៍ និងរដ្ឋហើយក្រុមហ៊ុនមានការទទួលខុសត្រូវក្នុងការគោរពតាមសិទ្ធិមនុស្ស រួមទាំងតាមរយៈការគោរពតាមការព្រមព្រៀង ជាមុនដោយស្ម័គ្រចិត្ត។

**បង្ហាញពីសិទ្ធិក្នុងការនិយាយថា "ទេ" ឬ "យើងមិនដឹង"៖** នៅពេលចាប់ផ្តើម សហគមន៍ គួរទទួលបានព័ត៌មានគ្រប់គ្រាន់ថា ពួកគេមិនមែនចាំបាច់ ត្រូវធ្វើសេចក្តីសម្រេចនោះឡើយ ប្រសិនបើពួកគេមិនទាន់ប្រាកដទាំងស្រុង។ គួរប្រាប់ទៅសហគមន៍ថា ពួកគេអាចទទួលយក បដិសេធ ទទួលយកផ្នែកណាមួយ បដិសេធផ្នែកណាមួយ ឬសម្រេចមិនផ្តល់មតិយោបល់លើសំណើ និងអាចស្នើសុំទុកពេលពិចារណាឱ្យបានច្រើនតាមដែលពួកគេត្រូវការដើម្បីជ្រើសរើសអ្វី ដែលល្អបំផុតសម្រាប់ខ្លួន។ ត្រូវពន្យារពេលពិគ្រោះយោបល់ប្រសិនបើក្រុមទទួលបានអត្ថ-ប្រយោជន៍យល់ថា ពួកគេត្រូវការពេលវេលា ឬព័ត៌មានបន្ថែមពីប្រភពផ្សេងទៀត ដើម្បីធ្វើសេចក្តីសម្រេច។

ត្រូវបង្ហាញច្បាស់ពីបុគ្គលក្នុងភាគីនីមួយៗ ដែលអាចទាក់ទងក្នុងករណីមានចម្ងល់ ដើម្បីជានាទំនាក់ទំនងយ៉ាងរលូន។ គួរអង្គម្នាក់ៗគួរស្គាល់បុគ្គលដែលត្រូវទាក់ទង ពេលមានបញ្ហាកង្វល់ និងស្នើសុំព័ត៌មាន និងបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសេចក្ដីសម្រេច។

**ការពារសេរីភាព និងសុវត្ថិភាព៖** រាល់ការពិគ្រោះយោបល់ និងការសម្រេចចិត្តមិនត្រូវមានលក្ខណៈបង្ខិតបង្ខំឡើយ ប៉ុន្តែ ត្រូវធ្វើដោយបើកចំហ មានតម្លាភាព និងបញ្ចៀសឱ្យបាននូវទម្រង់ណាមួយនៃការគ្រប់គ្រង ការស៊ីសំណូក ការគំរាមកំហែង ឬការបង្ខិតបង្ខំ។ អ្នកចូលរួមទាំងអស់ គួរទទួលបានអនាមិកភាព ដើម្បីការពារអ្នកផ្ដល់ព័ត៌មាន ក្នុងករណីចាំបាច់។ សហគមន៍មានសិទ្ធិទទួលបានភាពឯកជនក្នុងការចរចា និងការពិគ្រោះយោបល់ ក្នុងករណី ដែលពួកគេយល់ថា វត្តមានរបស់រដ្ឋាភិបាល ឬក្រុមហ៊ុនបានរិតត្បិតលទ្ធភាពរបស់ពួកគេក្នុងការពិភាក្សា និង សម្រេចចិត្តដោយសេរី។

**ជួលអ្នកបកប្រែផ្ទាល់មាត់ដែលមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់** ដើម្បីជានាថា ព័ត៌មានបានបង្ហាញដល់ភាគីទាំងអស់យ៉ាងត្រឹមត្រូវ និងយ៉ាងពេញលេញ ដោយមានប្រើប្រាស់ភាសាចម្រុះ។

### *ខ្លឹមសារ*

ប្រើប្រាស់ផែនទី ដែលបានបង្កើតក្នុងដំណើរការរៀបចំផែនទី ដែលមានការចូលរួម។ ផែនទីទាំងនេះគួរប្រើ ប្រាស់សម្រាប់ជាឯកសារយោងក្នុងអំឡុងពេលចរចា។

**ផ្ដល់លទ្ធភាពឱ្យមានភាពបត់បែនលើខ្លឹមសារ** នៃដំណើរការពិគ្រោះយោបល់ និងត្រូវប្រាកដថា របៀបវារៈផ្ដោតលើចំណុចសំខាន់ៗ ដែលភាគីទាំងអស់បានលើកឡើង។

**កិច្ចប្រជុំគួរផ្ដោតលើបញ្ហាដូចខាងក្រោមនេះ៖** ក្រុមហ៊ុន គួរផ្ដល់ព័ត៌មានមួយចំនួន ប៉ុន្តែមិនកំណត់ត្រឹមព័ត៌មានដូចខាងក្រោម៖

- ឈ្មោះក្រុមហ៊ុន ប្រវត្តិ និង ប្រវត្តិប្រតិបត្តិការ
- អង្គការលេខ និង ឋានានុក្រម
- ទីតាំងទីស្នាក់ការ និងប្រតិបត្តិការ
- ចំនួនបុគ្គលិក និងគម្រោងដែលត្រូវដំណើរការ
- លក្ខណៈនៃដំណើរការគម្រោង
- វិនិយោគិនសំខាន់ៗក្នុងក្រុមហ៊ុន (រួមមានស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ)
- គោលនយោបាយស្ដីពីការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត របស់ក្រុមហ៊ុនដែលមានស្រាប់។
- ស្តង់ដារដោយស្ម័គ្រចិត្តដែលអាចអនុវត្តបាន ដែលក្រុមហ៊ុនបានសន្យាចំពោះខ្លួនឯង និងកាតព្វកិច្ចពាក់ព័ន្ធរបស់ក្រុមហ៊ុន។
- ស្តង់ដារស្ថាប័នហិរញ្ញប្បទានអន្តរជាតិដែលអាចអនុវត្តបាន ដែលក្រុមហ៊ុនត្រូវគោរពតាម។
- ព័ត៌មានលម្អិតពីបុគ្គលសំខាន់សម្រាប់ទាក់ទងក្នុងក្រុមហ៊ុន។
- លក្ខណៈ ទំហំ គោលបំណង ទីតាំង រយៈពេល និងភាពអាចស្ដាឡើងវិញបានរបស់គម្រោងដែលបានស្នើឡើង។

- ប្រភេទលិខិតអនុញ្ញាតដែលបានស្នើសុំ។
- លទ្ធផលរកឃើញ និងអនុសាសន៍ដែលបានមកពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម។
- លទ្ធផលរកឃើញ និងអនុសាសន៍ដែលបានមកពីការវាយតម្លៃលើគុណតម្លៃនៃការអភិរក្សកម្រិតខ្ពស់។
- ការវាយតម្លៃដែលមានតុល្យភាពពីផលប៉ះពាល់រយៈពេលវែង និងរយៈពេលខ្លី របស់គម្រោងលើបរិស្ថាន និងសង្គម។
- ហានិភ័យដែលអាចកើតមាន និងអត្ថប្រយោជន៍គម្រោងដែលបានស្នើឡើងសម្រាប់ភាគីរងផលប៉ះពាល់។
- យន្តការមានស្រាប់ ឬរៀបចំឡើងសម្រាប់ដោះស្រាយ និងផ្ដល់ដំណោះស្រាយដល់ជម្លោះ។

**គោលការណ៍ណែនាំស្ដីពីសន្តិសុខស្បៀង និងរបរចិញ្ចឹមជីវិត**

**១២.១០** នៅពេលដែលការវិនិយោគពាក់ព័ន្ធនឹងប្រតិបត្តិការខ្នាតធំលើសិទ្ធិកាន់កាប់ដីធ្លី ដូចជា លទ្ធកម្មដីធ្លី និងកិច្ចព្រមព្រៀងភាពជាដៃគូ ត្រូវបានយកមកពិចារណា រដ្ឋគួរខិតខំប្រឹងប្រែងផ្ដល់លទ្ធភាពឱ្យភាគីផ្សេងៗរៀបចំការវាយតម្លៃដោយឯករាជ្យជាមុនស្ដីពីផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលអាចកើតមានដោយសារការវិនិយោគទាំងនោះលើសិទ្ធិកាន់កាប់ សន្តិសុខស្បៀង និងការសម្រេចបានសិទ្ធិជាបន្តបន្ទាប់ក្នុងទទួលបានអាហារគ្រប់គ្រាន់ របរចិញ្ចឹមជីវិត និងបរិស្ថាន។ រដ្ឋគួរធានាថា សិទ្ធិកាន់កាប់ដីស្របច្បាប់ដែលមានស្រាប់ និងការទាមទារ រួមមាន សិទ្ធិកាន់កាប់ជាប្រពៃណី និងសិទ្ធិកាន់កាប់ក្រៅផ្លូវការ ត្រូវបានកំណត់ជាប្រព័ន្ធ និងដោយផ្នែក ព្រមទាំងសិទ្ធិ និងរបរចិញ្ចឹមជីវិតរបស់ប្រជាជនផ្សេងទៀត ដែលបានរងផលប៉ះពាល់ដោយការវិនិយោគផងដែរ ដូចជា អ្នកផលិតខ្នាតតូចជាដើម។ ដំណើរការនេះគួររៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ដោយអនុលោមតាមគោលការណ៍នៃការពិគ្រោះយោបល់ និងការចូលរួមរបស់គោលការណ៍ណែនាំទាំងនេះ។ រដ្ឋគួរធានាថា សិទ្ធិកាន់កាប់ស្របច្បាប់ដែលមានស្រាប់មិនត្រូវបានកែសម្រួល តាមរយៈការវិនិយោគនេះឡើយ។

- ដំណើរការពិនិត្យតាមដាន ផ្ទៀងផ្ទាត់ និងវាយតម្លៃដែលមានការចូលរួមដែលមានស្រាប់ ឬរៀបចំឡើង។
- បុគ្គលិកដែលចូលរួមក្នុងការអនុវត្តគម្រោង។
- ឱកាសការងារសម្រាប់សហគមន៍ តាមរយៈគម្រោង លក្ខខណ្ឌការងារ អត្ថប្រយោជន៍ និងតម្រូវការការប៉ាន់ប្រមាណតួលេខចំនួនការងារជំនាញ និងមិនមែនជំនាញ កម្រិតនៃការជួលបុគ្គលិកពីខាងក្រៅ និងផលប៉ះពាល់លើការងារ ដែលអាចរកបានក្នុងតំបន់។
- នីតិវិធីដែលគម្រោងត្រូវអនុវត្តតាម។
- ទម្រង់បែបបទនៃដំណោះស្រាយ និងវិធានការកាត់បន្ថយដើម្បីការពាររបរចិញ្ចឹមជីវិតរបស់សហគមន៍។
- របៀបធានាសន្តិសុខស្បៀងអាហារនិងទឹករបស់សហគមន៍មូលដ្ឋាន[១៤]។
- ជម្រើស នីតិវិធី និងដំណោះស្រាយសម្រាប់ការផ្លាស់ប្ដូរទីលំនៅរបស់សហគមន៍មូលដ្ឋាន ប្រសិនបើពួកគេយល់ព្រម[១៥]។
- ផ្នែកនៃគម្រោង ដែលបើកចំហឱ្យមានការកែប្រែ ដោយផ្អែកតាមជាតុចូល និងផ្នែកដែលមិនអាចកែប្រែបាន។

14 សន្តិសុខស្បៀងអាហារ និងរបរចិញ្ចឹមជីវិត ៖ សូមមើលគោលការណ៍ណែនាំក្នុង 1.1; 4.1; 8.11; 12.1; 12.2; 12.6; 12.8; 12.10; 12.12; 12.15; 13.1; 26.2; 26.4។

15 សំណង ៖ សូមមើលគោលការណ៍ណែនាំ 4.1–14.4. សំណង និងការដេកហូត ៖ សូមមើលគោលការណ៍ណែនាំក្នុង 3A.1.4; 4.9; 16.1–16.9។ ការជម្លៀស ៖ សូមមើលគោលការណ៍ណែនាំក្នុង 3A.1.2; 4.4; 4.5; 7.6; 9.5; 10.6; 16.7–16.9។

**រដ្ឋាភិបាល គួរផ្តល់ព័ត៌មានមួយចំនួន ប៉ុន្តែមិនកំណត់ត្រឹមព័ត៌មានដូចខាងក្រោម ៖**

- ស្ថានភាពស្របច្បាប់របស់សហគមន៍
- សិទ្ធិរបស់សហគមន៍យោងតាមច្បាប់ជាតិ និងអន្តរជាតិ និងកាតព្វកិច្ចពាក់ព័ន្ធរបស់រដ្ឋ។ សិទ្ធិទាំងនេះអាចរាប់បញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម សិទ្ធិទទួលបានការផ្តល់សេវាសុខភាព ការអប់រំ អត្តិសនីគមនាគមន៍ ការដឹកជញ្ជូន ផ្លូវថ្នល់ ទីផ្សារ រដ្ឋបាល ការរៀបចំសន្តិសុខសង្គម និងសារពើពន្ធ ។ល។ សិទ្ធិទាំងនោះក៏គ្របដណ្តប់កាតព្វកិច្ចរបស់រដ្ឋក្នុងការគោរពសិទ្ធិបុគ្គលក្នុងការទទួលបានការអភិវឌ្ឍសុខភាព និងការរីករាយនឹងបរិស្ថាន ទ្រព្យសម្បត្តិ ឯកជនភាព ដំណោះស្រាយដ៏មានប្រសិទ្ធិភាព ការជំនុំជម្រះដោយយុត្តិធម៌ ការមិនរើសអើង ដំណោះស្រាយក្នុងករណីមិនបានអនុវត្តតាមភាពយុត្តិធម៌ ។ល។
- ស្ថានភាពស្របច្បាប់របស់តំបន់គម្រោងគោលដៅ
- ផលវិបាកផ្នែកច្បាប់លើការផ្លាស់ប្តូរការប្រើប្រាស់ដីសម្រាប់សិទ្ធិរបស់សហគមន៍
- យុត្តាធិការរបស់ស្ថាប័នរដ្ឋពាក់ព័ន្ធ និងភាពពាក់ព័ន្ធរបស់ស្ថាប័នទាំងនោះចំពោះសហគមន៍
- យន្តការដោះស្រាយ និងការផ្តល់ដំណោះស្រាយជម្លោះដែលមានស្រាប់ ឬមានការរៀបចំ
- ដំណើរការពិនិត្យតាមដាន ផ្ទៀងផ្ទាត់ និងវាយតម្លៃដែលមានការចូលរួមដែលមានស្រាប់ ឬរៀបចំឡើង
- ព័ត៌មានលម្អិតអំពីបុគ្គលសំខាន់សម្រាប់ទាក់ទងក្នុងក្រុមហ៊ុន
- សេវារដ្ឋដែលនឹងរងផលប៉ះពាល់ដោយសារគម្រោង
- សេវារដ្ឋដែលនឹងកែលម្អតាមរយៈគម្រោង
- ដំណោះស្រាយ ឬការកាត់បន្ថយផលប៉ះពាល់ដែលរដ្ឋាភិបាលនឹងទទួលបានពីក្រុមហ៊ុន ដើម្បីទូទាត់សងរាល់ផលប៉ះពាល់អវិជ្ជមានដោយសារគម្រោង ។
- យន្តការដំណោះស្រាយដែលរដ្ឋាភិបាលនឹងផ្តល់ឱ្យសហគមន៍ ក្នុងករណីមានការបំពានពីក្រុមហ៊ុន ។

សហគមន៍មូលដ្ឋាន គួរផ្តល់ព័ត៌មានមួយចំនួន រួមមានជាអាទិ៍ ដូចខាងក្រោម ៖

- សិទ្ធិជាប្រពៃណី និងការប្រើប្រាស់ដី និងធនធានធម្មជាតិ
- គុណតម្លៃផ្នែកវប្បធម៌ និងប្រវត្តិសាស្ត្ររបស់ដី និងធនធានធម្មជាតិ ។
- តំបន់ដែលមានសារសំខាន់បំផុតក្នុងតំបន់គម្រោងគោលដៅ និងរបៀបដែលតំបន់ទាំងនេះត្រូវបានអភិរក្ស ។
- បែបបទរបរចិញ្ចឹមជីវិតក្នុងតំបន់ និងទម្រង់ផ្សេងទៀតនៃការពឹងផ្អែកលើដី និងធនធានធម្មជាតិ ។ បែបបទទាំងនេះអាចរួមមាន លទ្ធភាពទទួលបានអាហារ និងទឹកប្រើប្រាស់ ការគ្រប់គ្រងធនធានធម្មជាតិ និង សកម្មភាពសេដ្ឋកិច្ចជាច្រើនផ្សេងទៀត ។
- បទពិសោធន៍ពីមុនៗ ជាមួយលទ្ធកម្មដីធ្លីរបស់វិស័យឯកជន លើដីដែលប្រើប្រាស់ជាលក្ខណៈប្រពៃណី និងការកើតទុក្ខមិនសុខចិត្តដែលបានលើកឡើង ។
- ដំណើរការចរចា និងធ្វើសេចក្តីសម្រេចក្នុងមូលដ្ឋានរួមមាន យន្តការដែលបានព្រមព្រៀងសម្រាប់តំណាងក្នុងមូលដ្ឋាន ។

**ការយល់ព្រមដោយទទួលបានព័ត៌មានពេញលេញ**

*ប្រភព*៖កម្មវិធី UN-REDD ឆ្នាំ២០១៣

- បញ្ហាកង្វល់ដោយសារគម្រោង
- ការរំពឹងទុកពាក់ព័ន្ធនឹងដំណោះស្រាយសម្រាប់ការខូចខាត ឬការបាត់បង់ដោយសារគម្រោង ប្រសិនបើមានការផ្តល់ការព្រមព្រៀង។
- ការកំណត់ឱកាសក្នុងគម្រោង (ដូចជា ការអភិវឌ្ឍតំបន់ជនបទ សុខុមាលភាពសង្គមហេដ្ឋារចនាសម្ព័ន្ធ ឬរបរចិញ្ចឹមជីវិតផ្សេងទៀត)។
- ការរំពឹងទុកពាក់ព័ន្ធនឹងគំរូអាជីវកម្មដែលត្រូវប្រើប្រាស់ និងលក្ខណៈ និងកម្រិតនៃអត្ថប្រយោជន៍ដែលពួកគេរំពឹងទុក។
- លក្ខណៈបទពិសោធន៍ពីមុននៃទំនាក់ទំនងជាមួយរដ្ឋ និងការកើតទុក្ខមិនសុខចិត្ត។
- សំណើឱ្យមានការកែប្រែគម្រោងដើម្បីបំពេញតាមតម្រូវការរបស់ពួកគេ។

**រាល់ព័ត៌មានដែលផ្តល់ឱ្យភាគីពាក់ព័ន្ធទាំងអស់ត្រូវតែ៖**

- អាចរកបាន ច្បាស់លាស់ ស៊ីសង្វាក់គ្នា ត្រឹមត្រូវ និងមានតម្លាភាព
- ផ្តល់ឱ្យដោយប្រើប្រាស់ភាសា និងទម្រង់សមស្រប (រួមមាន វិទ្យុ វីដេអូ ក្រាហ្វិក ភាពយន្តឯកសារ រូបថត)
- មិនលម្អៀង ដោយផ្តោតលើទាំងសក្តានុពលវិជ្ជមាន និងអវិជ្ជមានរបស់សកម្មភាពគម្រោង និងផលវិបាកនៃការផ្តល់ ឬលុបចោលការព្រមព្រៀង។
- មានលក្ខណៈពេញលេញ ដោយផ្តោតលើវិសាលភាពនៃផលប៉ះពាល់សង្គម ហិរញ្ញវត្ថុ នយោបាយ វប្បធម៌ បរិស្ថាន រួមទាំងព័ត៌មានវិទ្យាសាស្ត្រ ដែលផ្តល់ឱ្យនូវប្រភពដើមជាភាសាសមស្រប។
- ផ្តល់ឱ្យក្នុងលក្ខណៈមួយដែលពង្រឹង និងមិនប៉ះពាល់ដល់ជនជាតិដើមភាគតិច និង វប្បធម៌ក្នុងតំបន់។
- ផ្តល់ឱ្យដោយបុគ្គលិកដែលមានការយល់ដឹងពីវប្បធម៌ ក្នុងទីតាំងសមស្របតាមវប្បធម៌ និងរួមបញ្ចូលការកសាងសមត្ថភាពរបស់គ្រូឧទ្ទេសនាមជនជាតិដើមភាគតិច ឬ ក្នុងមូលដ្ឋាន។
- ផ្តល់ឱ្យក្នុងពេលវេលាគ្រប់គ្រាន់ដើម្បីយល់ដឹង និងផ្ទៀងផ្ទាត់។
- ផ្សព្វផ្សាយដល់សហគមន៍រស់នៅក្នុងតំបន់ដាច់ស្រយាល តំបន់ជនបទ ស្ត្រី និងក្រុមបាត់បង់ឱកាស។
- ផ្តល់ឱ្យជាហូត និងជាបន្តបន្ទាប់ក្នុងដំណើរការព្រមព្រៀងជាមុមដោយស្ម័គ្រចិត្ត ។

ការប្រើប្រាស់“ការសន្មតទុកជាមុនក្នុងលក្ខណៈមួយបើកចំហ”មានន័យថាជាការទទួលបានព័ត៌មានជាមុនក្នុងករណីចាំបាច់ ជាពិសេស ក្នុងករណីដែលមិនមានហេតុផលជំរុញណាមួយឱ្យចែករំលែកព័ត៌មាននោះ។ ត្រូវចងចាំថាការខ្វះខាតព័ត៌មាន អាចធ្វើឱ្យមានការរីកសាយនូវព័ត៌មានមិនត្រឹមត្រូវពីគម្រោងដែលអាចប៉ះពាល់ដល់ដំណើរការចរចា និងកិច្ចខិតខំប្រឹងប្រែងចូលរួមក្នុងកិច្ចសន្ទនា ដែលផ្អែកតាមព័ត៌មានត្រឹមត្រូវជាមួយអ្នកមានសិទ្ធិទាំងអស់។ តម្លាភាព និងលទ្ធភាពរួចជាស្រេចក្នុងការទទួលបានព័ត៌មាន ក៏អាចជាកស្តុតាងបង្ហាញពីការទទួលខុសត្រូវរបស់អ្នក និងការចូលរួមដោយសុចរិត ក្នុងដំណើរការនៃការគោរពការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត។

## ការផ្តល់លទ្ធភាពទទួលបានប្រភពព័ត៌មាន និងការណែនាំដោយឯករាជ្យ

សហគមន៍មានសិទ្ធិទទួលបានប្រភពព័ត៌មានដោយឯករាជ្យក្នុងដំណើរការនៃការគោរពយល់ព្រមជាមុនដូចជាក្នុងអំឡុងពេលដំណើរការសម្រេចបានការព្រមព្រៀង និងជាពិសេសមុនពេលធ្វើសេចក្តីសម្រេច និងកិច្ចព្រមព្រៀង។ ចំណុចនេះមានគោលបំណងផ្តល់លទ្ធភាពឱ្យសហគមន៍ធ្វើសេចក្តីសម្រេចដោយមានព័ត៌មានត្រឹមត្រូវ ផ្អែកលើព័ត៌មានជាច្រើនដែលពួកគេជ្រើសរើសរួមមាន ព័ត៌មានស្តីពីជម្រើសសម្រាប់គម្រោងដែលបានស្នើឡើង ដោយមិនផ្អែកលើអត្ថប្រយោជន៍អ្នកគាំទ្រគម្រោង។ រដ្ឋាភិបាលនិងក្រុមហ៊ុនគួរសម្របសម្រួលលទ្ធភាពរបស់សហគមន៍មូលដ្ឋាន ក្នុងការទទួលបានប្រភពព័ត៌មានដោយឯករាជ្យហើយអង្គការមិនមែនរដ្ឋាភិបាលអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាន និង/ឬផ្តល់ការណែនាំដោយឯករាជ្យ។

## តើកិច្ចការនេះគួរត្រូវអនុវត្តដោយរបៀបណា?

**ត្រូវជូនដំណឹងដល់សហគមន៍ថា** ពួកគេមានសិទ្ធិទទួលបានប្រភពព័ត៌មានដោយ ឯករាជ្យក្នុងដំណើរការព្រមទាំងសិទ្ធិស្វែងរកការណែនាំ ពីជនជាតិដើមភាគតិច និងពីអង្គការជនជាតិដើមភាគតិច ឬមិនមែនជនជាតិដើមភាគតិចទៅតាមករណីសមស្រប។ ក្នុងករណីចាំបាច់ត្រូវជួយកំណត់ប្រភពនិងក្រុមទាំងនេះ និងសម្របសម្រួលលទ្ធភាពទទួលបានដល់ពួកគេ។

**ផ្តល់ជម្រើសក្លាយជាអ្នកសម្របសម្រួលៈ** សហគមន៍ដែលស្នើសុំជំនួយគួរទទួលបានជម្រើសក្លាយជាអ្នក សម្របសម្រួលរួមមាន ការលើកឡើងដោយសហគមន៍ដោយផ្ទាល់។

**គាំទ្រឱ្យមានការប្រើប្រាស់អ្នកផ្តល់ប្រឹក្សាៈ** សហគមន៍ក៏មានសិទ្ធិស្នើឱ្យអ្នកផ្តល់ប្រឹក្សា ដែលរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម មេធាវី អ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬសម្ព័ន្ធផ្សេងទៀត ចូលរួមក្នុងការអង្កេត ឬការសម្របសម្រួល និងផ្តល់អនុសាសន៍បែបច្នៃប្រឌិត និងសំខាន់ៗ។ រដ្ឋាភិបាល និង/ឬអ្នកបង្កើតគម្រោងគួរផ្តល់ជំនួយហិរញ្ញវត្ថុ និងភស្តុភារឱ្យបានគ្រប់គ្រាន់ដល់សហគមន៍ដើម្បីទទួលបានការគាំទ្រនេះ។ ប៉ុន្តែ ទោះជាយ៉ាងណា អ្វីដែលល្អនោះ ជំនួយផ្នែកហិរញ្ញវត្ថុ និងភស្តុភារ មិនគួរបានមកដោយផ្ទាល់ពីអ្នកបង្កើតគម្រោងនោះឡើយ។ សហគមន៍មានសិទ្ធិទទួលបានមូលនិធិ និង សេវាដែលមិនស្ថិតក្រោមការគ្រប់គ្រងផ្តាច់មុខរបស់អ្នកបង្កើតគម្រោង។

## ការសម្រេចបានកិច្ចព្រមព្រៀង និងការជំរុញប្រសិទ្ធភាពកិច្ចព្រមព្រៀង

ប្រការសំខាន់ ដំណើរការស្វែងរកការព្រមព្រៀងត្រូវបញ្ចៀសឱ្យបាននូវការគ្រប់គ្រង ពោលគឺកិច្ចព្រមព្រៀងត្រូវសម្រេចបានដោយមានការទទួលស្គាល់ទៅវិញទៅមកពីភាគីទាំងអស់ ហើយជំហានបន្ទាប់នឹងអាចអនុវត្តទៅបាននៅពេលកិច្ចព្រមព្រៀងត្រូវបានលុបចោលប្រសិនបើមានការព្រមព្រៀងពីសហគមន៍មូលដ្ឋាន។ ការព្រមព្រៀងពីគ្រប់ភាគីគឺជាប្រការសំខាន់ដើម្បីបញ្ចប់ជំហាននីមួយៗនៃដំណើរការទោះបីជាជំហានទាំងនេះត្រូវបានអនុវត្តម្តងហើយម្តងទៀតក៏ដោយ។ បន្ថែមពីនេះ ទោះបីជាក្នុងករណីដែលមានការទទួលបានការព្រមព្រៀងពីជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានក៏ដោយ ក៏ការព្រមព្រៀងនោះមិនគួរបង្កឱ្យមានការប៉ះពាល់ដល់សិទ្ធិមនុស្សនោះដែរ។

### ជម្រើសនៃសិទ្ធិកាន់កាប់ និងម្ចាស់ភាគហ៊ុន

ប្រការសំខាន់ ភាគីទាំងអស់ត្រូវបើកចិត្តឱ្យទូលាយចំពោះសិទ្ធិកាន់កាប់ជាជម្រើស និងគំរូផលិតកម្មក្នុងការពិភាក្សាពីរបៀបអនុវត្តគម្រោង។ ការណ៍នេះ អាចសំដៅលើការផ្លាស់ប្តូរទំហំ និងទីតាំងរបស់ដីគោលដៅ និងគំរូនៃការប្រើប្រាស់ដី ហើយក៏អាចសំដៅលើជម្រើសខុសៗគ្នា លើគំរូនៃការដាំដុះ ៖ ដំណាំចម្រុះ និងដំណាំតែមួយមុខ គំរូផលរបរចិញ្ចឹមជីវិតលក្ខណៈគ្រួសារ គំរូដីកម្មសិទ្ធិធំ ការដាំដុះបែបប្រពលវប្បកម្ម ដែលផ្តល់ទិន្នផលខ្ពស់លើតំបន់តូចៗ( គំរូសន្សំសំចៃដី )ឬទិន្នផលទាប ប៉ុន្តែជាការដាំដុះខ្នាតធំ ( គំរូចែករំលែកដី )(Phalan et al. 2011 )។ ជម្រើសផ្សេងទៀត អាចមានដូចជាការវិនិយោគអាជីវកម្មរួម សមធម៌រួម ការគ្រប់គ្រងរួម ឬការម៉ៅការ ឬការម៉ៅការបន្តរបស់សហគ្រាសសហគមន៍។

ស្ថានភាពរបស់សហគមន៍ពាក់ព័ន្ធនឹងក្រុមហ៊ុន ឬវិនិយោគិនខាងក្រៅ គួរទទួលបានការពិភាក្សា ដើម្បីបង្ហាញពីការគោរព និងការពារសិទ្ធិរបស់ពួកគេ។ជម្រើសផ្សេងទៀត គឺនិយោជិតបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ម្ចាស់ភាគហ៊ុន ឬដៃគូអាជីវកម្ម។ បន្ថែមពីនេះភាគីពាក់ព័ន្ធទាំងអស់ គួរព្រមព្រៀងលើលក្ខខណ្ឌនៃកិច្ចសន្យាជួលរួមមាន រយៈពេល ការធ្វើកិច្ចសន្យាថ្មី លក្ខខណ្ឌតម្រូវ និងទោសបញ្ញត្តិពាក់ព័ន្ធ។

### តើកិច្ចការនេះគួរត្រូវអនុវត្តដោយរបៀបណា ?

**យល់ស្របលើរបៀបដើម្បីព្រមព្រៀងគ្នាៈ** ក្នុងការពិគ្រោះយោបល់ជាមួយសហគមន៍ ត្រូវយល់ស្របជាមួយពួកគេអំពីរបៀបសម្រេចបានកិច្ចព្រមព្រៀងនិងការលើកឡើងពីកិច្ចព្រមព្រៀង ដោយពិចារណាពីបែបបទជាប្រពៃណីនៃការធ្វើសេចក្តីសម្រេច និងការស្វែងរកការព្រមព្រៀង។ កិច្ចការទាំងនេះអាចរួមមាន ការបោះឆ្នោត ការលើកដៃ ការចុះហត្ថលេខាលើឯកសារដែលមានភាគីទីបីជាសាក្សី ការរៀបចំពិធីសាសនា ដែលធ្វើឱ្យកិច្ចព្រមព្រៀងក្លាយជាកិច្ចព្រមព្រៀងដែលចងភ្ជាប់កាតព្វកិច្ច។ល។ ជ្រើសរើសលក្ខខណ្ឌ សម្រាប់ការសម្រេចបានការព្រមព្រៀងដែលមានសុពលភាព។ ឧទាហរណ៍ សុពលភាព អាចអាស្រ័យលើភាគរយសហគមន៍ដែលមានវត្តមានក្នុងការធ្វើសេចក្តីសម្រេចចំនួនសន្លឹកឆ្នោត ឬកម្រិតនៃការតំណាងពីក្រុមផ្សេងៗក្នុងសហគមន៍( ដូចជា ស្ត្រីយុវជន ប្រជាជនក្រីក្រក្នុងតំបន់ជនបទ ឬជនចំណាកស្រុក )។ គ្រប់ករណីទាំង

អស់ សហគមន៍មានសិទ្ធិរៀបចំកិច្ចព្រមព្រៀង ឱ្យក្លាយជាកិច្ចព្រមព្រៀងដែលចងកាតព្វកិច្ច ដោយយោងតាមការអនុវត្តជាប្រពៃណីរបស់ខ្លួនទៅតាមការចង់បានរបស់ពួកគេ។

**ស្គាល់ពីតួនាទីរបស់អ្នកសម្របសម្រួល៖** អ្នកសម្របសម្រួលគួរផ្តល់ការរិះគន់ក្នុងន័យកែលម្អសន្តិសុខផ្លូវចិត្ត និងការគាំទ្រផ្នែកប្រាជ្ញាស្មារតីនៅក្នុងការពិគ្រោះយោបល់។ វាអាចជាប្រការសំខាន់ ក្នុងការចាត់តាំងភាគីឯករាជ្យទីបីឱ្យមានតួនាទីជា "អ្នករិះគន់" ដែលសាកសួរការធ្វើសេចក្តីសម្រេច។ ធ្វើដូច្នេះ ដំណាក់កាលនីមួយៗនៃការពិគ្រោះយោបល់ គឺត្រូវបានពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ និងអនុម័តដោយក្រុមពិគ្រោះយោបល់ទាំងមូលមុនពេលពួកគេបន្តទៅប្រធានបទថ្មី។

**ចូលរួមចរចាប្រកបដោយការសហការ៖** ការចរចាគឺមិនមែនជាការយកឈ្នះ ឬចាញ់នោះឡើយ។ ការចរចាគឺសំដៅលើការសហការ ដើម្បីអាចឱ្យភាគីទាំងអស់សម្រេចបានគោលបំណងណាមួយរបស់ខ្លួន។ត្រូវធ្វើយ៉ាងណាឱ្យភាគីផ្សេងទៀតយល់ឃើញថា ការចរចាគឺជាផ្នែកមួយនៃទំនាក់ទំនងនិងកិច្ចសន្ទនារយៈពេលវែង។ ត្រូវញែកព័ត៌មានពិតចេញពីគុណតម្លៃ៖ គេអាចដោះស្រាយបញ្ហាព័ត៌មានផ្ទុយគ្នាបានតាមរយៈការស្រាវជ្រាវ ប៉ុន្តែគេមិនអាចដោះស្រាយបញ្ហាគុណតម្លៃផ្ទុយគ្នាបានឡើយ។ ភាគីគួរគោរពតាមឃ្លា "ការឯកភាពគ្នាថាមិនព្រមព្រៀង" ទន្ទឹមនឹងការធ្វើឱ្យការចរចាកាន់តែមានលក្ខណៈជាមិត្តភាព។ ត្រូវផ្តល់ការសរសើរដល់អ្នកចូលរួមផ្សេងទៀត ដែលបានចែករំលែកគំនិតល្អៗ និងគោរពអ្នកដែលចែករំលែកគំនិតមិនល្អ។ត្រូវស្តាប់យ៉ាងយកចិត្តទុកដាក់ និងយ៉ាងសកម្មចំពោះ អ្វីដែលអ្នកគ្រប់គ្នាបានលើកឡើង។ប្រសិនបើព័ត៌មានមិនទាន់ច្បាស់ឬមានលក្ខណៈបច្ចេកទេសត្រូវស្នើសុំឱ្យមានការលើកឡើងព័ត៌មាននោះ សាជាថ្មី ឬ និយាយម្តងទៀត។

**ត្រូវមានការបត់បែន៖** នៅពេលដែលសហគមន៍ជំទាស់នឹងផ្នែកណាមួយនៃគម្រោង ត្រូវបង្កើតផ្នែកដែលអាចឱ្យសហគមន៍ទទួលយកបាន និងផ្នែកដែលត្រូវកែសម្រួល ឬលុបចោល។ ត្រូវបើកចិត្តឱ្យទូលាយក្នុងការកែប្រែគម្រោង និងគោលបំណងដើម ដើម្បីឱ្យភាគីទាំងអស់មានការពេញចិត្ត។

**ត្រូវត្រៀមខ្លួនក្នុងករណីមានការជាប់គាំង៖** ព្រមព្រៀងជាមុននូវវិធានការដែលនឹងត្រូវអនុវត្ត ប្រសិនបើការចរចា មិនអាចសម្រេចបានកិច្ចព្រមព្រៀង និងឈានដល់ការជាប់គាំង។ ការណ៍នេះ អាចរាប់បញ្ចូលនីតិវិធីស្នើទៅអ្នកសម្របសម្រួលឯករាជ្យរយៈពេលសម្រាកមុនពេលការចរចា នីតិវិធីសម្រាប់ការរៀបចំការចរចាសាជាថ្មី។ល។

**នៅពេលដែលមានការលុបចោលការព្រមព្រៀង** ត្រូវបង្កើតគោលការណ៍ ពេលគឺលក្ខខណ្ឌដែលត្រូវបំពេញឱ្យបានដើម្បីឱ្យសហគមន៍ព្រមព្រៀង មិនថាសហគមន៍នឹងពិចារណាពីការចរចាសាជាថ្មី និងលក្ខខណ្ឌ និងការកំណត់ពេលវេលានៃការចរចាឡើងវិញចុងក្រោយ ឬយ៉ាងណានោះទេ។ ក្រុមហ៊ុន គួរគោរពសិទ្ធិរបស់សហគមន៍ក្នុងការបដិសេធរាល់ការចរចា ទៅតាមការចង់បានរបស់ពួកគេ។

**មូលដ្ឋានគ្រឹះនៃការចរចាប្រកបដោយប្រសិទ្ធភាព**

*ប្រភព៖* Barsh និង Bastien ឆ្នាំ១៩៩៧

- ផ្តល់ព័ត៌មាន និងជំរុញឱ្យមានការចូលរួមពីសហគមន៍
- កំណត់តម្រូវការរបស់អ្នកឱ្យបានច្បាស់លាស់ និងព្រមព្រៀងលើចំណុចអាទិភាព។
- កំណត់តម្រូវការរបស់ភាគីផ្សេងទៀត។
- បង្ហាញពីភាពអាចជឿជាក់ និងសមត្ថភាពរបស់អ្នកក្នុងការផ្សព្វផ្សាយ។
- បង្កើតទំនាក់ទំនង (ទំនាក់ទំនងល្អ) ជាមួយនឹងអ្នកចរចាផ្សេងទៀត។
- ស្វែងរកមធ្យោបាយក្នុងការសម្របសម្រួល តម្រូវការភាគីផ្សេងទៀតជាមួយនឹងតម្រូវការផ្ទាល់ខ្លួនរបស់អ្នក។
- រៀបចំសំណើដែលមានលក្ខណៈជាក់លាក់ និងអាចសម្រេចបាន។
- បំបាត់ចោលនូវកំហឹង មោទនភាព និងចម្ងល់ផ្ទាល់ខ្លួន។

### ខ្លឹមសារនៃកិច្ចព្រមព្រៀង អាចបញ្ចូលៈ

- ភាគីហត្ថលេខី
- ភស្តុតាងនៃការព្រមព្រៀងជាបន្តបន្ទាប់ដែលមានការយល់ស្របទៅវិញទៅមក
- ព័ត៌មានលម្អិតអំពីកិច្ចព្រមព្រៀង (ដូចជា ចំណាយ អត្ថប្រយោជន៍ លក្ខខណ្ឌ វិធាន និងការរិតត្បិត) ដោយធានាថា រាល់ការរំពឹងទុកត្រូវបានលើកមកបង្ហាញ និងត្រួតពិនិត្យយ៉ាងត្រឹមត្រូវហើយកិច្ចព្រមព្រៀងចុងក្រោយ គឺជាការសន្យា និងព្រមព្រៀងដោយភាគីទាំងអស់។
- រយៈពេលគម្រោង
- ការរៀបចំកិច្ចព្រមព្រៀងឱ្យក្លាយជាកិច្ចព្រមព្រៀងដែលចងកាតព្វកិច្ច
- ដំណើរការ ការកើតទុក្ខមិនសុខចិត្ត
- ផែនការពិនិត្យតាមដាន និងវាយតម្លៃ
- លក្ខខណ្ឌក្នុងការលុបចោលកិច្ច ព្រមព្រៀង
- ចំណុចបន្ទាប់ដែលមានការយល់ស្របដើម្បីសម្រេចបានការព្រមព្រៀង
- ផ្តល់ការផ្ទៀងផ្ទាត់ដោយឯករាជ្យ
- ទោសបញ្ញត្តិសម្រាប់ការបំពានលើកិច្ចព្រមព្រៀង

ចងក្រងជាឯកសារពាក់ព័ន្ធនឹងដំណើរការ ក្នុងទម្រង់ និងភាសា ដែលអាចឱ្យភាគីទាំងអស់យល់បាន និងផ្តល់ការពិនិត្យឡើងវិញ និងការបញ្ជាក់ដល់ភាគីពាក់ព័ន្ធ។

### ការពិនិត្យតាមដាន និងការបញ្ជាក់កិច្ចព្រមព្រៀង[១៦]

នៅពេលសម្រេចបានការព្រមព្រៀង ប្រការសំខាន់ត្រូវធានាថា មានការគោរពតាមកិច្ចព្រមព្រៀងដែលត្រូវបានធ្វើឡើងតាមរយៈដំណើរការពិគ្រោះយោបល់ នៅក្នុងការអនុវត្តជាក់ស្តែងរបស់ខ្លួន។ ប្រសិនបើមិនគោរពតាមកិច្ចព្រមព្រៀង ត្រូវអនុវត្តការដាក់ទោសបញ្ញត្តិ និង/ឬយន្តការនៃការដោះស្រាយ។

បែបបទនៃការពិនិត្យតាមដាន និងផ្ទៀងផ្ទាត់កិច្ចព្រមព្រៀងគួរត្រូវបានកំណត់រួមគ្នា មុនពេលសម្រេចកិច្ចព្រមព្រៀង ហើយគួរមានការរៀបរាប់ពីនីតិវិធីពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ក្នុងកិច្ចព្រមព្រៀង។ សកម្មភាពពិនិត្យតាមដាន និងផ្ទៀងផ្ទាត់គួរធ្វើឡើង នៅពេលមានការព្រមព្រៀងឱ្យគម្រោងចាប់ផ្តើមដំណើរការ ហើយការពិនិត្យឡើងវិញតាមដំណាក់កាលដោយឯករាជ្យគួរធ្វើឡើងក្នុងអំឡុងចន្លោះពេលដែលក្រុមទទួលបានអត្ថប្រយោ-ជន៍ពេញចិត្តទាំងអស់គ្នា។

---

16 ការពិនិត្យតាមដាន និងការផ្ទៀងផ្ទាត់ ៖ សូមមើលគោលការណ៍ណែនាំក្នុង 3B.10; 5.8; 6.7; 12.14, 26.1–26.5។

## តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា?

**រៀបចំការពិនិត្យតាមដានរួមគ្នាជាមួយសហគមន៍៖** សហគមន៍ដែលពាក់ព័ន្ធក្នុងកិច្ចព្រមព្រៀងគម្រោង គួរចូលរួមក្នុងការពិនិត្យតាមដានរួមលើការអនុវត្តគម្រោង។ ការណ៍នេះ រួមមាន ព័ត៌មានរបស់សហគមន៍ ស្ដីពីការរៀបចំវិធីសាស្រ្តពិនិត្យតាមដាន សកម្មភាពដែលត្រូវពិនិត្យតាមដាន វិធីសាស្រ្តពិនិត្យតាមដាន របៀបសម្របសម្រួលទស្សនៈផ្សេងៗគ្នា និងរបៀបកត់ត្រា និងចែករំលែកលទ្ធផលជាមួយសហគមន៍ទាំងមូល។ សហគមន៍ គួរព្រមព្រៀងពីវិធីសាស្រ្តសម្រាប់ការពិនិត្យតាមដានដែលមានការចូលរួម និងយោបល់ត្រឡប់ ដោយមានការយល់ដឹង យ៉ាងពេញលេញពីធនធានមនុស្ស និងហិរញ្ញវត្ថុចាំបាច់ និងដែលអាចរកបាន។

**ប្រើប្រាស់អ្នកពិនិត្យតាមដានដែលឯករាជ្យ៖** ដំណើរការផ្ទៀងផ្ទាត់ គួរត្រូវបានធ្វើឡើងដោយភាគីឯករាជ្យ ដែលភាគីទាំងអស់អាចទទួលយកបាន។

**បញ្ចូលគំនិតយោបល់ផ្សេងៗ៖** ក្រុមផ្ទៀងផ្ទាត់ គួររៀបចំបទសម្ភាសន៍ក្នុងវិសាលភាពនៃអ្នកមានសិទ្ធិ និងអ្នកប្រើប្រាស់ដី រួមមានក្រុមបាត់បង់ឱកាសដូចជា ស្ត្រី ប្រជាជនក្រីក្រ ប្រជាជនគ្មានដីធ្លី និងយុវជន ដើម្បីធានាឱ្យបានការគោរពសិទ្ធិដោយស្មើភាព។

រក្សាអត្តសញ្ញាណអ្នកផ្តល់បទសម្ភាសន៍ជាសម្ងាត់ និងរក្សាឱ្យបាននូវអនាមិកភាពនៃព័ត៌មាន ក្នុងករណីមានការស្នើសុំ។

**ស្នើឱ្យមានយោបល់ត្រឡប់លើលទ្ធផលរកឃើញ៖** ការជួបប្រជុំជាសាធារណៈអាចត្រូវបានរៀបចំឡើង ដើម្បីចែករំលែក និងពិភាក្សាពីលទ្ធផលរកឃើញនៃដំណើរការផ្ទៀងផ្ទាត់។ ការណ៍នេះ ផ្តល់ឱ្យសមាជិកសហគមន៍នូវឱកាសក្នុងការបញ្ជាក់ ឬតវ៉ាលទ្ធផលរកឃើញ និងស្នើសុំឱ្យក្រុមផ្ទៀងផ្ទាត់ផ្សេងៗ រៀបចំដំណើរការម្តងទៀត ក្នុងករណីចាំបាច់។

**ដឹងពីរបៀបដោះស្រាយបញ្ហា៖** យល់ព្រមជាមួយសហគមន៍ អំពីដំណាក់កាលដែលត្រូវដោះស្រាយដំណើរការការកើតទុក្ខមិនសុខចិត្ត ប្រសិនបើមាន បញ្ហាកើតឡើងក្នុងអំឡុងពេលពិនិត្យតាមដាន។ ព្រមព្រៀងលើលក្ខខណ្ឌ នៃការចាប់ផ្តើមដំណើរកាព្រមព្រៀងសាជាថ្មី និងចរចាកិច្ចព្រមព្រៀងសាជាថ្មី។

## គោលការណ៍ណែនាំស្តីពីបណ្តឹងសាទុក្ខ ដំណោះស្រាយ និងដំណោះស្រាយជម្លោះ

ប្រភព៖ អង្គការ FAO ឆ្នាំ២០១២

២១.១ រដ្ឋគួរផ្តល់លទ្ធភាពតាមរយៈអង្គភាពរដ្ឋបាល និងតុលាការដែលមានសមត្ថកិច្ច និងមិនលម្អៀង ដើម្បីដោះស្រាយជម្លោះឱ្យបានទាន់ពេលវេលា សមស្រប និងប្រកបដោយប្រសិទ្ធភាពពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដី រួមមាន មធ្យោបាយផ្សេងៗ នៃការដោះស្រាយជម្លោះ និងគួរផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងសិទ្ធិប្តឹងឧទ្ធរណ៍។ ដំណោះស្រាយ គួរអនុវត្តឱ្យបានឆាប់រហ័ស។ រដ្ឋ គួររៀបចំយន្តការដើម្បីបញ្ចៀស ឬដោះស្រាយជម្លោះ ដែលអាចកើតមានសម្រាប់ភាគីទាំងអស់ នៅដំណាក់កាលដំបូង មិនថាក្នុងស្ថាប័នអនុវត្តន៍ ឬក្រៅស្ថាប័នអនុវត្តន៍នោះឡើយ។ គួរផ្តល់សេវាដោះស្រាយជម្លោះ ដល់ស្ត្រី និង បុរសគ្រប់រូបទាក់ទងនឹងទីតាំង ភាសា និង នីតិវិធី។

## ការបង្កើតដំណើរការបណ្តឹងសាទុក្ខ[១៧]

ប្រការសំខាន់ត្រូវបង្កើតយន្តការឯករាជ្យមួយសម្រាប់ភាគីទាំងអស់ដើម្បីលើកឡើងពីបញ្ហាកង្វល់ដែលអាចកើតមាន ក្នុងអំឡុងពេលអនុវត្តគម្រោង។ យន្តការបណ្តឹងសាទុក្ខ គួរផ្តល់លទ្ធភាពឱ្យមានការបង្កើតការព្រមព្រៀងសាជាថ្មីតាមរយៈជម្រើសដែលអាចធ្វើបាន និង ក្នុងមូលដ្ឋាន ដើម្បីដោះស្រាយជម្លោះខាងក្រៅ។

គួរមានការពិភាក្សា និងបង្កើតយន្តការនេះ ឱ្យបានលឿន ជាជាងទុករហូតទាល់តែកើតមានជម្លោះ ឬមានការលុបចោលកិច្ច ព្រមព្រៀង។ ហេតុដូច្នេះ ការជ្រើសរើសទម្រង់នៃដំណើរការបណ្តឹងសាទុក្ខ គួរត្រូវបានបញ្ចូលក្នុងការពិគ្រោះយោបល់ និងដំណើរការស្វែងរកការព្រមព្រៀង។ គួរ បង្កើតឱ្យមានដំណើរការនេះក្នុងអំឡុងដំណាក់កាលដំបូងនៃកិច្ចព្រមព្រៀង ហើយនឹងដំណើរការនេះ គួរត្រូវបានបញ្ចូលក្នុងកិច្ចព្រមព្រៀងដែលសម្រេចបាន។

**គោលការណ៍ណែនាំស្តីពីបណ្តឹងសាទុក្ខដំណោះស្រាយ និងដំណោះស្រាយជម្លោះ**

*ប្រភព ៖* អង្គការ FAO ឆ្នាំ២០១២

> **២១.១** រដ្ឋគួរផ្តល់លទ្ធភាពតាមរយៈអង្គភាពរដ្ឋបាល និងតុលាការដែលមានសមត្ថកិច្ច និងមិនលម្អៀងដើម្បីដោះស្រាយជម្លោះឱ្យបានទាន់ពេលវេលាសមស្រប
>
> និងប្រកបដោយប្រសិទ្ធភាពពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់ដីរួមមាន មធ្យោបាយផ្សេងៗ នៃការដោះស្រាយជម្លោះ និងគួរផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងសិទ្ធិប្តឹងឧទ្ធរណ៍។ ដំណោះស្រាយ គួរអនុវត្តឱ្យបានឆាប់រហ័ស។រដ្ឋ គួររៀបចំយន្តការ ដើម្បីបញ្ចៀស ឬដោះស្រាយជម្លោះដែលអាចកើតមានសម្រាប់ភាគីទាំងអស់ នៅដំណាក់កាលដំបូង មិនថាក្នុងស្ថាប័នអនុវត្តន៍ ឬក្រៅស្ថាប័នអនុវត្តន៍នោះឡើយ។ គួរផ្តល់សេវាដោះស្រាយជម្លោះ ដល់ស្ត្រី និង បុរសគ្រប់រូប ទាក់ទងនឹងទីតាំង ភាសា និង នីតិវិធី។

### តើកិច្ចការនេះគួរត្រូវបានអនុវត្តដោយរបៀបណា?

**ការព្រមព្រៀងជាមួយសហគមន៍អំពីរបៀបទទួលនិងចុះបញ្ជីបណ្តឹងសាទុក្ខ៖** កិច្ចការនេះ អាចធ្វើទៅបានតាមរយៈក្រុមប្រឹក្សា ឬគណៈកម្មាធិការតំណាងសំខាន់ៗ និងអ្នកផ្តល់ប្រឹក្សាឯករាជ្យ បទសម្ភាសន៍តាមដំណាក់កាលជាមួយសមាជិកសហគមន៍ ដោយអង្គភាពឯករាជ្យ ប្រអប់ទទួលយោបល់ត្រឡប់ជាលាយលក្ខណ៍អក្សរ និងអនាមិក។ល។ ក្នុងករណី ដែលមានយន្តការបណ្តឹងសាទុក្ខជាប្រពៃណី ហើយសហគមន៍សម្រេចអនុវត្តតាមយន្តការទាំងនោះភាគីផ្សេងទៀតគួរគោរពតាមប្រការនេះ។ ការផ្អែកលើដំណើរការបណ្តឹងសាទុក្ខជាប្រពៃណីក្នុងការផ្តល់ព័ត៌មានដល់យន្តការបណ្តឹងសាទុក្ខ នឹងធ្វើឱ្យដំណើរការនេះមានភាពពាក់ព័ន្ធ និងពេញលេញចំពោះសហគមន៍។

ព្រមព្រៀងជាមួយសហគមន៍អំពីរបៀបពិនិត្យឡើងវិញ និងស៊ើបអង្កេតបណ្តឹងសាទុក្ខ៖ ការណ៍នេះ គួររួមបញ្ចូលការតាមដានបណ្តឹងសាទុក្ខ និង ប្រព័ន្ធឆ្លើយតប និងរយៈពេលកំណត់ពាក់ព័ន្ធសម្រាប់ដំណើរការដោះស្រាយបណ្តឹងសាទុក្ខ។

**ព្រមព្រៀងលើជម្រើសដំណោះស្រាយដែលភាគីទាំងអស់ទទួលយក៖** ចំណុចទាំងនេះអាចរួមមានទម្រង់នៃការផ្តល់ដំណោះស្រាយ ការដាក់ទណ្ឌកម្ម ឬ បដិទាន។

**ព្រមព្រៀងលើរបៀបពិនិត្យតាមដានដំណោះស្រាយបណ្តឹងសាទុក្ខ៖** មានការវាយតម្លៃ និងព្រមព្រៀងពីគ្រប់ភាគីទាំងអស់។

**ផ្តល់ព័ត៌មានដល់សហគមន៍អំពីដំណើរការវិនិច្ឆ័យរបស់រដ្ឋាភិបាល និងការទទួលបានយុត្តិធម៌** ក្នុងករណីដែលមិនអាចដោះស្រាយបណ្តឹងសាទុក្ខ ដោយមិនមានជំនួយពីខាងក្រៅ។

**ធ្វើឱ្យមានលក្ខណៈផ្លូវការ ចងក្រងឯកសារ និងផ្សព្វផ្សាយពីដំណើរការបណ្តឹងសាទុក្ខ៖** ព្រមព្រៀងជាមួយសហគមន៍ពីរបៀបធ្វើឱ្យយន្តការបណ្តឹងសាទុក្ខមានលក្ខណៈផ្លូវការ ដោយអនុលោមតាមបទដ្ឋាន

17 ការកើតទុក្ខមិនសុខចិត្ត សំណង និងដំណោះស្រាយជម្លោះ ៖ សូមមើលគោលការណ៍ណែនាំក្នុង 3A.1.4; 3A.1.5; 3A.2; 3.2; 4.9; 6.3; 6.6; 6.7; 9.11; 12.14; 25.1–25.7; 21.1-21.6។

ជាប្រពៃណី និង/ឬតាមរយៈសេចក្តីប្រកាស និងការចុះបញ្ជីយន្តការនោះ ក្នុងស្ថាប័នផ្លូវការមួយ (ដូចជាការិយាល័យរដ្ឋាភិបាលមូលដ្ឋាន ឬតំបន់)។ ចងក្រងដំណើរការបណ្តឹងសាទុក្ខ ក្នុងទម្រង់ និងភាសាដែលភាគីទាំងអស់អាចទទួលយកបាន រួចផ្សព្វផ្សាយ។

## ការផ្តល់លទ្ធភាពទទួលបានដំណោះស្រាយ និងការដោះស្រាយជម្លោះ

ការផ្តល់លទ្ធភាពទទួលបានយន្តការដោះស្រាយជម្លោះ គឺជាកត្តាសំខាន់ក្នុងការបំពេញបាននូវសិទ្ធិទទួលបានដំណោះស្រាយសម្រាប់តួអង្គដែលយល់ថា ភាគីផ្សេងទៀតបានបំពានសិទ្ធិរបស់ខ្លួន។ ដោយមានការរំពឹងទុក និង ការបង្កើតយន្តការបណ្តឹងសាទុក្ខ គួរមានការពិភាក្សា និងបង្កើតយន្តការ ដោះស្រាយជម្លោះឱ្យបានឆាប់ជាជាងទុករហូតទាល់តែមានជម្លោះកើតឡើង ឬមានការលុបចោលកិច្ច ព្រមព្រៀង។

គួរមានការផ្តល់ព័ត៌មាន អំពីការពិគ្រោះយោបល់ ជាមួយសហគមន៍មូលដ្ឋាន តាមរយៈកាតព្វកិច្ចដែលមិនទាន់បានបំពេញរបស់ប្រតិបត្តិករ ពីមុនដែលត្រូវបានចងក្រងជាឯកសារហើយគួរមានការពិភាក្សាពីទម្រង់នៃដំណោះ ស្រាយក្នុងដំណាក់កាលសម្រេចការព្រមព្រៀង និងកិច្ចព្រមព្រៀង។ គួរមានការបំពេញឱ្យបាននូវកាតព្វកិច្ច ដែលមិនទាន់បានបំពេញនេះ នៅពេលដែលមានការបង្កើតការព្រមព្រៀងសម្រាប់គម្រោងដែលត្រូវអនុវត្ត។

**សិទ្ធិទទួលបានដំណោះស្រាយ**

*ប្រភព ៖* Mackay ឆ្នាំ២០០២

យោងតាមច្បាប់អន្តរជាតិ ការបំពានសិទ្ធិមនុស្សបានបង្កើតឱ្យមានសិទ្ធិទទួលបានដំណោះស្រាយសម្រាប់ជនរងគ្រោះ។ ដំណោះស្រាយសំដៅកាត់បន្ថយការរងគ្រោះ និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ "ដោយលុបបំបាត់ចោល ឬផ្តល់ដំណោះស្រាយទៅតាមកម្រិតផលវិបាកនៃអំពើខុសឆ្គង ព្រមទាំងបង្ការ និងទប់ស្កាត់ការរំលោភបំពាន"។ ក្នុងច្បាប់ ស្តីពីសិទ្ធិមនុស្ស ការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពគឺជាសិទ្ធិក្នុង និងរបស់សិទ្ធិនោះផ្ទាល់ដែលបន្ថែមលើសិទ្ធិដែលមានការទទួលស្គាល់ផ្សេងទៀត។ដំណោះស្រាយរួមមាន បដិទាន ដំណោះស្រាយជំងឺចិត្ត ការស្តារឡើងវិញ ការពេញចិត្ត និងការធានាមិនឱ្យករណីដដែលកើតឡើងម្តងទៀត។

## តើកិច្ចការនេះគួរត្រូវអនុវត្តដោយរបៀបណា?

**ជំរុញឱ្យមានការចូលរួមពីអ្នកសម្របសម្រួលជំនាញ** អ្នកឯកទេសដោះស្រាយជម្លោះ ឬការិយាល័យប្រជាពលរដ្ឋដើម្បីសម្របសម្រួលដំណើរការនេះ។ ប្រការសំខាន់អ្នកសម្របសម្រួលមិនត្រូវមានទំនាស់ផលប្រយោជន៍ និងជាអ្នកដែលទទួលយកដោយភាគីទាំងអស់។

**ផ្តល់ពេល និងធនធានឱ្យបានគ្រប់គ្រាន់** សម្រាប់ដំណើរការនេះ ដើម្បីសម្រេចបានលទ្ធផលដែលយុត្តិធម៌។

អនុវត្តតាមជំហាននៃដំណើរការការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្តដែលអាចពាក់ព័ន្ធនឹងការរៀបចំផែនទី ដែលមានការចូលរួម សិទ្ធិកាន់កាប់ដីធ្លី និងការកំណត់ការប្រើប្រាស់ដី ការវាយតម្លៃឡើងវិញលើដំណើរការនៃការធ្វើជាតំណាង និងការបង្កើតយន្តការសម្រាប់ការទូទាត់ដំណោះស្រាយ។

**ការផ្អាកប្រតិបត្តិការ៖** ក្រុមហ៊ុន អាចជួយបង្កើតឡើងវិញនូវការជឿជាក់លើគ្នាទៅវិញទៅមក ដោយផ្អាកប្រតិបត្តិការទាំងអស់ក្នុងតំបន់គម្រោងសម្រាប់អំឡុងពេលនៃការដោះស្រាយជម្លោះ និងដំណើរការស្វែងរកដំណោះស្រាយ។ ការងារនេះអាចសំដៅលើការផ្អាកការចរចាបញ្ហាដីធ្លីនិង/ឬការបញ្ឈប់ការឈ្លានពានលើដីធ្លីដែលស្ថិតក្រោមការពិភាក្សា។ ការផ្អាកប្រតិបត្តិការ ក្នុងពេលកើតមានជម្លោះ គួរត្រូវបានរួមបញ្ចូលជាប្រការក្នុងកិច្ចព្រមព្រៀងចុងក្រោយរបស់គម្រោង។

### ទម្រង់មួយចំនួននៃដំណោះស្រាយ រួមមាន៖

- ការប្រគល់ ឬធ្វើបដិទានដី ដែនដី និងធនធាន និងទ្រព្យសម្បត្តិ និងធនធានអរូបិយផ្សេងទៀត ដែលបានរំលោភយក ឬរងផលប៉ះពាល់ ដោយមិនមានការព្រមព្រៀងពីសហគមន៍។
- ការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី និង/ឬធនធានដែលខូចខាត។
- ការទូទាត់សម្រាប់ការបោះបង់សិទ្ធិ។
- ការបង្កើនអត្ថប្រយោជន៍ដល់ផលរបរចិញ្ចឹមជីវិតលក្ខណៈគ្រួសារ និងកម្មករ។
- ការទូទាត់ជាសាច់ប្រាក់ ឬវត្ថុសម្រាប់ការលះបង់ដី ឬការប្រើប្រាស់ដី។
- ការទូទាត់ដំណោះស្រាយសម្រាប់ការខូចខាត និងការរំលោភបំពានសិទ្ធិ។
- ការទូទាត់ដំណោះស្រាយសម្រាប់ការបាត់បង់របរចិញ្ចឹមជីវិត និងប្រាក់ចំណូល។
- ការទូទាត់ដំណោះស្រាយសម្រាប់ការបាត់បង់កេរ្តិ៍មរតក អរូបិយ។
- ការទូទាត់ថ្លៃដើមសម្រាប់ការធានាដំណោះស្រាយការចូលរួមក្នុងការចរចា និងការស្វែងរកការណែនាំ។
- កិច្ចព្រមព្រៀង មិនថាដើម្បីផ្អាកប្រតិបត្តិការ ជាស្ថាពរក្នុងតំបន់ជម្លោះ និង/ឬបន្តដំណើរការជាមួយកិច្ចព្រមព្រៀង ដែលបានចរចាថ្មី ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវទាំងអស់នៃដំណើរការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត។
- ការធានាជាផ្លូវការថាមិនឱ្យមានករណីនេះកើតឡើងម្តងទៀត។
- នីតិវិធីផ្លូវការ និងទណ្ឌកម្មក្នុងលក្ខខណ្ឌដែលមានករណីដដែលកើតឡើង។

ចងក្រងឯកសារពីដំណើរការផ្តល់ដំណោះស្រាយ ក្នុងទម្រង់ និងភាសាដែលភាគីទាំងអស់អាចយល់បាន។

# ឧបសម្ព័ន្ធ




ដកស្រង់ចេញពី FPP ឆ្នាំ២០០៨ និង Anderson ឆ្នាំ២០១១




# ឧបសម្ព័ន្ធ១
# ជំហានស្នើឡើងក្នុងដំណើរការនៃការគោរព FPIC

# ឧបសម្ព័ន្ធ ២៖ សំណួរសំខាន់ៗ

### សំណួរដែលអ្នកត្រូវឆ្លើយ ៖ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន

- តើនោះជាគម្រោងអ្វី? តើគម្រោងមានទំហំធំប៉ុណ្ណា? តើគម្រោងនឹងត្រូវបានបង្កើតឡើងនៅពេលណា និងនៅកន្លែងណា?
- តើអ្នកបង្កើតគម្រោងបានធ្វើទំនាក់ទំនងជាមួយអ្នក ពាក់ព័ន្ធនឹងការអភិវឌ្ឍដែលស្នើឡើងដែរ ឬទេ?
- តើអ្នកបង្កើតគម្រោងបានធ្វើទំនាក់ទំនងជាមួយស្ថាប័នសហគមន៍ណាខ្លះ?
- តើសហគមន៍មានសេរីភាពក្នុងការជ្រើសរើសអង្គការតំណាងដោយខ្លួនឯងដែរ ឬទេ? ឬក៏អង្គការទាំងនេះត្រូវបានជ្រើសតាំងដោយរដ្ឋាភិបាល ឬជ្រើសរើសដោយអន្តរការី ឬក្រុមហ៊ុន?
- តើអ្នកបង្កើតគម្រោងបានវាយតម្លៃពីទំហំនៃសិទ្ធិកាន់កាប់ដីធ្លីរបស់អ្នក ដូចមានចែងក្នុងច្បាប់ ឬទំនៀមទំលាប់ដែរ ឬទេ?
- តើអ្នកបង្កើតគម្រោងបានយល់ និងគោរពសិទ្ធិកាន់កាប់ដីធ្លី ឬការទាមទារយកដីរបស់អ្នកដែរ ឬទេ?
- តើការរៀបចំផែនទីដែលមានការចូលរួម ត្រូវបានធ្វើឡើងក្រោមការណែនាំរបស់សហគមន៍មូលដ្ឋាន ដើម្បីកំណត់ទំហំនៃសិទ្ធិរបស់អ្នកដែរ ឬទេ?
- តើមានការសម្រេចបានកិច្ចព្រមព្រៀងជាមួយសហគមន៍មូលដ្ឋានពាក់ព័ន្ធនឹងទំហំ និងព្រំដែននៃតំបន់ដែលអ្នកមានសិទ្ធិជាប្រពៃណីដែរ ឬទេ?
- តើតំបន់ដែលអ្នកមានសិទ្ធិជាប្រពៃណីទាំងនេះត្រួតគ្នានឹងតំបន់ ដែលកំពុងត្រូវបានគ្រប់គ្រងដោយអ្នកបង្កើតគម្រោងដែរ ឬទេ?
- តើអ្នកបានមើលឃើញពីការវាយតម្លៃផលប៉ះពាល់លើសង្គម និងបរិស្ថានដែរ ឬទេ?
- តើសហគមន៍របស់អ្នកបានចូលរួមក្នុងការវាយតម្លៃផលប៉ះពាល់លើសង្គមនិងបរិស្ថានដែរ ឬទេ?
- តើអ្នកយល់ស្របនឹងលទ្ធផលរកឃើញដែរ ឬទេ? ប្រសិនបើទេ តើអ្នកមានក្តីកង្វល់អ្វីខ្លះពាក់ព័ន្ធនឹងលទ្ធផលរកឃើញទាំងនោះ?
- តើការវាយតម្លៃផលប៉ះពាល់បានបង្ហាញច្បាស់ពីរបៀបដែលស្ថានភាពស្របច្បាប់នៃដីរបស់អ្នកអាចមានការផ្លាស់ប្តូរដែរ ឬទេ ក្នុងពេលជួល ឬធ្វើសម្បទាន រយៈពេលនៃការជួល ឬប្រតិបត្តិការ និងស្ថានភាពផ្លូវច្បាប់ បន្ទាប់ពីផុតកាលបរិច្ឆេទនៃការជួល ឬធ្វើសម្បទាន?
- តើអ្នកបានមើលឃើញពីការវាយតម្លៃលើគុណតម្លៃនៃការអភិរក្សដែលមានកម្រិតខ្ពស់ដែរ ឬទេ?
- តើសហគមន៍របស់អ្នកបានចូលរួមក្នុងការវាយតម្លៃលើគុណតម្លៃនៃការអភិរក្សដែលមានកម្រិតខ្ពស់ដែរ ឬទេ?
- តើអ្នកយល់ស្របនឹងលទ្ធផលរកឃើញដែរ ឬទេ? តើអ្នកយល់ថា មានការកំណត់តំបន់ដាច់ដោយ

ទ្បែកបានគ្រប់គ្រាន់ (ឧ. មិនមានការជាំជុះ ឬការកាប់ឆ្ការ) សម្រាប់ការការពារសេវាបរិស្ថាន ដូចជាទឹកសាបដែរ ឬទេ? សម្រាប់តំបន់ដែលមានសារសំខាន់ចំពោះអ្នក ដូចជា កន្លែងសាសនា ទីបញ្ចុះសព និងបូជនីយដ្ឋានដែរ ឬទេ? សម្រាប់តម្រូវការមូលដ្ឋានរបស់អ្នកផ្នែកចំណីអាហារ និងផ្នែកសំខាន់ៗផ្សេងទៀតនៃរបរចិញ្ចឹមជីវិតរបស់អ្នកដែរ ឬទេ?

- តើមានការផ្តល់ព័ត៌មានអ្វីខ្លះដល់សមាជិកសហគមន៍? តើព័ត៌មានទាំងនោះត្រូវបានផ្តល់ជាភាសា និងទម្រង់សមស្របដែលអ្នកអាចយល់បានដែរ ឬទេ?
- តើអ្នកបានដឹងអ្វីខ្លះពីសិទ្ធិរបស់អ្នក ដូចជា ការព្រមព្រៀងដោយសេរី និងដោយជូនដំណឹងជាមុន? តើអ្នកយល់ថា អ្នកអាចទទួលបានអត្ថប្រយោជន៍ពីព័ត៌មានជាច្រើនស្តីពីសិទ្ធិស្របច្បាប់របស់អ្នកដែរ ឬទេ?
- តើមានការពិភាក្សាជាមួយសហគមន៍មូលដ្ឋានពីការកាត់បន្ថយផលប៉ះពាល់ ការពិនិត្យតាមដាន ការបែងចែកផលប្រយោជន៍ និងការរៀបចំដំណោះស្រាយដែរ ឬទេ?
- តើមានការរៀបចំវិធានការរួចជាស្រេចអ្វីខ្លះដើម្បីធានាថា សហគមន៍អាចពិចារណាលើការអភិវឌ្ឍន៍ដែលបានស្នើឡើងលើដីរបស់ខ្លួន ដោយមិនមានការបង្ខិតបង្ខំ ឬការគំរាមកំហែង?
- តើកិច្ចប្រជុំត្រូវបានធ្វើឡើងក្នុងកន្លែងដែលជ្រើសរើសដោយសហគមន៍ដែរឬទេ? តើប្រជាជនយល់ថាពួកគេមានសេរីភាពក្នុងការបង្ហាញពីគំនិតរបស់ខ្លួនក្នុងកិច្ចប្រជុំទាំងនេះដែរ ឬទេ?
- តើសហគមន៍ត្រូវបានសាកសួរថាតើ ពួកគេបានយល់ស្របជាមួយនឹងការអភិវឌ្ឍ មុនពេលដែលក្រុមហ៊ុនធ្វើការសម្រេចចិត្តវិនិយោគ និងទទួលបានលិខិតអនុញ្ញាតពីរដ្ឋាភិបាលដែរ ឬទេ?
- ក្នុងការចរចាជាមួយក្រុមហ៊ុនសម្រាប់ការបង្កើតជាចម្ការដាំដុះ តើមានការផ្តល់វិសាលភាព និងពេលវេលាដល់តំណាងសហគមន៍ដើម្បីធ្វើសេចក្តីសម្រេច ដោយអនុលោមតាមប្រព័ន្ធនៃការធ្វើសេចក្តីសម្រេចជាប្រពៃណី ឬតាមការចង់បានរបស់ពួកគេដែរ ឬទេ?
- តើអ្នកមានសេរីភាពក្នុងការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍របស់អ្នកពីព័ត៌មានលម្អិតដើម្បីធានានូវការសម្រេចបានការព្រមព្រៀងដែរ ឬទេ? តើកិច្ចព្រមព្រៀងដែលបានចរចា និងចងកាតព្វកិច្ចផ្លូវច្បាប់ទទួលបានលទ្ធផលដែរ ឬទេ?
- តើសហគមន៍មានសេរីភាពក្នុងការទទួលបានការណែនាំផ្លូវច្បាប់ ឬជំរុញឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន ពាក់ព័ន្ធនឹងការជ្រើសរើសរបស់ខ្លួនដែរ ឬទេ?
- តើសហគមន៍យល់ព្រមលើការប្រើប្រាស់ដីរបស់ពួកគេសម្រាប់គម្រោងដែរ ឬទេ?
- តើអ្នកមានឯកសារថតចម្លងនៃកិច្ចព្រមព្រៀងនោះដែរ ឬទេ? ប្រសិនបើទេ តើបុគ្គលដែលអ្នកជឿជាក់មានឯកសារថតចម្លងនោះដែរ ឬទេ?
- ប្រសិនបើមានការសម្រេចបានកិច្ចព្រមព្រៀង តើបុគ្គលគ្រប់រូបយល់ថា កិច្ចព្រមព្រៀងទាំងនោះមានយុត្តិធម៌ដែរឬទេ? តើកិច្ចព្រមព្រៀងទទួលបានការគាំទ្រពេញលេញពីគ្រួសារ និងសហគមន៍ទាំងអស់ដែលរងផលប៉ះពាល់ដែរ ឬទេ?
- តើប្រជាជនទទួលបានការទូទាត់ ដំណោះស្រាយ ឬអត្ថប្រយោជន៍សមស្រប ស្របតាមកិច្ច

ព្រមព្រៀងដែរ ឬទេ?

- តើមានការជំទាស់ក្នុងចំណោមសមាជិកសហគមន៍ដែរ ឬទេ? ប្រសិនបើមាន តើសមាជិកណាខ្លះដែលមិនយល់ស្របនឹងកិច្ចព្រមព្រៀង? ហេតុអ្វី? (គួរផ្តោតសំខាន់លើចំណុចនេះដើម្បីធានាអនាមិកភាពរបស់អ្នកផ្តល់បទសម្ភាសន៍ប្រសិនបើពួកគេបានស្នើឡើង)។
- តើមានជម្លោះដីធ្លីដែលមិនទាន់បានដោះស្រាយរវាងសហគមន៍ដែរ ឬទេ? និងរវាងប្រជាជនមូលដ្ឋាន ឬសហគមន៍ និងក្រុមហ៊ុន ឬរដ្ឋាភិបាលដែរ ឬទេ?
- តើមានការត្រៀមរៀបចំយន្តការដើម្បីដោះស្រាយជម្លោះនោះដែរ ឬទេ?
- តើយន្តការទាំងនេះអាចទទួលយកបានសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ដែរ ឬទេ? ហើយតើយន្តការទាំងនោះមានប្រសិទ្ធភាពដែរ ឬទេ?
- តើសហគមន៍របស់អ្នកនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីគម្រោងនេះ?
- តើសហគមន៍របស់អ្នកនឹងបាត់បង់អត្ថប្រយោជន៍អ្វីខ្លះដោយសារគម្រោងនេះ?
- ក្នុងករណីដែលមានការសន្យាផ្តល់អត្ថប្រយោជន៍ តើអត្ថប្រយោជន៍ទាំងនេះមានលក្ខណៈបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍? តើអ្នកមានកស្តុតាងបញ្ជាក់ដែរ ឬទេ?
- តើនឹងមានអ្វីកើតឡើងចំពោះដីដែលប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់អ្នក នៅពេលដែលក្រុមហ៊ុនចាកចេញ?
- តើអ្នកនឹងត្រូវផ្លាស់ប្តូរទីលំនៅដោយសារតែគម្រោងដែរ ឬទេ? ប្រសិនបើដូច្នេះ តើវាកើតឡើងដោយរបៀបណា និងនៅពេលណា?
- តើគម្រោងនឹងបង្កផលប៉ះពាល់អ្វីខ្លះ លើលទ្ធភាពរបស់អ្នកក្នុងការទទួលបានចំណីអាហារ និងរបរចិញ្ចឹមជីវិត?
- ហេតុអ្វីបានជាដីដែលអ្នកប្រើប្រាស់មានសារសំខាន់ចំពោះអ្នក?
- តើបរិស្ថាននឹងទទួលរងផលប៉ះពាល់យ៉ាងដូចម្តេចដោយសារគម្រោង?
- តើអ្វីខ្លះជាសិទ្ធិជាប្រពៃណី និងការប្រើប្រាស់ដី និងធនធានធម្មជាតិរបស់អ្នក?
- ក្នុងនាមជាសហគមន៍ តើអ្នកមានតម្រូវការអ្វីខ្លះ? តើតម្រូវការណាខ្លះដែលមានសារសំខាន់បំផុត? ហើយតម្រូវការណាខ្លះដែលមិនសូវមានសារសំខាន់?
- តើនរណាជាអ្នកផ្តល់ការព្រមព្រៀងពីសហគមន៍របស់អ្នក? តើអ្នកយល់ថា តំណាងរបស់អ្នកអាចទុកចិត្តបានដែរ ឬទេ?
- តើអ្នកបង្កើតគម្រោងនឹងធ្វើការវាយតម្លៃផលប៉ះពាល់លើសង្គម យេនឌ័រ បរិស្ថាន និងសិទ្ធិមនុស្សដែរ ឬទេ? តើអ្នកមានឱកាសចូលរួមក្នុងការវាយតម្លៃនោះ ឬទេ?
- តើអ្នកមានឱកាសអ្វីខ្លះក្នុងការផ្តល់ធាតុចូលទៅក្នុងការរៀបចំ និងការគ្រប់គ្រងគម្រោង?
- តើនរណាជាអ្នកទទួលខុសត្រូវ និង/ឬចូលរួមក្នុងគម្រោង? (បុគ្គលទាំងនោះ អាចរួមមានរដ្ឋាភិបាលមូលដ្ឋាន ឬបរទេសក្រុមហ៊ុនអន្តរជាតិ ឬក្នុងស្រុកអាជ្ញាធរមូលដ្ឋាន និងធនាគារឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ)។

- តើអ្នកបានដឹងអ្វីខ្លះពីប្រវត្តិ និងកេរ្តិ៍ឈ្មោះរបស់អ្នកបង្កើតគម្រោង?
- តើអ្នកស្គាល់បុគ្គលដែលត្រូវបញ្ជូនក្ដីកង្វល់របស់អ្នកទៅរដ្ឋាភិបាល និងក្រុមហ៊ុនដែរ ឬទេ?
- តើអ្នកអាចស្វែងរកព័ត៌មានឯករាជ្យពីគម្រោងនៅកន្លែងណា?
- តើអ្នកយល់ថា អ្នកមានលទ្ធភាពទទួលបានព័ត៌មានគ្រប់គ្រាន់ដែរ ឬទេ? តើព័ត៌មាននេះត្រូវបានបង្ហាញក្នុងរបៀបដែលមានលក្ខណៈពេញលេញ និងផ្ដល់អត្ថប្រយោជន៍ដល់អ្នកដែរ ឬទេ?
- តើអ្នកយល់ថា អ្នកទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើសេចក្ដីសម្រេចដែរ ឬទេ?
- តើអ្នកយល់ថា អ្នកបានចូលរួមគ្រប់គ្រាន់ក្នុងការចរចា និងការធ្វើសេចក្ដីសម្រេចដែរ ឬទេ?
- តើអ្នកនឹងទាមទារដំណោះស្រាយអ្វីខ្លះ ប្រសិនបើអ្នកបាត់បង់ដីធ្លី?
- តើអ្នកបានមើលឃើញពីការផ្ដល់ដំណោះស្រាយសមស្របអ្វីខ្លះ សម្រាប់ការធ្វើឱ្យខូចខាតកេរ្តិ៍ម៌តកវប្បធម៌ ដូចជា បូជនីយដ្ឋាន និងការអនុវត្តជាប្រពៃណី?
- តើអ្នកមានលទ្ធភាពទទួលបានប្រភពព័ត៌មានឯករាជ្យដែរ ឬទេ?
- តើសហគមន៍របស់អ្នកធ្លាប់មានគម្រោងអភិវឌ្ឍន៍ក្នុងរយៈពេលកន្លងមកដែរ ឬទេ? តើអ្នកទទួលបានបទពិសោធន៍អ្វីខ្លះពីគម្រោងទាំងនោះ?
- តើអ្នកយល់ថា អ្នកបានយល់ដឹងពីសិទ្ធិរបស់អ្នកតាមច្បាប់របស់ប្រទេសអ្នកដែរ ឬទេ?
- តើមានរចនាសម្ព័ន្ធនៃការធ្វើសេចក្ដីសម្រេច និងការចរចាអ្វីខ្លះក្នុងប្រទេសរបស់អ្នក?
- តើអ្នកអាចធ្វើអ្វីបានខ្លះ ប្រសិនបើក្រុមហ៊ុន អាជ្ញាធររដ្ឋាភិបាល ឬសមាជិកសហគមន៍របស់អ្នកបំពានលើកិច្ចព្រមព្រៀងដែលអ្នកបានធ្វើឡើង?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកសម្រេចជំទាស់គម្រោងក្នុងរយៈពេល១០ ឬ២០ឆ្នាំខាងមុខ?

### សំណួរដែលអ្នកត្រូវឆ្លើយ៖ **ក្រុមហ៊ុន និងវិនិយោគិន**

- តើមានប្រជាជនរស់នៅក្នុងតំបន់គម្រោងគោលដៅដែរ ឬទេ? ប្រសិនបើមាន តើការទាមទារ សិទ្ធិ និងការប្រើប្រាស់អ្វីខ្លះ ដែលប្រជាជនទាំងនេះមានលើដីក្នុងតំបន់នោះ?
- តើអ្វីជាបរិបទប្រវត្តិសាស្ត្រ និងនយោបាយរបស់ប្រទេសអ្នក? តើបរិបទទាំងនេះ អាចជះឥទ្ធិពល និងបន្តជះឥទ្ធិពលលើសហគមន៍មូលដ្ឋាននិងទំនាក់ទំនងរបស់សហគមន៍ទៅនឹងដីធ្លីដោយរបៀបណា?
- តើអ្វីជាស្ថានភាពស្របច្បាប់របស់ដី? តើស្ថានភាពនេះនឹងផ្លាស់ប្ដូរដោយរបៀបណា នៅពេលដែលអ្នកទទួលបានដី?
- តើអ្នកយល់ថា អ្នកមានការយល់ដឹងច្បាស់លាស់ពីច្បាប់ជាតិទាក់ទងនឹងលទ្ធកម្មដីធ្លីដែរ ឬទេ?
- តើច្បាប់ជាតិបានគាំទ្រដល់ស្តង់ដារដោយស្ម័គ្រចិត្តរបស់ឧស្សាហកម្មអ្នកក្នុងកម្រិតណា? តើអាជ្ញាធររដ្ឋា-ភិបាលមានការយល់ដឹងកម្រិតណាពីស្តង់ដារដោយស្ម័គ្រចិត្តទាំងនេះ?
- តើច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិអ្វីខ្លះដែលត្រូវបានចុះហត្ថលេខា អនុម័ត និង/ឬផ្ដល់សច្ចាប័នដោយប្រទេសដែលអ្នកប្រតិបត្តិការ?

- តើអ្នកអាចរៀនសូត្រអ្វីខ្លះពីការអនុវត្តរបស់ក្រុមហ៊ុនដទៃ ពាក់ព័ន្ធនឹងដំណើរការព្រមព្រៀងដោយសេរី និងដោយជូនដំណឹងជាមុន ឬពីកង្វះដំណើរការនេះ?
- តើនឹងមានការពិចារណាអ្វីខ្លះពីទម្រង់នៃដំណោះស្រាយ និងវិធានការកាត់បន្ថយផលប៉ះពាល់ក្នុងការការពារបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន?
- តើនឹងមានការផ្តល់ឱកាសការងារដល់សហគមន៍មូលដ្ឋានដែរឬទេ? ប្រសិនបើមាន តើមានលក្ខខណ្ឌអ្វីខ្លះ?
- តើក្រុមហ៊ុនរបស់អ្នកមានគោលនយោបាយ ឬនីតិវិធីច្បាស់លាស់ស្តីពីការព្រមព្រៀងដោយសេរី និងដោយជូនដំណឹងជាមុនដែលចងភ្ជាប់កាតព្វកិច្ចដែរ ឬទេ? តើការណ៍នេះបានជួយរៀបចំដំណើរការនៃទំនាក់ទំនង និងការចរចាជាបន្តបន្ទាប់ និងម្តងហើយម្តងទៀតដោយរបៀបណា ក្នុងវដ្តគម្រោង និងការធ្វើផែនការទាំងមូល?
- តើភាសា និងគ្រាមភាសាអ្វីខ្លះដែលប្រើប្រាស់ក្នុងប្រទេស និងដោយសហគមន៍មូលដ្ឋាន? តើព័ត៌មាននឹងត្រូវបានផ្សព្វផ្សាយ និងកត់ត្រាដោយរបៀបណា ប្រសិនបើសហគមន៍មិនចេះអក្សរ?
- តើគំរូជាប្រពៃណីនៃការធ្វើសេចក្តីសម្រេច ការចរចា និងការស្វែងរកការព្រមព្រៀងនឹងត្រូវបានលើកមកពិចារណាក្នុងដំណើរការព្រមព្រៀងដោយសេរី និងដោយជូនដំណឹងជាមុនដោយរបៀបណា?
- តើមានការរៀបចំការវាយតម្លៃបរិស្ថាន និងសង្គមដែរ ឬទេ? ប្រសិនបើមាន តើសហគមន៍មូលដ្ឋាននឹងអាចចូលរួមក្នុងការវាយតម្លៃនោះដោយរបៀបណា?
- តើអ្នកនឹងធានាថា ព័ត៌មានត្រូវបានត្រៀមរួចជាស្រេចជាទម្រង់ និងភាសាសមស្របសម្រាប់សហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលដោយរបៀបណា ក្នុងករណីមានការស្នើសុំ?
- តើនរណាជាអ្នកទទួលខុសត្រូវលើការពិនិត្យតាមដាន និងវាយតម្លៃកិច្ចព្រមព្រៀងដែលបានធ្វើឡើងរវាងអ្នក និងសហគមន៍?
- តើអ្នកបានត្រៀមរៀបចំធនធានអ្វីខ្លះ និងរយៈពេលយូរប៉ុណ្ណាសម្រាប់ដំណើរការព្រមព្រៀងដោយសេរី និងដោយជូនដំណឹងជាមុន?
- តើនរណាជាតំណាងសហគមន៍ដែលអ្នកនឹងធ្វើទំនាក់ទំនងជាមួយ? តើនរណាជាអ្នកជ្រើសរើសពួកគេ?
- តើអ្នកបានត្រៀមរៀបចំការគាំទ្រ ឬហិរញ្ញវត្ថុអ្វីខ្លះដើម្បីផ្តល់ដល់សហគមន៍មូលដ្ឋានក្នុងការជួយឱ្យពួកគេទទួលបានប្រភពព័ត៌មានឯករាជ្យ?
- តើអ្នកបានពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលជាតិដែលមានជំនាញផ្នែកសិទ្ធិជាប្រពៃណី និងកម្មសិទ្ធិដីធ្លីដែរ ឬទេ?
- តើអ្នកនឹងធានាថា សហគមន៍ទទួលបានព័ត៌មានគ្រប់គ្រាន់ពីលក្ខណៈគម្រោងរបស់អ្នក និងផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងរបស់គម្រោង ទាំងវិជ្ជមាន និងអវិជ្ជមាន ដោយរបៀបណា?
- តើមានការផ្តល់ការបណ្តុះបណ្តាលអ្វីខ្លះដល់បុគ្គលចុះតាមមូលដ្ឋានរបស់អ្នក ស្តីពីដំណើរការព្រមព្រៀងដោយសេរី និងដោយជូនដំណឹងជាមុន និងស្តង់ដារដោយស្ម័គ្រចិត្តរបស់ឧស្សាហកម្មរបស់អ្នក?
- ប្រសិនបើកើតមានជម្លោះ តើគេអាចដោះស្រាយដោយរបៀបណា? តើនរណាជាអ្នកដោះស្រាយ?

## សំណួរដែលអ្នកត្រូវឆ្លើយ ៖ **មន្ត្រីរដ្ឋាភិបាល**

- តើនរណាកំពុងរស់នៅក្នុងតំបន់គម្រោងគោលដៅ? តើអ្វីខ្លះជាស្ថានភាព និងសិទ្ធិផ្លូវការ និងក្រៅផ្លូវការរបស់ពួកគេយោងតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ?
- តើអ្វីជាប្រវត្តិប្រតិបត្តិការរបស់ក្រុមហ៊ុនពាក់ព័ន្ធ? តើក្រុមហ៊ុនទាំងនោះត្រូវគោរពតាមស្តង់ដារដោយស្ម័គ្រ-ចិត្តអ្វីខ្លះ?
- តើលិខិតុបករណ៍អន្តរជាតិអ្វីខ្លះ ដែលប្រទេសរបស់អ្នកបានចុះហត្ថលេខា អនុម័ត ឬផ្តល់សច្ចាប័ន? តើលិខិតុបករណ៍ទាំងនោះមានភាពស៊ីសង្វាក់គ្នានឹង ឬបញ្ចូលទៅក្នុងច្បាប់ជាតិដោយរបៀបណា?
- តើនរណាជាអ្នកតំណាងឱ្យសហគមន៍មូលដ្ឋាន? តើតំណាងទាំងនេះត្រូវបានជ្រើសរើសដោយរបៀបណា?
- តើសហគមន៍មូលដ្ឋានបានចូលរួមក្នុង និងទទួលបានព័ត៌មានពីការចរចា និងដំណើរការធ្វើសេចក្តីសម្រេចក្នុងរយៈពេលយូរប៉ុណ្ណា មុនពេលចុះហត្ថលេខាលើកិច្ចសន្យា?
- តើអ្វីជាស្ថានភាពស្របច្បាប់របស់តំបន់គោលដៅគម្រោង? តើស្ថានភាពនោះស្ថិតក្រោមយុត្តាធិការរបស់នរណា?
- តើនឹងមានអ្វីកើតឡើងចំពោះដីក្នុងតំបន់គម្រោង នៅពេលដែលការជួលត្រូវបានបញ្ចប់? តើមានការបញ្ជាក់ច្បាស់ពីចំណុចនេះដល់សហគមន៍មូលដ្ឋានដែរ ឬទេ?
- តើគម្រោងនឹងផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់សហគមន៍មូលដ្ឋាន?
- តើសហគមន៍មូលដ្ឋានត្រូវប្រឈមនឹងហានិភ័យអ្វីខ្លះ តាមរយៈការផ្តល់ការព្រមព្រៀងលើគម្រោង? តើពួកគេនឹងទទួលបានដំណោះស្រាយដោយរបៀបណា?
- តើអ្នកនឹងព្យាយាមធ្វើឱ្យព័ត៌មានស្តីពីគម្រោងមានលក្ខណៈពេញលេញក្នុងទម្រង់ និងភាសាសមស្របសម្រាប់សហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលដោយរបៀបណា?
- តើស្តង់ដារដោយស្ម័គ្រចិត្តអ្វីខ្លះ ដែលក្រុមហ៊ុនត្រូវគោរពតាម? តើស្តង់ដារទាំងនេះ អាចត្រូវបានកែសម្រួលដោយច្បាប់ជាតិជាធរមានដោយរបៀបណា?
- តើលក្ខណវិនិច្ឆ័យ និងនីតិវិធីអ្វីខ្លះ ដែលមានស្រាប់ ឬត្រូវបង្កើតឡើងដើម្បីបញ្ជាក់ពីរបៀបដែល រដ្ឋាភិបាលគួរអនុវត្តការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត?
- តើអ្នកអាចធានាថា គម្រោងនឹងផ្តល់ផលប្រយោជន៍ច្រើនដល់សហគមន៍មូលដ្ឋានដោយសមធម៌ និងមិនមានអំពើពុករលួយដោយរបៀបណា?
- តើស្ថាប័ន និងបុគ្គលពាក់ព័ន្ធមានកាយសម្បទាន ហិរញ្ញវត្ថុ ចំណេះដឹង និងសមត្ថភាពកម្រិតណាក្នុងការទទួលខុសត្រូវលើកិច្ចការនេះ?
- តើសហគមន៍មូលដ្ឋានមានការយល់ដឹងពី និងអាចទទួលបានយន្តការស្របច្បាប់ក្នុងកម្រិតណា ប្រសិនបើពួកគេចង់ដាក់ពាក្យបណ្តឹង?
- តើមានផែនទីអ្វីខ្លះពាក់ព័ន្ធនឹងតំបន់គម្រោងគោលដៅ? តើផែនទីទាំងនោះ តំណាងឱ្យការទាមទារយក និងការប្រើប្រាស់ដីដែលប្រើប្រាស់ជាលក្ខណៈប្រពៃណី ក្នុងកម្រិតណា?

- តើវិធានការអ្វីខ្លះ ដែលនឹងត្រូវអនុវត្តឡើង ប្រសិនបើគម្រោងធ្វើឱ្យមានការផ្លាស់ប្តូរទីលំនៅរបស់សហគមន៍មូលដ្ឋាន?
- តើអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អាចផ្តល់ព័ត៌មានអំពីសកម្មភាពរបស់មន្ត្រីដោយរបៀបណា? តើអង្គការទាំងនោះ អាចបំពេញតួនាទីអ្វីខ្លះ ក្នុងដំណើរការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត?
- តើមានទណ្ឌកម្មអ្វីខ្លះ ដែលបានរៀបចំរួចជាស្រេច ឬត្រូវរៀបចំឡើងដើម្បីធានាថា ប្រតិបត្តិការទាំងនេះ គោរពសិទ្ធិរបស់សហគមន៍មូលដ្ឋាន?
- តើរដ្ឋាភិបាលកំពុងធ្វើអ្វីខ្លះ ដើម្បីសម្របសម្រួល ឬអនុញ្ញាតឱ្យក្រុមហ៊ុនអនុលោមតាមស្តង់ដារអន្តរជាតិ និងស្តង់ដារដោយស្ម័គ្រចិត្ត?
- តើច្បាប់ ឬគោលនយោបាយរដ្ឋ បានជួយ ឬបង្កឧបសគ្គដល់ការគោរពការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត ដោយរបៀបណា?

សំណួរដែលអ្នកត្រូវឆ្លើយ៖ **អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល** និងអង្គការជនជាតិដើមភាគតិច

- តើចំណុចអ្វីខ្លះដែលធ្វើឱ្យបទពិសោធន៍ និងគោលបំណងរបស់អ្នកមានភាពពាក់ព័ន្ធ និងសមស្របក្នុងការចូលរួមក្នុងដំណើរការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត?
- តើអ្នកអាចធានាបានដោយរបៀបណាថា មានការផ្សព្វផ្សាយព័ត៌មានបានគ្រប់គ្រាន់ដល់សហគមន៍មូលដ្ឋានក្នុងទម្រង់សមស្របដូចជា ព័ត៌មានស្តីពីជម្រើសជំនួសឱ្យការអភិវឌ្ឍដែលបានស្នើឡើង និងព័ត៌មានទិតៀនពីការអភិវឌ្ឍដែលបានស្នើឡើង?
- តើអ្នកផ្តល់ព័ត៌មានដល់ភាគីផ្សេងទៀតដូចជា រដ្ឋាភិបាល និងក្រុមហ៊ុន ដោយរបៀបណា?
- តើមានបណ្តាញអង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់ ឬប្រទេសរបស់អ្នក ដើម្បីគាំទ្រដល់ការចែករំលែកបទពិសោធន៍ និងមេរៀនក្នុងសហគមន៍មូលដ្ឋានដែរ ឬទេ?
- តើសកម្មភាពកសាងសមត្ថភាពអ្វីខ្លះ ដែលអ្នកអាចផ្តល់ដល់សហគមន៍មូលដ្ឋានដើម្បីជួយឱ្យពួកគេបង្ហាញ ពីទស្សនៈ និងប្រើប្រាស់សិទ្ធិនយោបាយ?
- តើសត្យានុម័តភាព តម្លាភាព និងគណនេយ្យភាពសកម្មភាព និងមូលហេតុរបស់អ្នកអាចត្រូវបានធានាដោយតួអង្គផ្សេងទៀតដោយរបៀបណា?
- តើអ្នកអាចធានាការប្រុងប្រយ័ត្ន និងការគ្រប់គ្រងដោយឯករាជ្យរបស់អង្គការអ្នកដោយរបៀបណា?
- តើអ្នកអាចបំពេញតួនាទីអ្វីខ្លះ ក្នុងនាមជាអ្នកសម្របសម្រួលក្នុងដំណើរការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត?
- តើអ្នកអាចគាំទ្រមន្ត្រីរដ្ឋាភិបាល និងក្រុមហ៊ុនក្នុងការអនុវត្តដំណើរការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្តដោយរបៀបណា?

- តើអ្នកអាចគាំទ្រសហគមន៍មូលដ្ឋានក្នុងការបង្កើត និងទទួលបានយន្តការបណ្តឹងសាទុក្ខដោយរបៀបណា?
- តើអ្នកយល់ថា ប្រព័ន្ធឃោសនាបានផ្សព្វផ្សាយព័ត៌មានបានត្រឹមត្រូវក្នុងកម្រិតណា ដល់តួអង្គ និងសាធារណៈជនក្នុងប្រទេសរបស់អ្នក?
- ក្រៅពីដំណើរការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត តើកំណែទម្រង់ផ្លូវច្បាប់ និងនីតិវិធីកំណត់ស្តង់ដារអ្វីខ្លះ ដែលអ្នកយល់ថាត្រូវបង្កើតឡើង ក្នុងប្រទេសរបស់អ្នក?
- តើអ្នកនឹងព្យាយាមធានាថា ការព្រមព្រៀងដែលបានធ្វើឡើង ឬលុបចោល បានឆ្លុះបញ្ចាំងពីទស្សនៈរបស់សហគមន៍ដោយរបៀបណា?
- តើអ្នកនឹងត្រូវមានតួនាទីអ្វីខ្លះ ក្នុងការពិគ្រោះយោបល់ និងការចរចា?
- តើអ្នកយល់ថា សហគមន៍មូលដ្ឋាន ទទួលបានព័ត៌មានក្នុងកម្រិតណា? តើគេអាចបំពេញបន្ថែមលើព័ត៌មានមិនគ្រប់ជ្រុងជ្រោយ ដោយរបៀបណា?
- តើការព្រមព្រៀងត្រូវធ្វើឡើងដោយសេរី ដោយសហគមន៍មូលដ្ឋានដែរ ឬទេ? ប្រសិនបើទេ តើគេអាចធានាចំណុចនេះ បានដោយរបៀបណា?
- តើអ្នកបានដឹងអ្វីខ្លះអំពីប្រវត្តិប្រតិបត្តិការរបស់ក្រុមហ៊ុន? តើក្រុមហ៊ុនគោរពតាមស្តង់ដារដោយ
- ស្ម័គ្រចិត្តអ្វីខ្លះ?
- តើសហគមន៍មូលដ្ឋានមានការយល់ដឹងកម្រិតណាអំពីសិទ្ធិរបស់ខ្លួន យោងតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ? តើគេអាចរៀបចំការបណ្តុះបណ្តាលអ្វីខ្លះ ដើម្បីបង្កើនការយល់ដឹងនេះដូចជា ការយល់ដឹងរបស់ពួកគេពាក់ព័ន្ធនឹងការព្រមព្រៀងជាមុនដោយស្ម័គ្រចិត្ត?

# ឧបសម្ព័ន្ធ ៣ ៖
# ឯកសារយោង និងអំណានបន្ថែម


**Amazon Watch.** 2011. *The right to decide: the importance of respecting free, prior and informed consent.* San Francisco & Washington, DC.

**Anderson, P.** 2011. *Free, prior, and informed consent: principles and approaches for policy and project development.* Bangkok, The Center for People and Forests (RECOFTC) & Deutsche Gesellschaft für Internationale Zusammenarbeit (GIZ).

**Barsh, R.L. & Bastien, K.** 1997. *Effective negotiation by indigenous peoples: an action guide with special reference to North America.* Geneva, International Labour Organization.

**CBD.** 2004. *Akwe: Kon voluntary guidelines for the conduct of cultural, environmental and social impact assessments regarding developments proposed to take place on, or which are likely to impact on, sacred sites and on lands and waters traditionally occupied or used by indigenous and local communities.* Montreal, Secretariat of the Convention on Biological Diversity.

**Colchester, M.** 2010. *Free, prior and informed consent: making FPIC work for forests and peoples.* The Forests Dialogue, Research Paper No. 11. New Haven, Connecticut, USA, Yale.

**Edwards, K., Triraganon, R., Silori, C. & Stephenson, J.** 2012. *A training manual: putting free, prior, and informed consent into practice in REDD+ initiatives.* The Center for People and Forests (RECOFTC), the Institute for Global Environmental Strategies (IGES) and the Norwegian Agency for Development Cooperation (Norad).

**EMRIP.** 2011. *Expert Mechanism advice no. 2 (2011): indigenous peoples and the right to participate in decision-making.* Geneva, The Expert Mechanism on the Rights of Indigenous Peoples.

**FAO.** 2009. *Participatory land delimitation: an innovative development model based upon securing rights acquired through customary and other forms of occupation,* by C. Tanner, P. de Wit and S. Norfolk. Land Tenure Working Paper 13. Rome.

**FAO.** 2010. FAO *Policy on Indigenous and Tribal Peoples.* Rome.

**FAO.** 2012. *Voluntary guidelines on the responsible governance of tenure of land, fisheries and forests in the context of national food security.* Rome.

**FAO.** 2013. *Governing land for women and men: a technical guide to support the achievement of responsible gender-equitable governance of land tenure.* Governance of tenure technical guide No. 1. Rome.

**Forest Carbon Partnership Facility & UN-REDD Programme.** 2011. *Draft guidelines on stakeholder engagement in REDD+ readiness with a focus on the participation of indigenous peoples and other forest-dependent communities.*

**Forest Peoples Programme.** 2008. *Free, prior and informed consent and the roundtable on sustainable palm oil: a guide for companies.* Moreton-in-Marsh, UK, Forest Peoples Programme.

**Herbertson, K., Ballesteros, A.R., Goodland, R. & Munilla, I.** 2009. *Breaking ground: engaging communities in extractive and infrastructure projects.* Washington, DC, World Resources Institute.

**Hill, C., Lillywhite, S. & Simon, S.** 2005. *Guide to free, prior and informed consent.* Carlton, Victoria, Australia, Oxfam Australia.

**IFC.** 2007. *Stakeholder engagement: a good practice handbook for companies doing business in emerging markets.* Washington, DC, International Finance Corporation.

**MacKay, F.** 2002. *Addressing past wrongs: indigenous peoples and protected areas: the right to restitution of lands and resources.* Moreton-in-Marsh, Forest Peoples Programme.

**Martin, S.** 2007. *Free, prior and informed consent: the role of mining companies.* Carlton, Victoria, Australia, Oxfam Australia.

**Mehta, L & Stankovich, M.** 2000. *Operationalisation of free prior informed consent.* Brighton, UK, Institute of Development Studies.

**Nelson, J.** 2007. *An overview of community mapping with FPP in Cameroon.* Moreton-in-Marsh, UK, Forest Peoples Programme.

**Phalan, B., Onial, M., Balmford, A. & Green, R.E.** 2011. *Reconciling food production and biodiversity conservation: Land sharing and land sparing compared.* Science 333(6047):1289–1291

**Puño, J.D. & Gutiérrez Laya, O.** 2007. *Starting point: self-determination – a Peruvian case study.* Moreton-in-Marsh, UK, Forest Peoples Programme.

**RSB.** 2011. *RSB guidelines for land rights: respecting rights, identifying risks, avoiding and resolving disputes and acquiring lands through free, prior and informed consent.* Geneva, Roundtable on Sustainable Biofuels.

**Sohn, J. (ed.)** 2007. Development without conflict: the business case for community consent. Washington, DC, World Resources Institute.

**UN Permanent Forum on Indigenous Issues (UNPFII).** 2005: *Report of the International Workshop on Methodologies Regarding Free, Prior and Informed Consent and Indigenous Peoples.* Document E/C.19/2005/3, submitted to the Fourth Session of the UNPFII, 16 – 17 May.

**UN-REDD Programme.** 2013. *UN-REDD Programme guidelines on free, prior and informed consent.* Geneva.

**World Bank.** 2005. Operational Policy 4.10: Indigenous Peoples. Washington, DC.

**World Commission on Dams.** 2000. *Dams and development: a new framework. The report of the World Commission on Dams.* London, Earthscan.

លទ្ធកម្មដីធ្លីដោយពុំមានច្បាប់ គ្រប់គ្រងត្រឹមត្រូវ បានក្លាយជាបញ្ហាចម្បង ជាពិសេស ក្នុងអនុតំបន់អាហ្វ្រិក សាហារ៉ា និងអាស៊ីអាគ្នេយ៍ ដោយបង្កជាការគំរាមកំហែងដល់សន្តិសុខស្បៀង ជីវភាពរស់នៅក្នុងមូលដ្ឋាន និងការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពព្រមទាំងធ្វើឱ្យមានជម្លោះដីធ្លី និងការរំលោភសិទ្ធិមនុស្ស។

ក្រុមដែលប្រឈមនឹងហានិភ័យបំផុតគឺក្រុមបាត់បង់ឱកាសក្នុងសង្គមដូចជា ជនជាតិដើមភាគតិច ម្ចាស់កម្មសិទ្ធិដីជាប្រពៃណីផ្សេងទៀត ស្រ្តីប្រជាជនក្រីក្រ និងជនជាតិភាគតិច។

ការណែនាំផ្នែកបច្ចេកទេសស្តីពីការយល់ព្រមដោយពេញចិត្តដោយបានប្រាប់ឱ្យដឹងជាមុន និងទទួលបានព័ត៌មានពេញលេញ (ការយល់ព្រមជាមុន) **(FPIC)** បានកំណត់វិធានការសំខាន់ៗដើម្បីឱ្យស្ថាប័នរដ្ឋាភិបាលគោរព និងការពារការយល់ព្រមជាមុន និងដើម្បីឱ្យអង្គការសង្គមស៊ីវិលអ្នកប្រើប្រាស់ដី និងវិនិយោគិនឯកជននៅជុំវិញពិភពលោកអនុលោមតាមការទទួលខុសត្រូវរបស់ពួកគេពាក់ព័ន្ធនឹងការយល់ព្រមជាមុននេះ។

**អាសយដ្ឋាន៖** អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ
(FAO) Viale delle Terme di Caracalla
00153 ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី
VG-Tenure@fao.org



ISBN 978-92-5-134323-4
9 789251 343234
I3496KM/1/05.21